មាតិកា

I. ខុទ្ទកាល័យព្រះមហាក្សត្រ

១. ព្រះរាជក្រម

២៩-១២-២០០៦ -ព្រះរាជក្រម នស/រកម/១២០៦/០៣៦ ស្តីពីការប្រកាសឱ្យប្រើ ច្បាប់ស្តីពីវិសោធនកម្ម មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃធនាគារជាតិនៃកម្ពុជា ៦៤៧

២. ព្រះរាជក្រឹត្យ

៣០-១២-២០០៦ -ព្រះរាជក្រឹត្យ នស/រកត/១២០៦/៥៣៨ ស្តីពីការកំណត់ជាក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិ អនុមន្ត្រីការបរទេសតាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ៦៥១

II. រាជរដ្ឋាភិបាល

១. អនុក្រឹត្យ

១១-០១-២០០៧ -អនុក្រឹត្យលេខ ០៧ អនក្រ.បក ស្តីពីការរៀបចំនិងការប្រព្រឹត្តិទៅ របស់សភាពាណិជ្ជកម្ម ៦៥៤

១១-០១-២០០៧ -អនុក្រឹត្យលេខ ៤១ អនក្រ.តត ស្តីពីការជូនមេដាយការងារ ៦៦១

១១-០១-២០០៧ -អនុក្រឹត្យលេខ ៤២ អនក្រ.តត ស្តីពីការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ ៦៧១

១១-០១-២០០៧ -អនុក្រឹត្យលេខ ៤៣ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧២

១៦-០១-២០០៧ -អនុក្រឹត្យលេខ ៤៤ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៣

១៦-០១-២០០៧ -អនុក្រឹត្យលេខ ៤៥ អនក្រ.តត ស្តីពីការជូនមេដាយស្ថាបនាជាតិ ៦៧៤

២. សារាចរ

១៦-០១-២០០៧ -សារាចរលេខ ០១ សរ ស្តីពីការផ្តល់របាយការណ៍ អំពីសកម្មភាពការងាររបស់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង ៦៧៥

III. ការិយាល័យនៃក្រសួង

១. ទីស្តីការអគ្គមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

២៩-១២-២០០៦ -ប្រកាសលេខ ១៤០២ សហវ ស្តីពីការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យរដ្ឋ ៦៧៧

២. ទីស្តីការអគ្គមន្ត្រីក្រសួងការពារជាតិ

១៥-០១-២០០៧ -ប្រកាសលេខ ០០៥ ប្រ.ក ស្តីពីរូបសញ្ញាសាកលវិទ្យាល័យការពារជាតិ ៧៥៨

ព្រះរាជក្រម

នស/រកម/១២០៦ /០៣៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ប្រកាសឱ្យប្រើ

ច្បាប់ស្តីពី វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១៨ ខែតុលា ឆ្នាំ២០០៦ នាសម័យប្រជុំរដ្ឋសភាលើកទី៥ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ ហើយក្រុមប្រឹក្សាធម្មនុញ្ញបានពិនិត្យធម្មនុញ្ញភាព និងបានប្រកាសថាស្របនឹងរដ្ឋធម្មនុញ្ញ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

15

ច្បាប់
ស្តីពី
វិសោធនកម្មមាត្រា ១៤ និងមាត្រា ៥៧
នៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា

មាត្រាមួយ.-

មាត្រា ១៤ និងមាត្រា ៥៧ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃធនាគារជាតិនៃកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១៩៦/២៧ ចុះថ្ងៃទី ២៦ ខែ មករា ឆ្នាំ ១៩៩៦ ត្រូវបានធ្វើវិសោធនកម្មដូចតទៅ :

មាត្រា ១៤.- ថ្មី

១- សមាជិកនៃក្រុមប្រឹក្សា ត្រូវតែជាអ្នកដែលគេទទួលស្គាល់ថាមានបទពិសោធន៍ និងកិត្តិនាមក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានអាយុមិនលើសពី ៦៥ ឆ្នាំ ។ សមាជិកទាំងនោះត្រូវបានតែងតាំងសម្រាប់រយៈពេល ៤ ឆ្នាំ និងអាចត្រូវបានតែងតាំងជាថ្មីបាន ។ ចំពោះក្រុមប្រឹក្សាលើកទី ១ ដែលបង្កើតតាមច្បាប់នេះ លើកលែងតែទេសាភិបាល ទេសាភិបាលរង និងតំណាងឱ្យបុគ្គលិកធនាគារកណ្តាល អាណត្តិរបស់សមាជិក ២ រូប ត្រូវចប់ក្នុងរយៈពេល ២ ឆ្នាំ ក្រោយពីថ្ងៃតែងតាំងដោយវិធីចាប់ឆ្នោត ។

សមាជិកក្រុមប្រឹក្សានិងគ្រួសារផ្ទាល់មិនអាចចូលហ៊ុនក្នុងគ្រឹះស្ថានធនាគារ និង ហិរញ្ញវត្ថុណាមួយ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់ធនាគារកណ្តាលឡើយ ។

២_សមាជិកនៃក្រុមប្រឹក្សាត្រូវបានបញ្ឈប់ពីតំណែងក្នុងករណី :

ក_ជាប់ទោសពីបទល្មើសព្រហ្មទណ្ឌ បទល្មើសរដ្ឋបាល ឬពីបទល្មើសផ្នែក សេដ្ឋកិច្ច ឬ ផ្នែកពាណិជ្ជកម្ម ។

ខ_មានសេចក្តីសម្រេចពីក្រុមប្រឹក្សាថាបានប្រព្រឹត្តបំពានទៅលើការហាម ឃាត់ ដែលចែងក្នុងមាត្រា ១៥ និង១៦ នៃច្បាប់នេះ ។

គ_អវត្តមានក្នុងការប្រជុំជាប់ៗគ្នា ៤ ដង លើកលែងតែមានជំងឺ និងក្នុងករណី ប្រធានស័ក្តិ ដែលបានការទទួលស្គាល់ពីក្រុមប្រឹក្សា ។

ឃ_លាឈប់ដោយបានសរសេរជាលាយលក្ខណ៍អក្សរ ។

ង_មិនអាចបំពេញភារកិច្ចរបស់ខ្លួនបាន ដោយបាត់បង់សមត្ថភាពពលកម្ម និងវិបត្តិស្មារតី ។

ច_ធនក្ស័យផ្ទាល់ខ្លួនដែលប្រកាសដោយតុលាការ ។

៣_ការប្រជុំរបស់ក្រុមប្រឹក្សា ត្រូវធ្វើយ៉ាងហោចណាស់ ២ ខែ ម្តង ។

៤_សមាជិកនៃក្រុមប្រឹក្សាត្រូវទទួលកម្រៃក្បាច់វត្តមាន ដែលក្រុមប្រឹក្សាជាអ្នក កំណត់ ។

៥_ទេសាភិបាល និងទេសាភិបាលរងទទួលប្រាក់តម្លៃការជាមូលដ្ឋានពីធនាគារ កណ្តាលស្មើនឹងសមាជិកនៃរាជរដ្ឋាភិបាល ។

4

15

មាត្រា ៥៧ .- ថ្មី

ការត្រួតពិនិត្យបញ្ជីហិរញ្ញវត្ថុរបស់ធនាគារកណ្តាល ត្រូវធ្វើឡើងដោយក្រុមប្រឹក្សាភិបាលធនាគារជាតិនៃកម្ពុជា និងអាជ្ញាធរសវនកម្មជាតិ ។

មាត្រា ពីរ.-

ច្បាប់នេះ ត្រូវបានប្រកាសជាការប្រញាប់ ។

រាជធានីភ្នំពេញថ្ងៃទី២៩ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជត្រាស់បង្គាប់

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

នស/រកម.០៦១២.៥៥៦

បានយកសេចក្តីក្រាបបង្គំទូលថ្វាយ
សូមឡាយព្រះហស្តលេខាព្រះមហាក្សត្រ

នាយករដ្ឋមន្ត្រី

ហត្ថលេខា

ហ៊ុន សែន

បានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី
អគ្គទេសាភិបាលធនាគារជាតិនៃកម្ពុជា

ហត្ថលេខា

ជា ចាន់តូ

លេខ : ១៧. ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ចិនកេង

ព្រះរាជក្រឹត្យ

នស/រកត/១២០៦ /៥៣៨

យើង

ព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១០ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៤០១/០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១.-

ត្រូវបានកំណត់ជាក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ និងចាត់បញ្ចូលទៅក្នុងឋានន្តរស័ក្តិអនុមន្ត្រីការបរទេស តាមលក្ខន្តិកៈដោយឡែក នូវមន្ត្រីរាជការស៊ីវិលរបស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដូចមានរាយនាមខាងក្រោម ៖

១	តាន់ ទុនយោង	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៤
២	នួន ជីវន្ត	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៥
៣	អ៊ិន ចន់	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៥
៤	កែះ សិរីបុត្រ	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៦
៥	ស៊ិន សួន	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៦
៦	ឃួន ពិណ្ណារី	ស	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ៧
៧	អ៊ីង ចេនា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១០
៨	ទូច សុផារ័ត្ន	ស	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១១
៩	យៀប សំណាង	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១១
១០	គាំ សារឿន	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១១
១១	សុខ ខឿន	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១១
១២	ថូ សំណាង	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៣	គ្រីង សុខ	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៤	អ៊ួន ភគិនី	ស	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៥	យោង ចាន់សុតារះ	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៦	កែច គឹមឃន	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៧	សារុន បុប្ផា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៨	ហួយ ពេជ្រវិទូរ	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
១៩	សុខ ភា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៣
២០	សម ជីវ័ន្ត	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៤
២១	សេដ្ឋា បញ្ញា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៤
២២	សំ មុនធា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៤
២៣	យើម ណៃគនារីន្ទ	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៤
២៤	អ៊ុក គុំត្រា	ប	អនុមន្ត្រីការបរទេស	ថ្នាក់លេខ ១៤

មាត្រា ២.-

រាល់ការផ្លាស់ប្តូរស្ថានភាពរដ្ឋបាលរបស់មន្ត្រីរាជការស៊ីវិល នៅក្រោយពេលបញ្ចប់ការកំណត់ក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់ ត្រូវអនុវត្តទាំងស្រុងតាមខ្លឹមសារដែលមានចែងក្នុងលក្ខន្តិកៈដោយឡែក ។

មាត្រា ៣.-

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤.-

សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥.-

ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខា តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ ធ្នូ ឆ្នាំ ២០០៦

ក្នុងព្រះបរមនាម និងតាមព្រះរាជបញ្ជាសបន្ទាប់

៣រល.០៦១២.៥៧៤

ប្រមុខរដ្ឋស្តីទី

ហត្ថលេខា និងព្រះរាជលញ្ឆករ

ជា ស៊ីម

លេខ : ៧៤ ច.ល

ដើម្បីចម្លងចែក

រាជធានីភ្នំពេញ ថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៧

អគ្គលេខាធិការរងរាជរដ្ឋាភិបាល

ឃុន ជិនកេន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ.....០៩.....អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការរៀបចំនិងការប្រព្រឹត្តទៅ របស់សភាពាណិជ្ជកម្មកម្ពុជា

* * * * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស/ រកត/ ០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលបានប្រកាសអោយប្រើ ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០៦៩៥/ ០៣ ចុះថ្ងៃទី ២២ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស / រកម /០៨០៦/ ០២២ ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៦ ស្តីពីវិសោធនកម្មមាត្រា ២ និងមាត្រា ១៥ នៃច្បាប់ស្តីពីសភាពាណិជ្ជកម្ម
- បានឃើញ ព្រះរាជក្រមលេខ នស/ រកម /០១៩៦/ ១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែកញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញ អនុក្រឹត្យលេខ ៤២ អនក្រ.បក ចុះថ្ងៃទី ១៧ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីរបៀបរបប និងការរៀបចំ ការបោះឆ្នោតសភាពាណិជ្ជកម្ម
- តាមសំណើ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

សំ រេ ច

ជំពូកទី ១
បទប្បញ្ញត្តិទូទៅ

មាត្រា ១.-

អនុក្រឹត្យនេះមានគោលដៅកំណត់ការរៀបចំនិងការប្រព្រឹត្តទៅរបស់សភាពាណិជ្ជកម្មកម្ពុជា ។

ជំពូកទី ២
តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធរបស់សភាពាណិជ្ជកម្មកម្ពុជា

មាត្រា ២.-

សភាពាណិជ្ជកម្មខេត្ត-ក្រុងប្រមូលផ្តុំបង្កើតសភាពាណិជ្ជកម្មកម្ពុជា ។

សភាពាណិជ្ជកម្មកម្ពុជាធ្វើសកម្មភាពទូទាំងព្រះរាជាណាចក្រកម្ពុជាហើយគាំទ្រដល់ជំហរ នឹងសកម្មភាពរបស់ពាណិជ្ជកម្មខេត្ត-ក្រុងទាំងឡាយ។ សភាពាណិជ្ជកម្មកម្ពុជា ទទួលបន្ទុកគ្រប់គ្រងសេវាដែលទាក់ទងដល់ពាណិជ្ជកម្ម ឧស្សាហកម្មសិប្បកម្ម កសិកម្ម នឹងអាជីវកម្មផ្សេងទៀត ដែលហួសពីលទ្ធភាពរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុង ។

មាត្រា ៣.-

ភារៈកិច្ចសភាពាណិជ្ជកម្មកម្ពុជា រួមមាន :

- ធ្វើការទំនាក់ទំនងជាមួយសភាពាណិជ្ជកម្មខេត្ត-ក្រុងនឹងជួយសំរបសំរួលការងារ ធ្វើអោយមានការអភិវឌ្ឍន៍
- ចូលរួមអនុវត្តគោលនយោបាយសេដ្ឋកិច្ចពាណិជ្ជកម្មរបស់រាជរដ្ឋាភិបាលដើម្បីបង្កើន សកម្មភាពសេដ្ឋកិច្ចក្នុងព្រះរាជាណាចក្រកម្ពុជា
- ផ្តល់ជូនរាជរដ្ឋាភិបាលនូវយោបល់នឹងពត៌មានស្តីពីសេដ្ឋកិច្ចនិងវិនិយោគ
- ជាដៃគូរចរចាជាមួយរាជរដ្ឋាភិបាល ក្នុងនាមតំណាងសហគមន៍ ពាណិជ្ជកម្ម -ឧស្សាហកម្មសិប្បកម្ម- កសិកម្ម នឹង សេវាកម្ម

- ធ្វើទំនាក់ទំនងជាមួយប្រភពសេដ្ឋកិច្ចនិងហិរញ្ញវត្ថុក្រៅប្រទេស
- បំពេញភារកិច្ចដែលហួសពីសមត្ថភាព និងលទ្ធភាពរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុង
- ជាសភាប្រឹក្សាធុរកិច្ចយុទ្ធសាស្ត្រសហប្រតិបត្តិការសេដ្ឋកិច្ច អាយ៉េយ៉ាវ៉ាឌី ចាវប្រាយ៉ា មេគង្គ (ACMECS)
- សម្របសម្រួលសភាពាណិជ្ជកម្មខេត្ត-ក្រុង ឱ្យធ្វើសហប្រតិបត្តិការជាមួយគ្នា ដើម្បីប្រើប្រាស់ សក្តានុពលដែលមាននៅតាមខេត្ត-ក្រុង
- ចូលរួមសកម្មភាពជាមួយសភាពាណិជ្ជកម្មក្នុងតំបន់និងលើសកលលោក
- បង្កើតនិងគ្រប់គ្រង គ្រឹះស្ថានធ្វើអាជីវកម្ម នឹងគ្រឹះស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈ
- ចូលរួមក្នុងការដេញថ្លៃជាសាធារណៈ ដើម្បីទទួលភារៈជាសម្បទានិកនៃសំណង់ សាធារណៈការ ឬទទួលបន្ទុកធ្វើសេវាសាធារណៈ
- ធ្វើរបាយការណ៍ប្រចាំឆ្នាំ ពីសកម្មភាពរបស់ខ្លួន ជូនរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ។

មាត្រា ៤.-

សភាពាណិជ្ជកម្មកម្ពុជាស្ថិតនៅក្រោមអាណាព្យាបាលនៃក្រសួងពាណិជ្ជកម្ម ហើយមានទីស្នាក់ការនៅរាជធានីភ្នំពេញ ។

មាត្រា ៥.-

សភាពាណិជ្ជកម្មកម្ពុជាត្រូវបានតំណាងដោយប្រធានរបស់សភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗ។

មាត្រា ៦.-

សមាជិកសភាពាណិជ្ជកម្មកម្ពុជា មានអាណត្តិ ៣ឆ្នាំហើយត្រូវជ្រើសតាំងសារជាថ្មី នៅក្រោយពេលបោះឆ្នោតជ្រើសតាំងសភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗរាល់៣ឆ្នាំម្តង។

សមាជិកសភាពាណិជ្ជកម្មកម្ពុជា ត្រូវបានជ្រើសរើសបង្គ្រប់ នៅពេលមានកន្លែងទំនេរស្របតាមមាត្រា ៥ នៃច្បាប់នេះ ។

មាត្រា ៧.-

៣០ថ្ងៃយ៉ាងយូរ ក្រោយពេលបោះឆ្នោតប្រចាំ ៣ឆ្នាំម្តង សភាពាណិជ្ជកម្មខេត្ត-ក្រុងនិមួយៗ ត្រូវចាត់តាំងតំណាងរបស់ខ្លួន អោយធ្វើជាសមាជិកសភាពាណិជ្ជកម្មកម្ពុជា។

មាត្រា ៨.-

សភាពាណិជ្ជកម្មកម្ពុជា បំពេញមុខការរបស់ខ្លួនដោយមិនយកប្រាក់បៀវត្ស ឬ ប្រាក់បំណាច់អ្វីឡើយ ។

មាត្រា ៩.-

សភាពាណិជ្ជកម្មកម្ពុជា ត្រូវគ្រប់គ្រងដោយការិយាល័យប្រតិបត្តិ ដែលមានសមាជិកដូចខាងក្រោម :

- ប្រធានមួយរូប
- អនុប្រធាន ជាប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុងទាំងអស់
- ហិរញ្ញិកមួយរូប ជ្រើសរើសក្នុងចំណោម សមាជិកជ្រើសតាំងសភាពាណិជ្ជកម្មខេត្ត-ក្រុង ។
- លេខាធិការមួយរូបជ្រើសរើសក្នុងចំណោមសមាជិកជ្រើសតាំងសភាពាណិជ្ជកម្ម ខេត្ត-ក្រុង ។

មាត្រា ១០.-

ប្រធានសភាពាណិជ្ជកម្មកម្ពុជា ត្រូវបានជ្រើសរើសក្នុងចំណោមប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុងតាមរយៈការបោះឆ្នោតដោយប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុង។

ការបោះឆ្នោតជ្រើសរើសប្រធានត្រូវធ្វើជាពីរជុំ ដោយយកតាមសំលេងភាគច្រើនដាច់ខាត ។ ក្នុងករណីមានសម្លេងស្មើគ្នាត្រូវជ្រើសរើសអ្នកមានអាយុច្រើនជាង ។

ចំពោះហិរញ្ញិក និង លេខាធិការ ការបោះឆ្នោតធ្វើតែមួយជុំ ដោយយកតាមសំលេងភាគច្រើនធម្មតា។

ដោយមានការឯកភាពពីមតិភាគច្រើនពីប្រធានសភាពាណិជ្ជកម្មខេត្តក្រុងប្រធានសភាពាណិជ្ជកម្មកម្ពុជាអាចជ្រើសរើសអនុប្រធានមួយចំនួនថែមទៀត តាមការចាំបាច់ពីក្នុងចំណោមអនុប្រធានសភាពាណិជ្ជកម្មខេត្ត-ក្រុង សំរាប់ជួយការងារ នៅក្នុងសភាពាណិជ្ជកម្មកម្ពុជា ។

មាត្រា ១១.-

ប្រធានសភាពាណិជ្ជកម្មកម្ពុជាជាប្រធានការិយាល័យប្រតិបត្តិមានភារៈកិច្ចដឹកនាំសភាពាណិជ្ជកម្មកម្ពុជា នឹងតំណាងអោយសភាពាណិជ្ជកម្មកម្ពុជាចំពោះមុខអាជ្ញាធរ នឹងក្នុងរាល់សកម្មភាពសង្គម ។

ប្រធានត្រូវដឹកនាំរាល់ការប្រជុំ ។ ក្នុងករណីអវត្តមាន ប្រធានត្រូវចាត់តាំងអនុប្រធានម្នាក់ជំនួស ។ ប្រធានសភាពាណិជ្ជកម្ម មានអាណត្តិ ៣ឆ្នាំ ។

មាត្រា ១២.-

ប្រធានសភាពាណិជ្ជកម្ម ខេត្ត-ក្រុងទាំងអស់ប្រជុំគ្នា ធ្វើការ បោះឆ្នោតជ្រើសរើសការិយាល័យប្រតិបត្តិ

របស់សភាពាណិជ្ជកម្មកម្ពុជា ។ ការបោះឆ្នោតត្រូវបានរៀបចំដោយគណៈកម្មការមួយ ដែលមានសមាជិក ២រូប :

- ប្រធាន ជ្រើសរើសយកសមាជិកដែលមានអាយុច្រើនជាងគេ
- លេខា ជ្រើសរើសយកសមាជិកដែលមានអាយុតិចជាងគេ។

ការបោះឆ្នោតត្រូវមានតំណាងក្រសួងពាណិជ្ជកម្ម ចូលរួម ។

មាត្រា ១៣.-

សភាពាណិជ្ជកម្មកម្ពុជា ត្រូវបង្កើតអគ្គនាយកដ្ឋានមួយ ដើម្បីទទួលបន្ទុកគ្រប់គ្រងការងារប្រចាំថ្ងៃ ។

មាត្រា ១៤.-

ការបង្កើតនិងការប្រព្រឹត្តទៅរបស់អគ្គនាយកដ្ឋាន និងគណៈកម្មការផ្សេង ៗ ទៀត ត្រូវកំណត់ដោយបទបញ្ជាផ្ទៃក្នុង ។

ជំពូកទី ៣

របៀបរបបធ្វើការងាររបស់សភាពាណិជ្ជកម្មកម្ពុជា

មាត្រា ១៥.-

សមាជិកសភាពាណិជ្ជកម្មកម្ពុជាធ្វើការរួមប្រជុំសន្និបាត ៤ដង ក្នុងមួយឆ្នាំ ឬលើសពីនេះតាមការចាំបាច់ តាមសំណើររបស់ប្រធាន ឬតាមសំណើរ របស់រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មឬតាមសំណើរ មួយភាគបីនៃចំនួនសមាជិករបស់សភាពាណិជ្ជកម្មកម្ពុជា។

មាត្រា ១៦.-

ការប្រជុំសន្និបាតអាចប្រព្រឹត្តទៅបានលុះត្រាតែ មានសមាជិកយ៉ាងតិច ២ភាគ៣ ចូលរួម។ ក្នុងករណីដែលកូរ៉ុមនេះមិនគ្រប់គ្រាន់ទេប្រធានត្រូវកោះប្រជុំសារជាថ្មី ក្នុងរយៈពេល១០ថ្ងៃក្រោយ ។ ការអញ្ជើញប្រជុំលើកទី២នេះ មិនត្រូវបានកំណត់កូរ៉ុមឡើយ ។

ការសំរេចរបស់សន្និបាត ដែលអាចយកជាការបាន គឺ សម្លេងភាគច្រើនដាច់ខាតរបស់សមាជិកបានចូលរួម លើកលែងតែការសំរេចលើថវិការប្រចាំឆ្នាំរបស់សភាពាណិជ្ជកម្មកម្ពុជា ។

មាត្រា ១៧.-

រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ត្រូវចាត់មន្ត្រីជាន់ខ្ពស់មួយរូប ឱ្យធ្វើជាមន្ត្រីសំរបសំរួលការងារជាមួយសភាពាណិជ្ជកម្មកម្ពុជា។ មន្ត្រីសំរបសំរួលការងារ ត្រូវចូលរួមគ្រប់ការប្រជុំនឹងសន្និបាតរបស់សភាពាណិជ្ជកម្មកម្ពុជាក្នុងឋានៈ ជាអ្នកពិគ្រោះយោបល់ ។

ជំពូកទី ៤
ហិរញ្ញប្បទាន

មាត្រា ១៨.-

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា ត្រូវបានអនុម័តដោយសន្និបាត តាមសំលេងភាគច្រើន២ភាគ ៣ នៃសមាជិកចូលរួម ។

មាត្រា ១៩.-

ថវិការបស់សភាពាណិជ្ជកម្មកម្ពុជា មានប្រភពមកពី ៖

- វិភាគទានរបស់សមាជិក
- អំណោយឧបត្ថម្ភទាំងក្នុងនិងក្រៅប្រទេស
- ចំណូលពីការគ្រប់គ្រងគ្រឹះស្ថានសាធារណៈ នឹងការដេញថ្លៃនានា
- ចំណូលព្រមទាំងវិភាគទានពីប្រភពផ្សេងៗ ។

មាត្រា ២០.-

រាល់ការចំណាយត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់ហិរញ្ញិក នឹងដោយមានការយល់ព្រម ពីប្រធានសភាពាណិជ្ជកម្មកម្ពុជា ។

ជំពូកទី ៥
អវសានប្បញ្ញត្តិ

មាត្រា ២១.-

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ២២.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ក្រសួងពាក់ព័ន្ធ នឹងអភិបាលខេត្ត-ក្រុងទាំងអស់ ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម ប្រសិទ្ធ

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- រាជកិច្ច
- ឯកសារ-កាលប្បវត្ត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:......៤១......អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ ប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិរជនដែលត្រូវជូនគ្រឿងឥស្សរិយយស

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនមន្ត្រី បុគ្គលិក សមាជិក សមាជិកា និងសប្បុរសជនសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ ខេត្តកោះកុង ខេត្តកំពង់ឆ្នាំង ក្រុងព្រះសីហនុ ខេត្តកំពង់ស្ពឺ ខេត្តកំពត ខេត្តបាត់ដំបង និងក្រសួងព្រះបរមរាជវាំង ចំនួន៣៣៤រូប ដែលមានស្នាដៃល្អក្នុងការបំរើការងារមនុស្សធម៌ជូនកាកបាទក្រហមកម្ពុជាកន្លងមក ដូចមានរាយនាមខាងក្រោម :-

១-ឯកឧត្តម	ស៊ូ ធីរិទ្ធ	ប្រធានកិត្តិយសសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ
២-ឯកឧត្តម	ស្រ៊ី ថេន	ប្រធានគណៈកម្មាធិការសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ
៣-លោក	អ៊ុន សារុន	អនុប្រធានគណៈកម្មាធិការសាខាកក្រក.ខេត្តតាកែវ
៤-លោក	ហ៊ុន សារឿន	លេខាធិការគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
៥-កញ្ញា	នូ សុវណ្ណនី	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
៦-លោក	នួន ខុន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
៧-លោកវេជ្ជ.	អ៊ុំ សុខន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
៨-លោកស្រី	ណាង គីមម៉ើ	សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
៩-លោកស្រី	ឈឹម សុខា	សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
១០-លោក	សិល សុខសារិន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ
១១-លោក	ឈុន ឯម	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តតាកែវ
១២-លោក	ជា សុខ	សមាជិកបំរុងគណៈកម្មាធិការ សាខាកក្រក. ខេត្តតាកែវ
១៣-លោក	សុខ ឡេះ	សមាជិកបំរុងគណៈកម្មាធិការ សាខាកក្រក. ខេត្តតាកែវ
១៤-លោក	ផែ ហ៊េង	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តតាកែវ

១៥-លោក	ឥម ចេន	លេខាធិការគណៈកម្មាធិការ សាខាកក្រក. (អាណត្តិទី ១)
១៦-លោកស្រី	ម៉ែន សុខា	សមាជិកាគណៈកម្មាធិការ សាខាកក្រក. (អាណត្តិទី ១)
១៧-លោក	អ៊ិត សុខ	សមាជិកគណៈកម្មាធិការ សាខាកក្រក. (អាណត្តិទី ១)
១៨-លោក	អ៊ិច ចំរុង	សមាជិកគណៈកម្មាធិការ សាខាកក្រក. (អាណត្តិទី ១)
១៩-លោកស្រី	យ៉ឹម ឈាង	នាយិកា សាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ
២០-លោក	ឆោង ឡៀង	បុគ្គលិករដ្ឋបាល-ហិរញ្ញកិច្ច សាខាកក្រក. ខេត្តតាកែវ
២១-លោក	ម៉ែន គន	បុគ្គលិកស្រាវជ្រាវ និងបេឡា សាខាកក្រក. ខេត្តតាកែវ
២២-លោក	ឡាយ សៅឌេ	ជំនួយការរដ្ឋបាល សាខាកក្រក.ខេត្តតាកែវ
២៣-លោក	ហ៊ិន ម៉ៀច	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ខេត្តតាកែវ
២៤-លោក	ស្រី សៅ	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក. ខេត្តតាកែវ
២៥-លោក	សៅ សាយ	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ខេត្តតាកែវ
២៦-លោក	ម៉ែន នី	បុគ្គលិករបៀប និងបើកបរ សាខាកក្រក.ខេត្តតាកែវ
២៧-លោក	នួន សុខ	អតីតនាយកសាខាកាកបាទក្រហមកម្ពុជា ខេត្តតាកែវ
២៨-លោក	ពូ វណ្ណថន	ប្រធាន អនុសាខាកក្រក.ស្រុកព្រៃកប្បាស ខេត្តតាកែវ
២៩-លោក	ចំនួ សុគន្ធ	ប្រធាន អនុសាខាកក្រក.ស្រុកគីរីវង់ ខេត្តតាកែវ
៣០-លោក	ពឹក សុខលឹម	ប្រធាន អនុសាខាកក្រក.ស្រុកគីរីវង់ ខេត្តតាកែវ
៣១-លោក	ពឹក គឹមចិន	អនុប្រធានអនុសាខាកក្រក.ស្រុកគីរីវង់ ខេត្តតាកែវ
៣២-លោក	ឡេង ចាសនា	ប្រធាន អនុសាខាកក្រក.ស្រុកបាទី ខេត្តតាកែវ
៣៣-លោក	ទ្រាក់ មុន្នី	ប្រធាន អនុសាខា.ស្រុកសំរោង ខេត្តតាកែវ
៣៤-លោក	ជា វណ្ណា	ប្រធាន អនុសាខាកក្រក.ស្រុកត្រាំកក់ ខេត្តតាកែវ
៣៥-លោក	គឹម ចាង	ប្រធាន នុសាខាកក្រក.ស្រុកដូនកែវ ខេត្តតាកែវ
៣៦-លោក	ទំ ឆន	អតីតប្រធាន អនុសាខាកក្រក.ស្រុកទ្រាំង ខេត្តតាកែវ
៣៧-លោក	ឆន រឿន	ប្រធាន នុសាខាកក្រក.ស្រុកទ្រាំង ខេត្តតាកែវ
៣៨-លោក	ស៊ុត ខុន	ប្រធាន អនុសាខាកក្រក.ស្រុកបូរីជលសារ ខេត្តតាកែវ
៣៩-លោក	ហៀង ឃួន	អនុប្រធានអនុសាខាកក្រក.ស្រុកបូរីជលសារ ខេត្តតាកែវ
៤០-លោក	ម៉ែន ភព	ប្រធាន អនុសាខាកក្រក.ស្រុកកោះអណ្តែត ខេត្តតាកែវ
៤១-លោក	នាង សិន	ប្រធាន អនុសាខា កក្រក.ស្រុកអង្គរបុរី ខេត្តតាកែវ
៤២-លោក	ស៊ុម សុខន	ទីប្រឹក្សាយុវជន សាខា កក្រក.ខេត្តតាកែវ
៤៣-ឯកឧត្តម	យុទ្ធ តូច	ប្រធានកិត្តិយស សាខាកក្រក.ខេត្តកោះកុង
៤៤-លោក	អ៊ុន ចាណី	ប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តកោះកុង
៤៥-លោកស្រី	អេង គឹមនាង	អនុ.គណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៤៦-លោក	សួន សីហា	លេខាធិការគណៈកម្មាធិការ សាខាកក្រក.ខេត្តកោះកុង
៤៧-លោកស្រី	កែម យ៉ាន	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៤៨-វរសេនីយ៍ឯក	យន្ត មីន	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៤៩-លោក	នុន ម៉ាន់ម៉ិន	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៥០-លោក	ឈី សាវ៉ែត	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៥១-លោក	ជាន់ គយណូ	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៥២-លោក	ដួង សារឿន	សមាជិកគណៈកម្មាធិការ សាខាកក្រក. ខេត្តកោះកុង
៥៣-លោក	ឡុង សុគន្ធា	បុគ្គលិករដ្ឋបាល-ហិរញ្ញកិច្ច សាខាកក្រក.ខេត្តកោះកុង

៥៤-លោក	ឈួន យ៉ាដា	បុគ្គលិកអភិវឌ្ឍន៍ និងផ្សព្វផ្សាយ សាខាកក្រក. ខេត្តកោះកុង
៥៥-លោក	ឃួន សំអាត	បុគ្គលិកគំរោងអប់រំជំងឺអេដស៍ សាខាកក្រក. ខេត្តកោះកុង
៥៦-លោក	ដឹក ឃួរ	ប្រធានអនុសាខាកក្រក. ស្រុកកំពង់សីលា ខេត្តកោះកុង
៥៧-លោក	គួក សំអាន	ប្រធានអនុសាខាកក្រក. ស្រុកមណ្ឌលសីមា ខេត្តកោះកុង
៥៨-លោក	ឌី មន្នី	ប្រធានអនុសាខាកក្រក.ស្រុកគីរីសាគរ ខេត្តកោះកុង
៥៩-លោក	ហាក់ ឡេង	ប្រធានអនុសាខាកក្រក.ស្រុកស្មាច់មានជ័យ ខេត្តកោះកុង
៦០-លោកស្រី	ហេង ដារ៉ែ	ប្រធានកំពង់ផែស្រែអំបិល
៦១-លោក	ផាន់ សេងខួន	អាជីវករខេត្តកោះកុង
៦២-លោក	ហេង យីស្រ៊ីន	ប្រធានក្រុមហ៊ុនដឹកជញ្ជូនរ៉ូយ៉ាល់ខេមរាខេត្តកោះកុង
៦៣-លោក	សុខ គា	អាជីវករខេត្តកោះកុង
៦៤-លោក	លី ខួន	ប្រធានក្រុមហ៊ុនដឹកជញ្ជូនមិត្តភាពខេត្តកោះកុង
៦៥-លោកវេជ្ជ.	នៅ ម៉ុង	អនុប្រធានមន្ទីរសុខាភិបាលខេត្តកោះកុង
៦៦-លោក	ផាន់ ម៉ិនហ៊ួរ	អគ្គនាយករង ក្រុមហ៊ុន យូធីហ្វ្រី សឹបខេត្តកោះកុង
៦៧-លោក	គង់ ឆេង	អាជីវករខេត្តកោះកុង
៦៨-លោក	ហេង សួន	អ្នកស្ម័គ្រចិត្ត សាខាកក្រក.ខេត្តកោះកុង
៦៩-ឯកឧត្តម	ខូច ម៉ារីម	ប្រធានកិត្តិយស សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពង់ឆ្នាំង
៧០-ឯកឧត្តម	ឈឹម ឆាមដាន	ប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧១-លោកស្រី	កែ ចិន្ទមុនី	អនុប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧២-លោក	អ៊ុន សំអុល	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៣-លោកស្រី	ជោគ សុខ្លា	សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៤-លោក	ឈួរ ចំនួនឡឿន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៥-លោក	ឌូ មណ្ណា	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៦-លោក	ស៊ឹម សារុន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៧-លោកវេជ្ជ.	គឹម សាឡឿន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៧៨-លោកស្រី	សំ សារី	អនុប្រ.គណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ឆ្នាំង (អាណត្តិទី១)
៧៩-លោក	អ៊ុច គឹមឈាង	លេខា.គណៈកម្មាធិការសាខាកក្រក.ខេត្តកំពង់ឆ្នាំង (អាណត្តិទី១)
៨០-លោក	ជួន ជឿន	សមាជិកគណៈកម្មាធិការសាខាកក្រក.ខ.កំពង់ឆ្នាំង (អាណតិទី១)
៨១-លោក	ព្រាក់ សោភ័ណ្ឌ	នាយក សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពង់ឆ្នាំង
៨២-លោក	សោម ស៊ីណាត	បុគ្គលិកអភិវឌ្ឍន៍ សាខា កក្រក.ខេត្តកំពង់ឆ្នាំង
៨៣-កញ្ញា	ចាន់ ម៉ូលី	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៨៤-លោកស្រី	ឃូ ស៊ីម	ភ្នាក់ងារស្រាវជ្រាវរកគ្រួសារ សាខាកក្រក.ខេត្តកំពង់ឆ្នាំង
៨៥-លោក	អៀន ឈៀវ	ប្រធានអនុសាខាកក្រក.ស្រុកកំពង់ត្រឡាច ខេត្តកំពង់ឆ្នាំង
៨៦-លោកជំទាវ	ឡៀម សុខគឹមចិន្ត	ភរិយា ឯកឧត្តម ខូច ម៉ារីម
៨៧-លោក	ភាណុល មិត្រា	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៨៨-លោក	ឡួន នុន	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៨៩-លោក	ស៊ឹម រុន	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩០-លោក	ឡិ សុវណ្ណសំអៀ	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩១-លោក	គុយ ចន្ថា	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩២-លោកស្រី	ម៉ែន សុខា	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង

៩៣-លោកស្រី	ស៊ុំ ចន្ធូ	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៤-លោកស្រី	នួម ហ៊េង ធី ណារ	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៥-លោកស្រី	ឡេង យូសឿន	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៦-លោកស្រី	ចាន់ ចន្ថា	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៧-លោក	រស់ ច័ន្ទកុសល្យ	សប្បុរសជនសាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៨-លោក	ឡៀម សាម៉ាត	ទីប្រឹក្សាយុវជន សាខាកក្រក. ខេត្តកំពង់ឆ្នាំង
៩៩-លោកស្រី	កែន មនោរម្យ	ទីប្រឹក្សាយុវជន សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០០-លោក	អ៊ុយ សំអាត	ទីប្រឹក្សាយុវជន សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០១-លោក	ប្រាក់ ស៊ីថា	អ្នកស្ម័គ្រចិត្ត សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០២-លោកស្រី	ពុំ សីធាន់	អ្នកស្ម័គ្រចិត្ត សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០៣-លោក	ជា យ៉ោន	អ្នកស្ម័គ្រចិត្ត សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០៤-លោក	ប្រាក់ សុផាត	អ្នកស្ម័គ្រចិត្ត សាខាកក្រក. ខេត្តកំពង់ឆ្នាំង
១០៥-ឯកឧត្តម	លូ គីមឈន់	ប្រធានគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១០៦-ឯកឧត្តម	ចេម គីមហេង	អនុប្រធានគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១០៧-ឯកឧត្តម	ស៊ូ ជុំធួរ	សមាជិកគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១០៨-ឧកញ៉ា	ឈឹម ហ៊ុយឡេង	សមាជិកគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១០៩-លោកជំទាវ	ម៉ាន ឈុនហេង	ភរិយា ឯកឧត្តម ស្បោង សារ៉ាត
១១០-លោកស្រី	ប្រាក់ ច័ន្ទសុខា	សមាជិកាគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១១១-លោក	ប្រាក់ ចាន់ធឿន	សមាជិកគណៈកម្មាធិការ សាខាកក្រក. ក្រុងព្រះសីហនុ
១១២-លោក	នេង ហ៊ុយ	នាយក សាខាកាកបាទក្រហមកម្ពុជា ក្រុងព្រះសីហនុ
១១៣-លោក	គាំ សុខុម	បុគ្គលិករដ្ឋបាល-ហិរញ្ញកិច្ច សាខាកក្រក.ក្រុងព្រះសីហនុ
១១៤-លោក	សាន់ បូរិន្ទ	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ក្រុងព្រះសីហនុ
១១៥-លោក	ចេង ម៉ឺន	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ក្រុងព្រះសីហនុ
១១៦-លោក	ឌិន ចុន្នី	ប្រធានអនុសាខាកក្រក.ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ
១១៧-លោក	គីម តូមី	អនុប្រធានអនុសាខាកក្រក.ខ័ណ្ឌស្ទឹងហាវ ក្រុងព្រះសីហនុ
១១៨-លោក	ម៉ុន ហ៊ួរ	ប្រធានអនុសាខាកក្រក.ខ័ណ្ឌព្រៃនប់ក្រុងព្រះសីហនុ
១១៩-លោក	មាស លី	អនុប្រធានអនុសាខាកក្រក.ខ័ណ្ឌព្រៃនបក្រុងព្រះសីហនុ
១២០-លោក	ឆេង ឈឿន	ប្រធានអនុសាខាកក្រក.ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
១២១-លោក	គុយ អាត	អនុប្រធានអនុសាខាកក្រក.ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
១២២-លោក	អ៊ិន សុគន្ធ	សមាជិកអនុសាខាកក្រក.ខ័ណ្ឌមិត្តភាព ក្រុងព្រះសីហនុ
១២៣-លោក	ម៉េង សឿន	ចៅសង្កាត់បឹងតាព្រហ្ម ក្រុងព្រះសីហនុ
១២៤-លោកស្រី	សុខ ណាង	ម្ចាស់សណ្ឋាគារ ឆ្នេរសមុទ្រ ក្រុងព្រះសីហនុ
១២៥-លោក	ម៉ា ស៊ីនឃួន	អគ្គនាយករងកំពង់ផែស្វយ័ត ក្រុងព្រះសីហនុ
១២៦-លោក	សំ សំអាត	នាយខុទ្ទកាល័យសាលា ក្រុងព្រះសីហនុ
១២៧-លោក	សែម គីមចាយ	ប្រ.នាយកដ្ឋានគណនេយ្យកំពង់ផែស្វយ័តក្រុងព្រះសីហនុ
១២៨-លោក	ជា យុទ្ធនីកា	ប្រ.នាយកដ្ឋាន បច្ចេកទេស និងសំណង់ ក្រុងព្រះសីហនុ
១២៩-លោក	ជឹម ជីហេង	នាយករោងចក្រញ៉ូវស្តា ក្រុងព្រះសីហនុក្រុងព្រះសីហនុ
១៣០-លោក	ឈឹម សេងហុង	នាយករោងចក្រស្រាបៀរអង្គរ ក្រុងព្រះសីហនុ
១៣១-លោក	ឡាំ ជឹមហួយ	នាយករោងចក្រលីនតិចថាយ ក្រុងព្រះសីហនុ

១៣២-លោក	ទឹម ភារណ្ណុល	បុគ្គលិកទំនាក់ទំនងទីប្រឹក្សាយុវជន សាខាកក្រក.ក្រុងព្រះសីហនុ
១៣៣-លោក	ខូច ខុន្នី	ទីប្រឹក្សាយុវជន វិ.ក្រុងព្រះសីហនុ សាខាកក្រក. ក្រុងព្រះសីហនុ
១៣៤-លោកស្រី	សែម ផល្លា	ទីប្រឹក្សាយុវជន វិ.ក្រុងព្រះសីហនុ សាខាកក្រក.ក្រុងព្រះសីហនុ
១៣៥-លោក	នាង ចន្ធា	ទីប្រឹក្សាយុវជន អនុវិ.សម្ដេចឪ សាខាកក្រក.ក្រុងព្រះសីហនុ
១៣៦-លោក	និន សាម	ទីប្រឹក្សាយុវជន បឋម.ផ្សារលើ សាខាកក្រក. ក្រុងព្រះសីហនុ
១៣៧-លោកស្រី	ជា ពុន្ធា	ទីប្រឹក្សាយុវជន បឋម.ផ្សារលើ សាខាកក្រក.ក្រុងព្រះសីហនុ
១៣៨-លោក	ម៉ើន សុផាន	អ្នកស្ម័គ្រចិត្ត សាខាកាកបាទក្រហមកម្ពុជា ក្រុងព្រះសីហនុ
១៣៩-លោក	លី ហេង	អ្នកស្ម័គ្រចិត្ត សាខាកាកបាទក្រហមកម្ពុជា ក្រុងព្រះសីហនុ
១៤០-ឯកឧត្តម	ភង ហ៊ាង	ប្រធានកិត្តិយស សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពង់ស្ពឺ
១៤១-លោក	ទូច សារុន	ប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤២-លោក	ម៉ុន ច័ន្ទវណ្ណៈ	លេខាធិការគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៣-លោកស្រី	ម៉ុល សុខលីម	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៤-លោក	ឃួន ឈនាន	សមាជិកគណៈកម្មាធិការសាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៥-លោក	អែម ស៊ីនណារី	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៦-លោក	ខៀវ រិទ្ធ	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៧-លោក	ណែន ឡេងអ៊ីម	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៨-លោក	ឈី ចន្ទ្រធាន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៤៩-លោក	សយ បញ្ញា	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥០-លោក	មិន នឹម	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥១-លោក	ស៊ីម អ៊ុយឃាង	បុគ្គលិករដ្ឋបាល-ហិរញ្ញកិច្ច សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥២-លោក	សុត សុឃន	បុគ្គលិកអភិវឌ្ឍន៍ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥៣-លោក	សួស ម៉ុនស៊ឿន	បុគ្គលិកស្រាវជ្រាវរកគ្រួសារ សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥៤-លោកស្រី	អ៊ិន សារ៉ឿន	ជំនួយការរដ្ឋបាល និងឃ្លាំងឃ្លាំង សាខាកក្រក.ខេត្តកំពង់ស្ពឺ
១៥៥-លោកស្រី	ម៉េង ចន្ធារី	បេឡាធិការ សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពង់ស្ពឺ
១៥៦-លោក	អោ ម៉ាន់ថុន	អ្នកបើកបររថយន្ត សាខាកក្រក. ខេត្តកំពង់ស្ពឺ
១៥៧-លោក	ឡាយ ភង	ប្រធានអនុសាខាកក្រក.ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
១៥៨-លោក	ជី មង	ប្រធានអនុសាខាកក្រក.ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
១៥៩-លោក	ទេព មាន	ប្រធានអនុសាខាកក្រក.ស្រុកភ្នំស្រួចខេត្តកំពង់ស្ពឺ
១៦០-លោក	ពួល នៅ	ប្រធានអនុសាខាកក្រក.ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៦១-លោក	សៅ សុម	អនុប្រធានអនុសាខាកក្រក.ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៦២-លោក	ម៉េង វ៉ាន់	អនុប្រធានអនុសាខាកក្រក.ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
១៦៣-លោក	អ៊ុំ យ៉ុង	អនុប្រធានអនុសាខាកក្រក.ស្រុកភ្នំស្រួច ខេត្តកំពង់ស្ពឺ
១៦៤-លោក	នួន សុខ	អនុប្រធានអនុសាខាកក្រក.ស្រុកថ្ពង ខេត្តកំពង់ស្ពឺ
១៦៥-លោក	ម៉ា សាម៉ាត	អនុប្រធានអនុសាខាកក្រក.ស្រុកគងពិសី ខេត្តកំពង់ស្ពឺ
១៦៦-លោក	ហ៊ុយ ស៊ីធឿន	ប្រធានអនុសាខាកក្រក.ស្រុកបរសេដ្ឋ ខេត្តកំពង់ស្ពឺ
១៦៧-លោក	ខែម សុធី	អនុប្រធានអនុសាខាកក្រក.ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ
១៦៨-លោក	សុខ សាវុន	ប្រធានអនុសាខាកក្រក.ស្រុកច្បារមន ខេត្តកំពង់ស្ពឺ
១៦៩-លោក	អោម អ៊ុម	អនុប្រធានអនុសាខាកក្រក.ស្រុកច្បារមន ខេត្តកំពង់ស្ពឺ
១៧០-លោក	ម៉ែម សារឹម	ប្រធានអនុសាខាកក្រក.ស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ

១៧១-លោក	ជុំ ឆ្នុត	ប្រធានអនុសាខាកក្រក.ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
១៧២-លោក	អ៊ុច ជាងស្រួយ	ប្រធានផ្សារបាត់ដឹង ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៧៣-លោក	អ៊ុច ឈុនធ្វី	អាជីវករស្ថានីយ៍ប្រេងឥន្ធនៈសូគីម៉ិចផ្សារកំពង់ស្ពឺ
១៧៤-លោក	អ៊ុន យុទ្ធី	ប្រធានក្រុមហ៊ុនផ្គត់ផ្គង់ទឹកស្អាត ខេត្តកំពង់ស្ពឺ
១៧៥-លោក	ថេង ម៉ុនថន	បុគ្គលិកទំនាក់ទំនងយុវជន កក្រក.ខេត្តកំពង់ស្ពឺ
១៧៦-លោក	[redacted]	ទីប្រឹក្សាយុវជន កាកបាទក្រហមកម្ពុជា ខេត្តកំពង់ស្ពឺ
១៧៧-លោក	មាស ម៉ុនធឿន	ទីប្រឹក្សាយុវជន កាកបាទក្រហមកម្ពុជា ខេត្តកំពង់ស្ពឺ
១៧៨-លោកស្រី	ឃួន ស៊ីខុន	ប្រធានស្ម័គ្រចិត្តឃុំក្សេមក្សាន្តស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៧៩-លោក	អ៊ុក ឡឿន	អនុប្រធានស្ម័គ្រចិត្តឃុំក្សេមក្សាន្តស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៨០-លោក	ជ័យ សារ៉ាន់	ប្រធានស្ម័គ្រចិត្តឃុំច្បារមនស្រុកច្បារមន ខេត្តកំពង់ស្ពឺ
១៨១-លោកស្រី	ជា អាន	ប្រធានស្ម័គ្រចិត្តឃុំច័ន្ទសែនស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ
១៨២-លោក	ម៉ុច អ៊ីន	ប្រធានស្ម័គ្រចិត្តឃុំរលាំងចកស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
១៨៣-លោកស្រី	ហែម ពៅ	ប្រធានស្ម័គ្រចិត្តឃុំរលាំងគ្រើលស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
១៨៤-លោក	ឡុច សុ	ប្រធានស្ម័គ្រចិត្តឃុំសែនដីស្រុកសំរោងទង ខេត្តកំពង់ស្ពឺ
១៨៥-លោក	ស ទាសនា	ប្រធានស្ម័គ្រចិត្តឃុំសុព័រ ស្រុកច្បារមន ខេត្តកំពង់ស្ពឺ
១៨៦-លោកស្រី	ជិន ចាន់	ប្រធានស្ម័គ្រចិត្តឃុំរកាធំស្រុកច្បារមន ខេត្តកំពង់ស្ពឺ
១៨៧-ឯកឧត្តម	ខូយ ឃុនហ៊ួរ	ប្រធានកិត្តិយស សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពត
១៨៨-លោក	អ៊ុច ម៉េងហួរ	ប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៨៩-លោក	កៅ រិទ្ធ	លេខាធិការគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩០-លោក	គង់ សំណាង	ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩១-លោក	ណែម ស៊ីនួន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩២-លោក	ចាន់ ចេស្តា	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩៣-លោកស្រី	ឆិត សេដ្ឋា	សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩៤-លោក	អ៊ុំ ឈុន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩៥-លោក	អ៊ុច ណីសាន	សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តកំពត
១៩៦-លោក	អ៊ុច វណ្ណារិទ្ធ	សមាជិកភាព សាខាកក្រក.ខេត្តកំពត
១៩៧-លោក	យឹម ម៉ុនធឿន	សមាជិកភាព សាខាកក្រក.ខេត្តកំពត
១៩៨-លោក	គង់ ធឿន	ហេរញ្ញិកគណៈ. សាខាកក្រក.ខេត្តកំពត (អាណត្តិទី ១)
១៩៩-លោក	ម៉ាន់ ចាយ	សមាជិកគណៈ. សាខាកក្រក.ខេត្តកំពត (អាណត្តិទី ១)
២០០-លោក	អ៊ុក ឡាយ	នាយក សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពត
២០១-លោក	គង់ សៀត	បុគ្គលិកអភិវឌ្ឍន៍ សាខាកាកបាទក្រហមកម្ពុជា ខេត្តកំពត
២០២-លោក	ស៊ុម សំណាង	បុគ្គលិកកម្មវិធីអេដស៍ សាខាកក្រក.ខេត្តកំពត
២០៣-លោកស្រី	ឈឹមឡុច សុវណ្ណារី	បុគ្គលិកកម្មវិធីសុខភាពបឋម សាខាកក្រក.ខេត្តកំពត
២០៤-លោក	ខួន សុធី	បុគ្គលិកកម្មវិធីអប់រំជំងឺអេដស៍ សាខាកក្រក.ខេត្តកំពត
២០៥-លោក	ខួន ត្រៀច	បុ.ទឹកស្អាតកម្មវិធីសុខភាពបឋម សាខាកក្រក.ខេត្តកំពត
២០៦-លោកស្រី	ឡាយ សុគន្ធ	បុគ្គលិកកម្មវិធីអេដស៍ សាខាកក្រក.ខេត្តកំពត
២០៧-លោកស្រី	នេត សុធី	បុគ្គលិកកម្មវិធីអេដស៍ សាខាកក្រក.ខេត្តកំពត
២០៨-លោក	នូ សុភារ៉ា	បុគ្គលិកបើកបរកម្មវិធីសុខភាពបឋម សាខាកក្រក.ខេត្តកំពត
២០៩-លោក	សៅ សំបូរ	ប្រធានអនុសាខាកក្រក.ស្រុកកំពត ខេត្តកំពត

២១០-លោក	ម៉ៅ ឆេង	ប្រធានអនុសាខាកក្រក.ស្រុកជុំគីរី ខេត្តកំពត
២១១-លោក	ឃួន សំអាង	ប្រធានអនុសាខាកក្រក.ស្រុកកំពង់ត្រាច ខេត្តកំពត
២១២-លោកស្រី	គង់ ម៉ូរី	សមាជិកាអនុសាខាកក្រក.ស្រុកកំពង់ត្រាច ខេត្តកំពត
២១៣-លោក	ឆេង ម៉ិចុល	ប្រធានអនុសាខាកក្រក.ស្រុកឈូក ខេត្តកំពត
២១៤-លោក	គង់ សាខន	ប្រធានអនុសាខាកក្រក.ស្រុកដងទង់ ខេត្តកំពត
២១៥-លោក	ស៊ឹម ឆេង	ប្រធានអនុសាខាកក្រក.ស្រុកអង្គរជ័យ ខេត្តកំពត
២១៦-លោក	អ៊ឹង ម៉ូង	សមាជិកអនុសាខាកក្រក.ស្រុកអង្គរជ័យ ខេត្តកំពត
២១៧-លោក	មួច សារឹម	ប្រធានអនុសាខាកក្រក.ស្រុកបន្ទាយមាស ខេត្តកំពត
២១៨-លោក	ជា ចាន់លី	សមាជិកអនុសាខាកក្រក.ស្រុក ខេត្តកំពត
២១៩-លោក	ស៊ុំ ចាយ	ប្រធានអនុសាខាកក្រក.ស្រុកកំពង់បាយ ខេត្តកំពត
២២០-លោក	ឯម សុវណ្ណនី	សមាជិកអនុសាខាកក្រក.ស្រុកកំពង់បាយ ខេត្តកំពត
២២១-លោកជំទាវ	អ៊ិន សុគន្ធា	ភរិយា ឯកឧត្តម ខូយ ឃុនហួរ សប្បុរសជនខេត្តកំពត
២២២-លោក	នួន ហួន	សប្បុរសជនខេត្តកំពត
២២៣-លោក	ជឹម ឃិយ	សប្បុរសជនខេត្តកំពត
២២៤-លោក	លី សេង	សប្បុរសជនខេត្តកំពត
២២៥-លោក	ម៉ុន ធារ៉ាង	សប្បុរសជនខេត្តកំពត
២២៦-លោកស្រី	សូរ សាម៉ាន	សប្បុរសជនខេត្តកំពត
២២៧-លោក	ចោង ឡេង	សប្បុរសជនខេត្តកំពត
២២៨-លោក	សំ សុខា	សប្បុរសជនខេត្តកំពត
២២៩-លោក	អ៊ូ ម៉ៃ	ស្នងការនគរបាលខេត្តកំពត
២៣០-លោកស្រី	ហ៊ី គីម	សប្បុរសជនខេត្តកំពត
២៣១-លោកស្រី	ជុំ សុគន្ធា	សប្បុរសជនខេត្តកំពត
២៣២-លោក	លឹម ជី	សប្បុរសជនខេត្តកំពត
២៣៣-លោកស្រី	ជុំ សុខា	សប្បុរសជនខេត្តកំពត
២៣៤-លោកស្រី	អ៊ុច យ៉ានី	សប្បុរសជនខេត្តកំពត
២៣៥-លោកស្រី	ឃឹន មុនី	សប្បុរសជនខេត្តកំពត
២៣៦-លោកស្រី	ស៊ឹម ចន្ថា	សប្បុរសជនខេត្តកំពត
២៣៧-លោក	ឡាយ សារ៉ឿន	សប្បុរសជនខេត្តកំពត
២៣៨-លោក	ម៉ុន ធន	សប្បុរសជនខេត្តកំពត
២៣៩-លោក	សម្បត្តិ សុធារ័ត្ន	សប្បុរសជនខេត្តកំពត
២៤០-លោក	គីម សោភ័ណ្ឌ	សប្បុរសជនខេត្តកំពត
២៤១-លោក	មាស សាម៉ន	អនុប្រធានមន្ទីរសេដ្ឋកិច្ចហិរញ្ញវត្ថុ ខេត្តកំពត
២៤២-លោក	ភួង រដ្ឋា	សប្បុរសជនខេត្តកំពត
២៤៣-លោក	ម៉ុន យោង	អនុប្រធានមន្ទីរសុខាភិបាល ក្រុងកែប
២៤៤-លោក	កែវ សុផាន់	អនុប្រធានមន្ទីរសុខាភិបាល ខេត្តកំពត
២៤៥-ឯកឧត្តម	ប្រាជ្ញ ចន្ទ	ប្រធានកិត្តិយស សាខាកាកបាទក្រហមកម្ពុជា ខេត្តបាត់ដំបង
២៤៦-លោកស្រី	ខៀវ គីមហួច	អនុប្រធានកិត្តិយស សាខាកក្រក.ខេត្តបាត់ដំបង
២៤៧-លោកស្រី	ជួន ទុំ ស្រី សុចិន	សមាជិកាកិត្តិយស សាខាកក្រក.ខេត្តបាត់ដំបង
២៤៨-ឯកឧត្តមឧកញ៉ា	ម៉ុន គីមស៊ាន	ប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង

២៤៩-លោកវេជ្ជ. ញ៉ឹក ម៉ុនឈុម អនុប្រធានគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥០-លោក អេង សាឈឿន លេខាធិការគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥១-លោកស្រី សុខ សុខុន ហេរញ្ញិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥២-លោក សួស សុភ័ក្ត្រ សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៣-លោកស្រី ឈឹម សេង សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៤-លោក លី ម៉េង សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៥-លោក ម៉ៅ ម៉ើ សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៦-លោក អេ សារុម សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៧-លោកស្រី ហេង សុខលីម សមាជិកាគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៥៨-លោក អួន សាយ លេខា.គណៈ. សាខាកក្រក.ខេត្តបាត់ដំបង (អាណត្តិទី១)
២៥៩-លោកស្រី កែវ សារាំង ហេរញ្ញិកគណៈ. សាខាកក្រក.ខេត្តបាត់ដំបង (អាណត្តិទី១)
២៦០-លោក សែម សុខា សមាជិកគណៈកម្មាធិការ សាខាកក្រក.ខេត្តបាត់ដំបង
២៦១-លោកជំទាវ ទិម សារី ប្រាជ្ញ ចន្ទ ប្រធានគណៈស្វែងរកមូលនិធិ សាខាកក្រក.ខេត្តបាត់ដំបង
២៦២-លោកជំទាវ ឈួន ទូច អនុ.គណៈស្វែងរកមូលនិធិ សាខាកក្រក. ខេត្តបាត់ដំបង
២៦៣-លោកស្រី គីម ចាន សេង ម៉ាឡាត់ អនុ.គណៈស្វែងរកមូលនិធិ សាខាកក្រក.ខេត្តបាត់ដំបង
២៦៤-លោក ទុយ គី សមាជិក គណៈស្វែងរកមូលនិធិសាខាកក្រក.ខេត្តបាត់ដំបង
២៦៥-លោក ភង ម៉ិន នាយក សាខាកាកបាទក្រហមកម្ពុជា ខេត្តបាត់ដំបង
២៦៦-លោក ជា ម៉ុល ប្រធានផ្នែករដ្ឋបាល-ហិរញ្ញកិច្ច សាខាកក្រក.ខេត្តបាត់ដំបង
២៦៧-លោកស្រី ស៊ុត ម៉ិ ប្រធានផ្នែកអភិវឌ្ឍន៍ និងត្រៀមបង្ការ សាខាកក្រក.ខេត្តបាត់ដំបង
២៦៨-លោក សាំង ជឿន ភ្នាក់ងារស្រាវជ្រាវរកគ្រួសារ សាខាកក្រក.ខេត្តបាត់ដំបង
២៦៩-លោកស្រី ញាណា នារី ប្រធានអនុសាខាកក្រក.ស្រុកកំរៀង ខេត្តបាត់ដំបង
២៧០-លោក សុខ គង់ ប្រធានកិត្តិយសអនុសាខាកក្រក.ស្រុកកំរៀង ខេត្តបាត់ដំបង
២៧១-លោក ហែន សុផល ប្រធានកិត្តិយសអនុសាខាកក្រក.ស្រុកសំឡូត ខេត្តបាត់ដំបង
២៧២-លោក ឥន្ទ សៅឫទ្ធិ ប្រធានអនុសាខាកក្រក.ស្រុកសំឡូត ខេត្តបាត់ដំបង
២៧៣-លោក គង់ ប៉ែ ប្រធានកិត្តិយសអនុសាខាកក្រក.ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង
២៧៤-លោក សូ សេង ប្រធានអនុសាខាកក្រក.ស្រុកភ្នំព្រឹក ខេត្តបាត់ដំបង
២៧៥-លោក អ៊ុច អឿង ប្រធានអនុសាខាកក្រក.ស្រុកថ្មគោល ខេត្តបាត់ដំបង
២៧៦-លោក ជុំ ស៊ីម ប្រធានអនុសាខាកក្រក.ស្រុកសំពៅលូន ខេត្តបាត់ដំបង
២៧៧-លោក ទឹម ជារ៉េត ប្រធានអនុសាខាកក្រក.ស្រុកបវេល ខេត្តបាត់ដំបង
២៧៨-លោក ឡុំ សោម ប្រធានអនុសាខាកក្រក.ស្រុកមោងឫស្សី ខេត្តបាត់ដំបង
២៧៩-លោក អ៊ុយ រី ប្រធានអនុសាខាកក្រក.ស្រុកបាត់ដំបង ខេត្តបាត់ដំបង
២៨០-លោក អៀម សុខុន ប្រធានអនុសាខាកក្រក.កាកបាទក្រហម ខេត្តបាត់ដំបង
២៨១-លោក សួន សារ៉េត ប្រធានអនុសាខាកក្រក.ស្រុកសង្កែ ខេត្តបាត់ដំបង
២៨២-លោក សំ សៀក ប្រធានអនុសាខាកក្រក.ស្រុករតនៈមណ្ឌល ខេត្តបាត់ដំបង
២៨៣-ឧត្តមសេនីយ៍ទោ ម៉ុន សេង មេបញ្ជាការយោធាភូមិភាគទី៥ ខេត្តបាត់ដំបង
២៨៤-លោក អ៊ុក វឌ្ឍ អភិបាលរងខេត្តបាត់ដំបង
២៨៥-លោក សៀង ស៊ុតថង អភិបាលរងខេត្តបាត់ដំបង
២៨៦-លោក ស្រី សុភិន អភិបាលរងខេត្តបាត់ដំបង
២៨៧-លោក អែល សយ អភិបាលរងខេត្តបាត់ដំបង

២៨៨-លោក	សោម មនោរត្ន	នាយកក្រុមហ៊ុនសាជីវកម្ម S.O.M
២៨៩-ព្រះវិសុទ្ធវង្ស	អ៊ុក ម៉ុត	មេគុណខេត្តបាត់ដំបង
២៩០-លោក	ង៉ោ ហ្វ៊ាំ	នាយកខុទ្ទកាល័យសាលាខេត្តបាត់ដំបង
២៩១-ឧកញ៉ា	ភូ ពុយ	ប្រធានសភាពាណិជ្ជកម្មខេត្តបាត់ដំបង
២៩២-លោក	ឈាន់ សុភាព	ប្រធានក្រុមហ៊ុនទេសចរណ៍កាពីតូល
២៩៣-វរសេនីយ៍ឯក	អ៊ុក យួច	មេបញ្ជាការតំបន់ប្រតិបត្តិការសឹកខេត្តបាត់ដំបង
២៩៤-ឧត្តមសេនីយ៍ត្រី	ភេង សុខន	ស្នងការនគរបាលខេត្តបាត់ដំបង
២៩៥-វរសេនីយ៍ឯក	សូ សំអាន	ស្នងការរងនគរបាលខេត្តបាត់ដំបង
២៩៦-លោក	ខាន់ ម៉ាណោរ	ប្រធានសាធារណៈការ និងដឹកជញ្ជូន ខេត្តបាត់ដំបង
២៩៧-វរសេនីយ៍ឯក	ង៉ោ វណ្ណះ	មេបញ្ជាការកងរាជអាវុធហត្ថខេត្តបាត់ដំបង
២៩៨-លោក	ស្រី សឿន	ប្រធានសាខាគយ និងរដ្ឋាករខេត្តបាត់ដំបង
២៩៩-លោក	ជាម ច័ន្ទសោភ័ណ្ឌ	ប្រធានមន្ទីរកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ខេត្តបាត់ដំបង
៣០០-លោក	ធី សុខុន	ប្រធានសាខាពន្ធដារ ខេត្តបាត់ដំបង
៣០១-លោក	សក់ ចន្ទ្រាវុធ	នាយកវិទ្យាល័យព្រះមុនីវង្ស ខេត្តបាត់ដំបង
៣០២-លោកស្រី	ឃុន គីមឆេង	សមាជិកាសកម្មខេត្តបាត់ដំបង
៣០៣-លោកជំទាវ	សុខ លីម	ភរិយា ឧកញ៉ា **សេន ចំន** សមាជិកាឧបការី
៣០៤-លោក	សាន់ នម	នាយកវិទ្យាល័យ នេត- យ៉ង់ ខេត្តបាត់ដំបង
៣០៥-ឯកឧត្តម	គុយ សុផល	រដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង
៣០៦-ឯកឧត្តម	ជុំ ទៀន	រដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង
៣០៧-ឯកឧត្តម	ឈា ចាន	អនុរដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង
៣០៨-ឯកឧត្តម	អន ស៊ាម	អនុរដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង
៣០៩-ឯកឧត្តម	សូ ស៊ីនួន	អនុរដ្ឋលេខាធិការ ក្រសួងព្រះបរមរាជវាំង
៣១០-ឯកឧត្តម	នួ ឌុម	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១១-ឯកឧត្តម	ភឹម សឿ	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១២-ឯកឧត្តម	ផេង គិរុណា	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៣-ឯកឧត្តម	ឡាក់ គី	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៤-ឯកឧត្តម	យូរ សំអៀល	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៥-ឯកឧត្តម	ម៉ាន់ ម៉ាន	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៦-លោកស្រី	ហេង សុភាន	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៧-លោក	ម៉ែន ទុន្នី	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៨-លោក	នួន វណ្ណះ	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣១៩-លោក	ឆេង ហួត	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣២០-លោក	ឃាន ឈុន	ជំនួយការសម្តេចចៅហ្វាវាំង ក្រសួងព្រះបរមរាជវាំង
៣២១-លោក	ទូន សៅពេង	អ្នករៀបចំរូបភាព ក្រសួងព្រះបរមរាជវាំង
៣២២-លោក	ហូ ឌីណា	អ្នករៀបចំរូបភាព ក្រសួងព្រះបរមរាជវាំង
៣២៣-លោក	សារឹម ម៉ុណ្ណារ៉ា	ទូរទស្សន៍ជាតិកម្ពុជា ក្រសួងព្រះបរមរាជវាំង
៣២៤-លោក	សុត ចាន់ធឿន	អ្នកយ កព័ត៌មានទូរទស្សន៍ជាតិកម្ពុជា ក្រសួងព្រះបរមរាជវាំង
៣២៥-លោក	ឡាច សុភាព	អ្នកថតទូរទស្សន៍ ប្រចាំក្រសួងព្រះបរមរាជវាំង
៣២៦-លោក	កើត ឌឿន	អ្នកវាយកុំព្យូទ័រ ក្រសួងព្រះបរមរាជវាំង

៣២៧-លោក	ឡាយ ខុម	អ្នកវាយកុំព្យូទ័រ ក្រសួងព្រះបរមរាជវាំង
៣២៨-លោក	គាន់ សុមណ្ណា	អ្នកវាយកុំព្យូទ័រ ក្រសួងព្រះបរមរាជវាំង
៣២៩-លោក	ស៊ុន គាម	អ្នករៀបចំតម្លើងវេទិកា និងក្រាលព្រំ ក្រសួងព្រះបរមរាជវាំង
៣៣០-លោក	ណែម អៀម	អ្នករៀបចំតម្លើងវេទិកា និងក្រាលព្រំ ក្រសួងព្រះបរមរាជវាំង
៣៣១-លោក	ភាច គិន	អ្នករៀបចំតម្លើងវេទិកា និងក្រាលព្រំ ក្រសួងព្រះបរមរាជវាំង
៣៣២-លោកស្រី	ផន រចនា	អ្នករៀបចំលំអផ្កា ក្រសួងព្រះបរមរាជវាំង
៣៣៣-លោក	ឈុយ សែម	អ្នករៀបចំលំអវេទិកាកិត្តិយស ក្រសួងព្រះបរមរាជវាំង
៣៣៤-លោក	ជំរ សន	អ្នករៀបចំលំអវេទិកាកិត្តិយស ក្រសួងព្រះបរមរាជវាំង

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងប្រធានគណៈកម្មការពិនិត្យលក្ខណសម្បត្តិវរជនដែលត្រូវជូនគ្រឿងឥស្សរិយយស ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- -ក្រសួងព្រះបរមរាជវាំង
- -អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- -អគ្គលេខាធិការដ្ឋានរដ្ឋសភា
- -អគ្គលេខាធិការរាជរដ្ឋាភិបាល
- -ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- -ដូចក្នុងមាត្រា ១ និង មាត្រា ២
- -រាជកិច្ច
- -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤២ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការសំរួល និង ប្រគល់ភារកិច្ចមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- យោងអនុក្រឹត្យលេខ ៦៣ អនក្រ ចុះថ្ងៃទី ០៨ ខែ កញ្ញា ឆ្នាំ២០០៣ របស់រាជរដ្ឋាភិបាល ស្តីពីការគ្រប់គ្រង ការអនុវត្តន៍ការផ្លាស់ប្តូរក្របខ័ណ្ឌ ឋានន្តរសក្តិ និងថ្នាក់របស់មន្ត្រីរាជការ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានសំរួលភារកិច្ចលោក **អាន ឈឿន** ឋានន្តរសក្តិ អនុមន្ត្រី ថ្នាក់លេខ ១២ ពីអភិបាលស្រុកពាមជរ អោយទៅបំរើការងារនៅសាលាខេត្តព្រៃវែង ដោយរក្សាឋានន្តរសក្តិ និងថ្នាក់ដដែល ។

មាត្រា ២ : ត្រូវបានប្រគល់ភារកិច្ចជូនលោក **ចាន់ ដេត** ឋានន្តរសក្តិ នាយក្រមការ ថ្នាក់លេខ ៣ ជាអភិបាលស្រុកពាមជរ ខេត្តព្រៃវែង ។

មាត្រា ៣ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៤ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មករា ឆ្នាំ២០០៧

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី (ដើម្បីជូនជ្រាប)
- ដូចមាត្រា ៤ (ដើម្បីអនុវត្ត)
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤៣ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ប្រគេន និងជូនសប្បុរសជន ចំនួន០៧រូប ដែលបានបរិច្ចាគធនធានជួយកសាង ព្រះវិហារ សាលាធម្មសភា ជីកស្រះ និង សមិទ្ធផលផ្សេងៗទៀត នៅ ***វត្តអង្គតាពៅ*** ស្ថិតក្នុងឃុំខ្នារ ស្រុកសំរោង ខេត្តតាកែវ ដូចមានរាយព្រះនាមនិងនាមខាងក្រោម :-

ក-មេដាយមាសស្ថាបនាជាតិ :

១-ព្រះតេជគុណ	**ឡេវ ដារ៉ា**	ចៅអធិការវត្ត អង្គតាពៅ	បច្ច័យចំនួន ១៧.៥០០ ដុល្លារ
២-ព្រះតេជគុណ	**ឆែន ម៊ិន**	គង់នៅសហរដ្ឋអាមេរិក	បច្ច័យចំនួន ១០.០០០ ដុល្លារ
៣-លោក	**ឈី ឃាងហេង**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ១២.១៤០ ដុល្លារ

ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោក	**យស ឈឹម**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៤.៥០០ ដុល្លារ
២-លោក	**សោម ទូច**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៤.២៥០ ដុល្លារ
៣-លោក	**ម្រេស ស័យ**	សប្បុរសជននៅសហរដ្ឋអាមេរិក	ថវិកាចំនួន ៣.៤៤២ ដុល្លារ
៤-លោក	**អ៊ុត ម៉ឿន**	សប្បុរសជននៅក្រុងភ្នំពេញ	ថវិកាចំនួន ២.៦០០ ដុល្លារ

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងអភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យ នេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៤៤ អនក្រ.បក [illegible]

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ
៦៧៣

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន សមាគម និង សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា ចំនួន ៣២.៨៦៥ ដុល្លារ ជួយសាងសង់អគារសិក្សា ចំនួន ០១ខ្នង មាន ០៥បន្ទប់ នៅសាលាបឋមសិក្សា ហ៊ុន សែន អណ្តូងថ្ម ក្នុងក្រុងព្រះសីហនុ ដូចមាននាមខាងក្រោម :-
១-លោកស្រី **OSANAI MIEKO** ប្រធានអង្គការ **JHP**
២-សមាគម **Yaita Higaski High School Parent- Teacher Association**

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលក្រុងព្រះសីហនុ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៤៥ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚៚

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូន **Ms. HORI MIDORI** សប្បុរសជនជប៉ុន ដែលបានឧបត្ថម្ភថវិកា ចំនួន ៦១.៤៣៥ ដុល្លារ តាមរយៈអង្គការ **JHP** សំរាប់ជួយសាងសង់ អគារសិក្សា ០១ខ្នង មានកំពស់០២ជាន់ បង្គន់អនាម័យ ០១ខ្នង បំពាក់ដោយសម្ភារៈ និងប្រព័ន្ធអគ្គិសនី នៅសាលាបឋមសិក្សាព្រៃកន្សាយ "ខ" ក្នុងឃុំព្រៃកន្សាយ "ខ" ស្រុកពាមរក៍ ខេត្តព្រៃវែង ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និងអភិបាលខេត្តព្រៃវែង ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មករា ឆ្នាំ ២០០៧

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ០១ សរ

សារាចរ
ស្តីពី
ការផ្តល់របាយការណ៍ អំពីសកម្មភាពការងាររបស់ ក្រសួង ស្ថាប័ន និងខេត្ត ក្រុង

កន្លងមករាជរដ្ឋាភិបាលបានបំពេញភារកិច្ចរៀបចំចងក្រងជារបាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួនលើគ្រប់វិស័យប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ ថ្វាយព្រះមហាក្សត្រ និងជូនស្ថាប័ននីតិប្បញ្ញត្តិ បានទៀងទាត់តាមកាលកំណត់គួរជាទីមោទនៈ។ សមិទ្ធផលដែលរាជរដ្ឋាភិបាលសម្រេចបាននេះ បានមកពីការយកចិត្តទុកដាក់ចូលរួមផ្តល់របាយការណ៍យ៉ាងសកម្ម និងទៀងទាត់ពីក្រសួង ស្ថាប័ន និងខេត្ត ក្រុង ។ ក៏ប៉ុន្តែ ទន្ទឹមនេះ នៅមានក្រសួង ស្ថាប័ន និងខេត្ត ក្រុងមួយចំនួន ពុំទាន់យកចិត្តទុកដាក់ក្នុងការផ្តល់របាយការណ៍ ស្តីពីសកម្មភាពការងាររបស់ខ្លួន ប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងឆ្នាំ មកទីស្តីការគណៈរដ្ឋមន្ត្រីនៅឡើយ ដែលជាហេតុធ្វើឱ្យរបាយការណ៍របស់រាជរដ្ឋាភិបាលមានខ្លឹមសារ និងទិន្នន័យមិនទាន់គ្រប់គ្រាន់តាមលទ្ធផល និងសមិទ្ធផលជាក់ស្តែង ទោះបីជារាជរដ្ឋាភិបាលបានចេញលិខិតជូនដំណឹងក្រើនរំឭកជាច្រើនលើករួចមកហើយក៏ដោយ ។

ម្យ៉ាងវិញទៀត ក្នុងឱកាសបំពេញទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូថ្នាក់ដឹកនាំរដ្ឋាភិបាលបរទេស នៅព្រះរាជាណាចក្រកម្ពុជា ក៏ដូចជាទស្សនកិច្ចជាផ្លូវការរបស់គណៈប្រតិភូរាជរដ្ឋាភិបាលកម្ពុជានៅបរទេស រាជរដ្ឋាភិបាលត្រូវការចាំបាច់ នូវរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការ ឬឯកសារផ្សេងៗដែលក្រសួង ស្ថាប័ន និងខេត្ត ក្រុងសាមី បានចុះហត្ថលេខាជាមួយប្រទេសនានា ឬអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ឬជាមួយខេត្ត ក្រុងជាប់ព្រំដែននៃបណ្តាប្រទេសជាមិត្ត សម្រាប់ជាជំនួយស្មារតីក្នុងការពិភាក្សាជាមួយគណៈប្រតិភូរដ្ឋាភិបាលបរទេស ។

ដើម្បីឆ្លើយតបទៅនឹងតម្រូវការចាំបាច់ខាងលើ និងដើម្បីរំលេចឱ្យឃើញនូវស្នាដៃការងាររបស់ក្រសួង ស្ថាប័ន និងខេត្ត ក្រុង ដែលបានខិតខំយកចិត្តទុកដាក់អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល សម្រាប់នីតិកាលទី ៣ នៃរដ្ឋសភា រាជរដ្ឋាភិបាលធ្វើការណែនាំដូចតទៅ :

១-គ្រប់ក្រសួង ស្ថាប័ន ត្រូវបង្កើតយន្តការមួយដែលមានមន្ត្រីបំពេញការងារជាអចិន្ត្រៃយ៍ ដើម្បីបូកសរុបសកម្មភាពការងាររបស់ខ្លួន ឱ្យមានខ្លឹមសារ និងទិន្នន័យគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងនូវលទ្ធផល និងសមិទ្ធផលទាំងអស់នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល រួចផ្ញើមកទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ ឱ្យបានទៀងទាត់តាមកាលបរិច្ឆេទកំណត់ ដូចខាងក្រោម :

-របាយការណ៍ប្រចាំខែ	សប្តាហ៍ទី១ នៃខែបន្ទាប់
-របាយការណ៍ប្រចាំត្រីមាស	សប្តាហ៍ទី១ នៃខែមេសា
-របាយការណ៍ប្រចាំឆមាស	សប្តាហ៍ទី១ នៃខែកក្កដា
-របាយការណ៍ប្រចាំ៩ខែ	សប្តាហ៍ទី១ នៃខែតុលា
-របាយការណ៍ប្រចាំឆ្នាំ	សប្តាហ៍ទី២ នៃខែធ្នូ ។

២-គ្រប់ខេត្ត ក្រុង ត្រូវបង្កើតយន្តការមួយ ដែលមានមន្ត្រីបំពេញការងារជាអចិន្ត្រៃយ៍ ដើម្បីបូកសរុបសកម្មភាពការងាររបស់ខ្លួន ឱ្យមានខ្លឹមសារ និងទិន្នន័យគ្រប់ជ្រុងជ្រោយ ដោយឆ្លុះបញ្ចាំងនូវលទ្ធផល និងសមិទ្ធផលទាំងអស់នៃការអនុវត្តកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល រួចផ្ញើមកក្រសួងមហាផ្ទៃ ដោយចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី និងក្រសួងផែនការ។

៣-គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុងពាក់ព័ន្ធ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ដោយចម្លងជូនទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងផែនការ នូវរបាយការណ៍ស្តីពីកិច្ចសហប្រតិបត្តិការអន្តរជាតិ ឬការចុះហត្ថលេខាលើឯកសារផ្សេងៗជាមួយខេត្ត ក្រុងជាប់ព្រំដែននៃបណ្តាប្រទេសជាមិត្ត ឬក៏ប្រទេសនានា ឬអង្គការក្រៅរដ្ឋាភិបាលអន្តរជាតិ ដើម្បីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ និងក្រសួងផែនការ បូកសរុបជូនរាជរដ្ឋាភិបាលបានទាន់ពេលវេលា ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន និងខេត្ត ក្រុងទាំងអស់ ត្រូវយកចិត្តទុកដាក់អនុវត្តឱ្យសម្រេចបានលទ្ធផលល្អប្រសើរ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៨ ខែ មករា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- គ្រប់ក្រសួង ស្ថាប័ន
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- គ្រប់សាលាខេត្ត ក្រុង
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ១៤០៧...សហវ.....

រាជធានីភ្នំពេញ. ថ្ងៃទី២៩...ខែ...ធ្នូ...ឆ្នាំ ២០០៦

ប្រកាស

ស្តីពី

ការដាក់អោយអនុវត្តប្លង់គណនេយ្យទូទៅ នៃគណនេយ្យរដ្ឋ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ន.ស / រកម / ០៧០៤ / ០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសអោយប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានាដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ ន.ស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ នស/រកម/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
		544.1	នៅរតនាគារកណ្តាល	ឥណពន្ធ	ឥណទាន	ឥណាយិក
		544.2	នៅរតនាគារខេត្ត-ក្រុង	ឥណពន្ធ	ឥណទាន	ឥណាយិក
ថ្នាក់ ៦ : គណនី ចំណាយ						
60	**ការទិញ**					
	601		សំភារៈ ផ្គត់ផ្គង់ ថែទាំ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6011	សំភារៈផ្គត់ផ្គង់សំអាត និង អនាម័យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6012	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំអាគារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6013	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំផ្លូវថ្នល់ ស្ពាន និងលូ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6014	សំភារៈផ្គត់ផ្គង់សំរាប់ថែទាំសំភារៈ ឧបករណ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6015	ប្រេងឥន្ធនៈ និង ប្រេងរំអិល	ឥណពន្ធ	ឥណទាន	ឥណាយិក
	602		សំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល	ឥណពន្ធ	ឥណទាន	ឥណាយិក
		6021	សំភារៈការិយាល័យ និង ការបោះពុម្ព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6022	សៀវភៅមើល និង ឯកសារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6028	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	603		ស្បៀងអាហារ និង ផលិតផលកសិកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6031	ស្បៀង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6032	ចំណីសត្វ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6033	ពូជ និង កូនរុក្ខជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6034	ផលិតផលការពារសុខុមាលភាពរុក្ខជាតិ និង ជី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6035	ពូជសត្វ ឱសថ និង វត្ថុធាតុសំរាប់បសុពេទ្យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6038	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	604		សំលៀកបំពាក់ និង ការតុបតែង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6041	ឯកសណ្ឋាន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6042	សំលៀកបំពាក់ការពារសុវត្ថិភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6043	មេដាយ (គ្រឿងឥស្សរិយយស)	ឥណពន្ធ	ឥណទាន	ឥណាយិក
		6048	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	605		សំភារៈតូចតាច សង្ហារឹម និង សំភារៈបរិក្ខារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6051	សំភារៈ និង បរិក្ខារ	ឥណពន្ធ	ឥណទាន	ឥណាយិក

		6052	សង្ហារឹម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6053	សំភារៈប្រើប្រាស់	ឥណពន្ធ	ឥណទាន	ឥណាយិក
		6058	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	606		ថាមពល និង ទឹក	ឥណពន្ធ	ឥណទាន	ឥណាយិក
		6061	អគ្គិសនី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6062	ទឹក	ឥណពន្ធ	ឥណទាន	ឥណាយិក
		6068	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	607		សំភារៈបរិក្ខារថែទាំសុខភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
	608		សំភារៈផ្គត់ផ្គង់ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
61	**សេវាខាងក្រៅ**					
	611		កិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស	ឥណពន្ធ	ឥណទាន	ឥណាយិក
	612		ការជួលមធ្យោបាយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
	613		ថ្លៃឈ្នួល និង បន្ទុក (អសង្ហារឹម)	ឥណពន្ធ	ឥណទាន	ឥណាយិក
	614		សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក	ឥណពន្ធ	ឥណទាន	ឥណាយិក
	615		ការថែទាំ និងជួសជុល	ឥណពន្ធ	ឥណទាន	ឥណាយិក
		6151	ការថែទាំដីធ្លី ព្រៃឈើ និងតំបន់ឆ្នេរ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6152	ការថែទាំ និងជួសជុល អាគារ និងប្រាសាទ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6153	ការថែទាំ និងជួសជុល ផ្លូវ ផ្លូវលំ ស្ពាន និងលូ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6154	ការថែទាំបណ្តាញផ្សេង ៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6155	ការថែទាំដែនទេសាទ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6156	ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6157	ការថែទាំ និងជួសជុលសំភារៈ ឧបករណ៍ការិ.សំភារៈពត៌មានវិទ្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
			និង ទូរគមនាគមន៍			
		6158	ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
	616		សោហ៊ុយធានារ៉ាប់រង	ឥណពន្ធ	ឥណទាន	ឥណាយិក
	617		សោហ៊ុយសិក្សា ពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និង	ឥណពន្ធ	ឥណទាន	ឥណាយិក
			នៃការប្រើប្រាស់សិទ្ធិ			
		6171	សោហ៊ុយសិក្សា ពិសោធន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6172	សោហ៊ុយនៃការប្រើប្រាស់សេវា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6173	សោហ៊ុយនៃការប្រើប្រាស់ និងសិទ្ធិ	ឥណពន្ធ	ឥណទាន	ឥណាយិក
	618		សោហ៊ុយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6181	សំភារៈ និង ទំនិញ	ឥណពន្ធ	ឥណទាន	ឥណាយិក
62	**សេវាខាងក្រៅផ្សេងៗ**					
	621		បុគ្គលិកខាងក្រៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6211	ភ្នាក់ងារជាតិជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក

		6212	ភ្នាក់ងារបរទេសជាប់កិច្ចសន្យា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6213	បុគ្គលិក សមូលហភាពសាធារណៈផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	622		ទំនាក់ទំនងសាធារណៈ និង ផ្សព្វផ្សាយ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6221	សោហ៊ុយទទួលភ្ញៀវជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6222	សោហ៊ុយទទួលភ្ញៀវបរទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6223	ប្រជុំ សិក្ខាសាលា និង សន្និសិទ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6224	សោហ៊ុយពិធីបុណ្យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6225	ចំណាយសំរាប់វត្ថុអនុស្សាវរីយ៍ ក្នុង និង ក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6226	សោហ៊ុយសំរាប់ការតាំងពិពណ៌នៅក្នុង និង ក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6227	ការឃោសនា និង ផ្សព្វផ្សាយព័តសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
	623		សោហ៊ុយជាវសារពត៌មាន និង ឯកសារ	ឥណពន្ធ	ឥណទាន	ឥណាយិក
	624		ចំណាយទូទាត់សោហ៊ុយក្នុងប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6241	សោហ៊ុយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6242	សោហ៊ុយបេសកកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6243	សោហ៊ុយស្នាក់នៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
	625		ចំណាយទូទាត់សោហ៊ុយក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6251	សោហ៊ុយដឹកជញ្ជូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6252	សោហ៊ុយបេសកកម្ម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6253	សោហ៊ុយស្នាក់នៅ	ឥណពន្ធ	ឥណទាន	ឥណាយិក
	626		សោហ៊ុយទូរគមនាគមន៍ ទូរសព្ទ៍ តេឡិច ទូរសារប្រៃសណីយ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6261	សោហ៊ុយប្រៃសណីយ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6262	សោហ៊ុយទូរគមនាគមន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
	627		សោហ៊ុយធនាគារ	ឥណពន្ធ	ឥណទាន	ឥណាយិក
	628		សោហ៊ុយផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
63	**ពន្ធ និង អាករ**					
	631		លតាគបត្រ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
64	**បន្ទុកបុគ្គលិក**					
	641		លាភការ និងប្រាក់បំណាច់ នៃអំណាចសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6411	ខុទ្ទកាល័យព្រះបរមរាជវាំង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6412	ប្រាក់បំណាច់ប្រធាន អនុប្រធាន សមាជិកសភាជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6413	ប្រាក់បំណាច់នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6414	ប្រាក់បំណាច់រដ្ឋមន្ត្រី-រដ្ឋលេខាធិការ និង អនុរដ្ឋលេខាធិការ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6415	ប្រាក់បំណាច់អង្គទូត	ឥណពន្ធ	ឥណទាន	ឥណាយិក
		6416	លាភការទីប្រឹក្សា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6417	លាភការ បេសកជន	ឥណពន្ធ	ឥណទាន	ឥណាយិក

		6418	លាភការ អ្នកជំនួយការ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6419	ការសង និង ការបង្វិលវិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
	642		លាភការ និងប្រាក់បំណាច់បុគ្គលិកក្របខណ្ឌអចិន្ត្រៃយ៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6421	បៀវត្សមូលដ្ឋាន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6422	ប្រាក់បំណាច់មុខងារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6423	ប្រាក់បំណាច់ម៉ោងបន្ថែម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6424	ប្រាក់កំរៃគរុកោសល្យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6425	ប្រាក់បំប៉នជីវភាពពិសេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6426	ប្រាក់បំណាច់តំបន់	ឥណពន្ធ	ឥណទាន	ឥណាយិក
		6427	ប្រាក់បំណាច់ទទួលខុសត្រូវ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6428	ប្រាក់បំណាច់ការងារធ្ងន់ និង ប៉ះពាល់សុខភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6429	ការសង និង ការបង្វិលវិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
	643		រង្វាន់ និង ប្រាក់បំណាច់ផ្សេងៗទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
		6431	កន្សោមអាទិភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6432	ប្រាក់បំណាច់សំរាប់ប្រឡង-ប្រឡងប្រជែង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6433	រង្វាន់	ឥណពន្ធ	ឥណទាន	ឥណាយិក
		6434	ប្រាក់បំណាច់បុគ្គលិកក្រសួងផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6435	អាហារសំរាប់បុគ្គលិករដ្ឋ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6438	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6439	ការសង និង ការបង្វិលវិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
	644		លាភការ និងប្រាក់បំណាច់ បុគ្គ.មិនមែនក្របខ័ណ្ឌ និងបុគ្គ.អណ្តែត	ឥណពន្ធ	ឥណទាន	ឥណាយិក
		6441	បៀវត្សមូលដ្ឋានបុគ្គលិកមិនមែនក្របខ័ណ្ឌ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6442	លាភការផ្សេងៗ ទៀតបុគ្គលិកមិនមែនក្របខ័ណ្ឌ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6443	បៀវត្សមូលដ្ឋានបុគ្គលិកអណ្តែត	ឥណពន្ធ	ឥណទាន	ឥណាយិក
		6444	លាភការផ្សេងៗ ទៀតបុគ្គលិកអណ្តែត	ឥណពន្ធ	ឥណទាន	ឥណាយិក
		6449	ការសង និង ការបង្វិលវិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
	645		ប្រាក់វិភាជន៍សង្គម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6451	ប្រាក់បំណាច់ជាលក្ខណៈគ្រួសារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6452	មន្ត្រីមានជំងឺ និង ឧបត្ថម្ភអ្នកសំរាលកូន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6453	មរណៈភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6454	ឧបត្ថម្ភនិវត្តជន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6455	ឧបត្ថម្ភដល់អ្នកសុំឈប់ពីការងារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6456	គ្រោះថ្នាក់ក្នុងការងារ និង ទុព្វលភាព	ឥណពន្ធ	ឥណទាន	ឥណាយិក
		6457	ឧបត្ថម្ភ ដល់កូនកំព្រារបស់មន្ត្រីរាជការ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6458	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក

			6459	ការសង និង ការបង្វិលវិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
65	**ឧបត្ថម្ភធន និង ជំនួយសង្គម**						
	651			ឧបត្ថម្ភធនដល់រដ្ឋបាលដែនដី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6511		ឧបត្ថម្ភធនដល់ខេត្ត -ក្រុង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6512		ឧបត្ថម្ភធន ស្រុក	ឥណពន្ធ	ឥណទាន	ឥណាយិក
		6513		ឧបត្ថម្ភធន ឃុំ សង្កាត់	ឥណពន្ធ	ឥណទាន	ឥណាយិក
	652			ឧបត្ថម្ភធនដល់អង្គការសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
	653			ឧបត្ថម្ភធន ដល់គ្រឹះស្ថានសាធារណៈមានលក្ខណៈរដ្ឋបាល	ឥណពន្ធ	ឥណទាន	ឥណាយិក
	654			ការចូលរួម ក្នុងការអនុវត្តនិគំរោង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6541		ចំណាយចរន្ត ក្នុងការអនុវត្តនិគំរោង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6542		ចំណាយជាមូលធន ក្នុងការអនុវត្តនិគំរោង	ឥណពន្ធ	ឥណទាន	ឥណាយិក
		6549		និយ័តកម្មចំណាយវិនិយោគ	ឥណពន្ធ	ឥណទាន	ឥណាយិក
	655			ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6551		សហគ្រាសសាធារណៈ ឬពាក់កណ្តាលសាធារណៈមិនមាន	ឥណពន្ធ	ឥណទាន	ឥណាយិក
				លក្ខណៈហិរញ្ញវត្ថុ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6552		ឧបត្ថម្ភធនដល់សហគ្រាសសាធារណៈ ឬពាក់កណ្តាលសាធារណៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
				មានលក្ខណៈហិរញ្ញវត្ថុ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6553		ឧបត្ថម្ភធនដល់សហគ្រាសឯកជនមិនមានលក្ខណៈហិរញ្ញវត្ថុ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6554		ឧបត្ថម្ភធនដល់សហគ្រាសឯកជនមានលក្ខណៈហិរញ្ញវត្ថុ	ឥណពន្ធ	ឥណទាន	ឥណាយិក
	656			វិភាគទានដល់អង្គការអន្តរជាតិនានា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6561		អង្គការសហប្រជាជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6561		ធនាគារពិភពលោក	ឥណពន្ធ	ឥណទាន	ឥណាយិក
		6563		ធនាគារអភិវឌ្ឍន៍ អាស៊ី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6564		សហពន្ធអន្តរជាតិខាងកីឡាផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6565		អង្គការអាស៊ាន	ឥណពន្ធ	ឥណទាន	ឥណាយិក
		6568		អង្គការអន្តរជាតិផ្សេងៗ ទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
	657			ជំនួយសង្គម និងប្រាក់វិភាជន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6571		ជំនួយដល់ប្រជាជនសំរាកពេទ្យ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6572		ឱសថ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6573		អាហារ និងសំភារៈ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6574		ជួយជនរងគ្រោះ ដោយគ្រោះធម្មជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6575		ស្បៀងបំរុងរដ្ឋ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6576		អាហារូបករណ៍សំរាប់ការសិក្សា និង ស្រាវជ្រាវក្នុងប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6577		អាហារូបករណ៍សំរាប់ការសិក្សា និង ស្រាវជ្រាវក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6578		ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក

	658		ឧបត្ថម្ភដល់អង្គភាពដែលមានលក្ខណៈសង្គម និង វប្បធម៌	ឥណពន្ធ	ឥណទាន	ឥណាយិក
		6581	ឧបត្ថម្ភ សហគមន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6582	ឧបត្ថម្ភ មណ្ឌលកុមារកំព្រា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6583	ឧបត្ថម្ភ ដំណើរលំហែ និង សិក្សា	ឥណពន្ធ	ឥណទាន	ឥណាយិក
		6584	ឧបត្ថម្ភ កាកបាទក្រហម	ឥណពន្ធ	ឥណទាន	ឥណាយិក
		6585	ឧបត្ថម្ភ សហគមន៍កីឡា និង វប្បធម៌	ឥណពន្ធ	ឥណទាន	ឥណាយិក
		6586	ឧបត្ថម្ភមណ្ឌលស្តារលទ្ធភាពពលកម្ម និតិសម្បទា និងបណ្តុះបណ្តាលអភិវឌ្ឍន៍	ឥណពន្ធ	ឥណទាន	ឥណាយិក
		6587	ចំណាយសង្គមកិច្ចរបស់ព្រះមហាក្សត្រ	ឥណពន្ធ	ឥណទាន	ឥណាយិក
66	**បន្ទុកហិរញ្ញវត្ថុ**					
	661		ការប្រាក់នៃបំណុលក្នុងប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6611	ធនាគារជាតិ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6612	ធនាគារពាណិជ្ជ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6613	ប័ណ្ណរតនាគារ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6614	សញ្ញាប័ណ្ណ	ឥណពន្ធ	ឥណទាន	ឥណាយិក
		6618	ផ្សេងៗ	ឥណពន្ធ	ឥណទាន	ឥណាយិក
	662		ការប្រាក់នៃ បំណុលក្រៅប្រទេស	ឥណពន្ធ	ឥណទាន	ឥណាយិក
		6621	ពហុភាគី	ឥណពន្ធ	ឥណទាន	ឥណាយិក
		6622	ទ្វេភាគី	ឥណពន្ធ	ឥណទាន	ឥណាយិក
	666		ខាតពីការប្តូរប្រាក់	ឥណពន្ធ	ឥណទាន	ឥណាយិក
	668		បន្ទុកហិរញ្ញវត្ថុផ្សេងៗ ទៀត	ឥណពន្ធ	ឥណទាន	ឥណាយិក
67	**បន្ទុកពិសេស**					
	671		ឥណទេយ្យដែលទទួលស្គាល់តែទារមិនបាន	ឥណពន្ធ	ឥណទាន	ឥណាយិក
	675		តំលៃគណនេយ្យចំណែកសកម្មបានលក់ (តំលៃនៅសល់)	ឥណពន្ធ	ឥណទាន	ឥណាយិក
68	**ទាយជ្ជទានអោយដល់រំលស់អចលកម្ម**					
	681		ទាយជ្ជទានអោយដល់រលស់អចលកម្មអរូបី	ឥណពន្ធ	ឥណទាន	ឥណាយិក
	682		ទាយជ្ជទានអោយដល់រំលស់អចលកម្មរូបី	ឥណពន្ធ	ឥណទាន	ឥណាយិក
ថ្នាក់ ៧ : គណនី ចំណូល						
70	**ចំណូលសារពើពន្ធក្នុងប្រទេស**					
	700		ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុនរូបវន្តបុគ្គល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7001	ពន្ធលើប្រាក់បៀវត្ស	ឥណទាន	ឥណពន្ធ	ឥណទាយី
		7002	ពន្ធលើផលទុននៃដីធ្លី ផ្ទះសំបែង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7003	ពន្ធលើផលចំណេញពីការលក់អចលនៈទ្រព្យ	ឥណទាន	ឥណពន្ធ	ឥណទាយី
	701		ពន្ធលើផលទុនប្រាក់ចំណេញ និង កំរៃទុននីតិបុគ្គល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7011	ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7012	ពន្ធលើប្រាក់ចំណេញរបស់សហគ្រាសឯកជន	ឥណទាន	ឥណពន្ធ	ឥណទាយី

		7013	ពន្ធលើផលទុននៃដីធ្លីផ្ទះសំបែង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7014	ពន្ធលើផលចំណេញពីការលក់អចលនទ្រព្យ	ឥណទាន	ឥណពន្ធ	ឥណទាយី
	702		ពន្ធទូទៅលើទ្រព្យសម្បត្តិ និង សេវា	ឥណទាន	ឥណពន្ធ	ឥណទាយី
		7021	អាករលើផលរបរ- របបផ្ទៃក្នុង- សហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7022	អាករលើផលរបរ- របបផ្ទៃក្នុង- សហគ្រាសឯកជន	ឥណទាន	ឥណពន្ធ	ឥណទាយី
		7023	អាករលើតំលៃបន្ថែម -របបផ្ទៃក្នុង- សហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7024	អាករលើតំលៃបន្ថែម- របបផ្ទៃក្នុង- សហគ្រាសឯកជន	ឥណទាន	ឥណពន្ធ	ឥណទាយី
		7025	អាករលើតំលៃបន្ថែម-របបនាំចូល- សហគ្រាសប្រេងឥន្ធនៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7026	អាករលើតំលៃបន្ថែម-របបនាំចូល -សហគ្រាសផ្សេងៗទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
	703		ពន្ធលើទ្រព្យសម្បត្តិបានកំណត់	ឥណទាន	ឥណពន្ធ	ឥណទាយី
		7031	អាករពិសេសលើទំនិញមួយចំនួន-របបផ្ទៃក្នុង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7032	អាករពិសេសលើទំនិញមួយចំនួនរបបនាំចូលសហគ្រាសប្រេងឥន្ធនៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7033	អាករពិសេសលើទំនិញមួយចំនួនរបបនាំចូល	ឥណទាន	ឥណពន្ធ	ឥណទាយី
	704		អាករលើសេវាដែលបានកំណត់	ឥណទាន	ឥណពន្ធ	ឥណទាយី
		7041	អាករលើកាស៊ីណូ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7042	អាករលើឆ្នោត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7043	អាករលើល្បែងកម្សាន្តផ្សេងៗ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7044	អាករអាកាសយានដ្ឋាន	ឥណទាន	ឥណពន្ធ	ឥណទាយី
		7048	អាករពិសេសលើសេវាមួយចំនួនផ្សេងៗ ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
	705		អាករលើការប្រើប្រាស់ទ្រព្យសម្បត្តិ ឬការអនុវត្តន៍សកម្មភាព	ឥណទាន	ឥណពន្ធ	ឥណទាយី
		7051	អាជ្ញាបណ្ណនាំចេញឈើ	ឥណទាន	ឥណពន្ធ	ឥណទាយី
	708		ចំណូលសារពើពន្ធផ្សេងៗទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7081	ពន្ធតែមប្រិ៍	ឥណទាន	ឥណពន្ធ	ឥណទាយី
		7082	ការផាកពិន័យ និងទោសបញ្ញត្តិសារពើពន្ធ	ឥណទាន	ឥណពន្ធ	ឥណទាយី
	709		ការសង និងការបង្វិលវិញ	ឥណពន្ធ	ឥណទាន	ឥណាយិក
		7090	លើគណនី ៧០០	ឥណពន្ធ	ឥណទាន	ឥណាយិក
		7091	លើគណនី ៧០១	ឥណពន្ធ	ឥណទាន	ឥណាយិក
		7092	លើគណនី ៧០២	ឥណពន្ធ	ឥណទាន	ឥណាយិក
		7093	លើគណនី ៧០៣	ឥណពន្ធ	ឥណទាន	ឥណាយិក
		7094	លើគណនី ៧០៤	ឥណពន្ធ	ឥណទាន	ឥណាយិក
		7095	លើគណនី ៧០៥	ឥណពន្ធ	ឥណទាន	ឥណាយិក
		7098	លើគណនី ៧០៨	ឥណពន្ធ	ឥណទាន	ឥណាយិក
71	**ចំណូលពន្ធ លើពាណិជ្ជកម្មក្រៅប្រទេស**					
	710		ពន្ធ និងអាករលើការនាំចូល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7101	ពន្ធគយពីការនាំចូល	ឥណទាន	ឥណពន្ធ	ឥណទាយី

		7102	កំរៃយកមុនពីការងារគយក្នុងការនាំចូល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7103	ពន្ធគយលើផលិតផលតែលសិលា	ឥណទាន	ឥណពន្ធ	ឥណទាយី
		7104	អាករបន្ថែមលើផលិតផលតែលសិលាសំរាប់ថែទាំផ្លូវថ្នល់	ឥណទាន	ឥណពន្ធ	ឥណទាយី
		7105	ផលនៃការលក់ផ្នែកគយ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7106	ពិន័យផ្សេងៗ លើការនាំចូល	ឥណទាន	ឥណពន្ធ	ឥណទាយី
	711		ពន្ធ និង អាករនៃការនាំចេញ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7111	អាករនៃការនាំចេញឈើ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7112	អាករនៃការនាំចេញកៅស៊ូ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7113	អាករនៃការនាំចេញផលិតផលកសិផលផ្សេងៗ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7114	ចំណូលពីកូតានាំចេញ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7115	ពិន័យផ្សេងៗ នៃការនាំចេញ	ឥណទាន	ឥណពន្ធ	ឥណទាយី
72	**ផលទុននៃទ្រព្យសម្បត្តិរដ្ឋ**					
	720		ផលនៃការជួលដីធ្លី	ឥណទាន	ឥណពន្ធ	ឥណទាយី
		7201	ផលនេសាទ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7202	ផលព្រៃឈើ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7203	សម្បទានពីប្រេងកាត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7204	សម្បទានរ៉ែ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7205	ការជួលដីទំនេរ	ឥណទាន	ឥណពន្ធ	ឥណទាយី
	721		ផលទុនពីសហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7211	ចំនួនលើសនៃទុនចល័ត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7212	ប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7213	ការបង់ប្រាក់រំលស់	ឥណទាន	ឥណពន្ធ	ឥណទាយី
73	**ផលទុនលើការលក់ ជួលទ្រព្យសម្បត្តិ និង សេវា**					
	730		សហគ្រាសសាធារណៈ រដ្ឋបាល និងសេវាដំណើរការ (រកចំណេញ)	ឥណទាន	ឥណពន្ធ	ឥណទាយី
		7301	ផលទុនរបស់អាកាសចរណ៍ស៊ីវិល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7302	ផលទុននៃសកម្មភាពភាពយន្ត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7303	ផលទុននៃសកម្មភាពទេសចរណ៍	ឥណទាន	ឥណពន្ធ	ឥណទាយី
		7304	ផលទុននៃសកម្មភាពវប្បធម៌	ឥណទាន	ឥណពន្ធ	ឥណទាយី
		7305	ផលទុនពីប្រៃសណីយ៍ និង ទូរគមនាគមន៍	ឥណទាន	ឥណពន្ធ	ឥណទាយី
		7306	ផលទុនពីវិទ្យុ និងទូរទស្សន៍	ឥណទាន	ឥណពន្ធ	ឥណទាយី
		7307	ផលទុននៃរដ្ឋាករទឹក	ឥណទាន	ឥណពន្ធ	ឥណទាយី
		7308	ផលទុនផ្សេង ៗ ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
	731		រដ្ឋបាល និង សេវា (មិនរកចំណេញ)	ឥណទាន	ឥណពន្ធ	ឥណទាយី
		7311	ការលក់សំភារៈបរិក្ខា-សំភារៈខូតខាត-សំភារៈសិក្សា	ឥណទាន	ឥណពន្ធ	ឥណទាយី
		7312	លក់ឯកសារ-លតាប័ត្រ-និងលិខិតបោះពុម្ពផ្សេងៗ	ឥណទាន	ឥណពន្ធ	ឥណទាយី

		7313	ផលនៃការដឹកជញ្ជូនទំនិញ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7314	ផលនៃប្រតិបត្តិការអន្តរាគមន៍ដើម្បីថែទាំកិច្ចដំណើរការ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7315	កំរៃនៃការថែទាំ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7316	ផលបានពីការលក់ទ្រព្យសម្បត្តិកំទេចកំទី សត្វពាហនៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
	732		ផលពីការគ្រប់គ្រងរដ្ឋបាល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7321	អាករស្ថានទូត (ចំណូលពីលិខិតឆ្លងដែន និង ទិដ្ឋាការ)	ឥណទាន	ឥណពន្ធ	ឥណទាយី
		7322	ផលពីការចុះបញ្ជីគណៈបក្សនយោបាយ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7323	ផលលើការបង្កើតសហគ្រាស	ឥណទាន	ឥណពន្ធ	ឥណទាយី
		7324	ផលពីការបង់សិទ្ធប្រឡង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7325	ផលពីការលក់ផ្លាកលេខ	ឥណទាន	ឥណពន្ធ	ឥណទាយី
		7326	ចំណូលពីប្រដាប់ក្តី	ឥណទាន	ឥណពន្ធ	ឥណទាយី
		7327	សេវាសុរិយោដី	ឥណទាន	ឥណពន្ធ	ឥណទាយី
		7328	ផលពីការត្រួតពិនិត្យគុណភាពផលិតផលនិងការគោរពបទដ្ឋាន	ឥណទាន	ឥណពន្ធ	ឥណទាយី
	733		ការជួលទ្រព្យសម្បត្តិអចល័ត	ឥណទាន	ឥណពន្ធ	ឥណទាយី
		7331	ការជួលសហគ្រាសសាធារណៈនៅថ្នាក់រដ្ឋបាលកណ្តាល	ឥណទាន	ឥណពន្ធ	ឥណទាយី
		7332	ការជួលសហគ្រាសសាធារណៈនៅ ខេត្ត-ក្រុង (មន្ទីរជំនាញ)	ឥណទាន	ឥណពន្ធ	ឥណទាយី
		7333	ការជួលសំភារៈ និង មធ្យោបាយដឹកជញ្ជូន	ឥណទាន	ឥណពន្ធ	ឥណទាយី
		7334	ការជួលអចលកម្ម (អសង្ហារឹម)	ឥណទាន	ឥណពន្ធ	ឥណទាយី
		7335	ចំណូលពីការប្រើប្រាស់សេវាបម្រើ ដោយម្ចាស់កសិដ្ឋាន	ឥណទាន	ឥណពន្ធ	ឥណទាយី
74	**ផលពីការផាកពិន័យ និងការដាក់ទណ្ឌកម្ម**					
	741		ផលពីការផាកពិន័យ និង ការដាក់ទណ្ឌកម្ម	ឥណទាន	ឥណពន្ធ	ឥណទាយី
75	**ការឧបត្ថម្ភ អំណោយ**					
	751		ឧបត្ថម្ភកធនផ្តល់ដោយរដ្ឋ (ក្រៅប្រទេស) ប្រទេស...	ឥណទាន	ឥណពន្ធ	ឥណទាយី
	752		ឧបត្ថម្ភកធនផ្តល់ដោយអង្គការអន្តរជាតិ	ឥណទាន	ឥណពន្ធ	ឥណទាយី
	753		ជំនួយ ផ្សេង ៗ ទៀត	ឥណទាន	ឥណពន្ធ	ឥណទាយី
76	**ផលហិរញ្ញវត្ថុ**					
	761		ការប្រាក់នៃការអោយខ្ចី	ឥណទាន	ឥណពន្ធ	ឥណទាយី
	766		ចំណេញពីការប្តូរប្រាក់	ឥណទាន	ឥណពន្ធ	ឥណទាយី
	768		ផលហិរញ្ញវត្ថុផ្សេង ៗ	ឥណទាន	ឥណពន្ធ	ឥណទាយី
77	**ផលផ្សេងៗ និង ផលពិសេស**					
	771		ផលផ្សេងៗ និងកិច្ចប្រតិបត្តិការគ្រប់គ្រង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7711	ចំណូលពីការបង់អតិរេកពីថវិកាខេត្ត-ក្រុង	ឥណទាន	ឥណពន្ធ	ឥណទាយី
		7712	កំរៃតនាគារ	ឥណទាន	ឥណពន្ធ	ឥណទាយី
	772		ផលនៃឯកជនភាវូបនីយកម្មសហគ្រាសសាធារណៈ	ឥណទាន	ឥណពន្ធ	ឥណទាយី
	775		ផលពីការលក់អចលកម្ម (ការលក់ទ្រព្យសម្បត្តិរដ្ឋ)	ឥណទាន	ឥណពន្ធ	ឥណទាយី

	777		ចំណែកនៃឧបត្ថម្ភកធន វិនិយោគផ្ទេរទៅគណនីលទ្ធផល	ឥណទាន	ឥណពន្ធ	ឥណទាយី
78	**ការងារនៃរង្វង់យៀ**					
	781		នៅរតនាគារជាតិ	ឥណទាន	ឥណពន្ធ	ឥណទាយី
	782		នៅរតនាគារខេត្ត-ក្រុង	ឥណទាន	ឥណពន្ធ	ឥណទាយី

ឧបសម្ព័ន្ធ ២

ប្រព្រឹត្តិកម្មរបស់គណនី នៃ គណនេយ្យរដ្ឋ

****

១_គណនី ទាយជ្ជទាន " លេខ ១០១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ជាប្រភពធនធាននៃតំលៃអចលកម្មរូបី អរូបីរបស់រដ្ឋដែលមាននៅតាម ក្រសួង មន្ទីរ ស្ថាប័ននានា និងបំណុលត្រូវសង ត្រូវទារ ដែលកន្លងមកពុំទាន់បានកត់ត្រាទៅក្នុងលេខានាគណនេយ្យ ។ តំលៃនៃទ្រព្យសម្បត្តិ និងបំណុលទាំងនេះ គឺបានមកពីការវាយតំលៃនៅលើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងតារាងស្ថានភាពបំណុលរបស់អង្គភាពដែលមានការពាក់ព័ន្ធ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលបានធ្វើសមាហរ័ណកម្ម

ឥណទាន : កត់ត្រាតំលៃអចលកម្មប្រាក់អោយខ្ចីដែលបាន ចាត់ទុកជាធនធានរបស់រដ្ឋ

សមតុល្យ : ឥណទាយី បង្ហាញតំលៃអចលកមប្រាក់អោយខ្ចីមានពីមុនមកដែលជាធនធានរបស់រដ្ឋ ។

ចំណាំ : តំលៃនៃអចលកម្មប្រាក់ខ្ចី និង ប្រាក់អោយខ្ចី ដែលកើតមានក្រោយពីបញ្ជីសារពើភ័ណ្ឌគឺត្រូវកត់ត្រាតាមចំនួនទឹកប្រាក់ដែលបានទូទាត់ពេលទិញ ឬ សាងសង់ បានខ្ចី អោយខ្ចី ទៅក្នុងគណនីអចលកម្ម គណនីបំណុល និងគណនីឥណទេយ្យដែលពាក់ព័ន្ធ ដោយពុំមានការពាក់ព័ន្ធនឹងគណនីនេះទេ ។

២_គណនី ធនធានអចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់ " លេខ ១០២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវចំនួនទឹកប្រាក់ជាប្រភពធនធាននៃអចលកម្មដែលពុំមែនជាកម្មសិទ្ធរបស់រដ្ឋ តែបានទទួលមកធ្វើការគ្រប់គ្រងប្រើប្រាស់ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានទទួលមកគ្រប់គ្រងប្រើប្រាស់ហើយបានផ្ទេរចេញវិញ

ឥណទាន : កត់ត្រាតំលៃអចលកម្ម ដែលបានទទួលមកគ្រប់គ្រងប្រើប្រាស់

សមតុល្យ : ឥណទាយី បង្ហាញប្រភពធនធាននៃតំលៃអចលកម្មដែលបានទទួលមកគ្រប់គ្រង ប្រើប្រាស់ ។

៣_គណនី ធនធានដែលបានពីអំណោយ និង កេរ្តិ៍មរតក " លេខ ១០៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់

ជាប្រភពធនធាននៃអចលកម្ម ដែលបានមកពីអំណោយឬកេរ្តិ៍មរតករបស់អ្នកដែលបានទទួលមរណៈភាពផ្តល់ជូនជាកម្មសិទ្ធិរបស់រដ្ឋ ។

ការកត់ត្រា :

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាតំលៃទ្រព្យសម្បត្តិ ឬ សាច់ប្រាក់ដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ នៃតំលៃអចលកម្ម ឬសាច់ប្រាក់ដែលរដ្ឋបានទទួល និងចាត់ទុកជាធនធានរបស់រដ្ឋ ។

៤-គណនី អតិរេកផ្នែកចរន្ត-ធនបំរុង " លេខ ១០៦ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់នៃអតិរេកថវិកាផ្នែកចរន្តដែលបានផ្ទេរមកទុកជាធនបំរុង និងរង់ចាំការសំរេចដើម្បីធ្វើនិយ័ត្តភាពទៅក្នុងថវិកាឆ្នាំបន្ទាប់ ។

ការកត់ត្រា :

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់អតិរេកដែលបានផ្ទេរមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃ ធនបំរុងពុំទាន់បានចាត់ចែង ។

៥-គណនី យោងជាថ្មី ឥណទាយី (អតិរេក) " លេខ ១១០ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានផ្ទេរពីគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃ លទ្ធផល ឱនភាពដែលបានផ្ទេរមក

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃ លទ្ធផល អតិរេកដែលបានផ្ទេរមក

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃ លទ្ធផល អតិរេកបូកបន្ត ។

<u>ចំណាំ</u> : ការជំរះផ្ទេរលទ្ធផលពីគណនីលទ្ធផលនៃការិយបរិច្ឆេទមកគណនីយោងជាថ្មីគឺនៅក្នុងឆ្នាំបន្ទាប់ ។

៦-គណនី យោងជាថ្មី ឥណពន្ធ (ឱនភាព) " លេខ ១១៩ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីគណនីលទ្ធផលនៃការិយបរិច្ឆេទ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃ លទ្ធផល ឱនភាពដែលបានផ្ទេរមក

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃ លទ្ធផល អតិរេកដែលបានផ្ទេរមក

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់នៃ លទ្ធផល ឱនភាពបូកបន្ត ។

ចំណាំ : ការជំរះផ្ទេរលទ្ធផលពីគណនីលទ្ធផលនៃការិយបរិច្ឆេទមកគណនីយោងជាថ្មីគឺនៅក្នុងឆ្នាំបន្ទាប់ ។

៧_គណនី លទ្ធផលនៃការិយបរិច្ឆេទ " លេខ ១២១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាការគណនារក លទ្ធផលនៃការិយបរិច្ឆេទ ដោយផ្ទេរសមតុល្យចុងឆ្នាំនៃគណនីចំណូល និងគណនីចំណាយថវិកាចរន្ត ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាផ្ទេរសមតុល្យឥណាយិកនៃគណនី ចំណាយថវិកាចរន្ត

- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី យោងជាថ្មី ឥណទាយី ឬ គណនី យោងជាថ្មី ឥណាយិក
- កត់ត្រាផ្ទេរលទ្ធផលអតិរេកចូលគណនី ធនបំរុង
- កត់ត្រាផ្ទេរលទ្ធផលអតិរេករបស់រតនាគារ ខេត្ត-ក្រុង ទៅរតនាគារកណ្តាល
- កត់ត្រាផ្ទេរលទ្ធផលឱនភាពពីរតនាគារខេត្ត-ក្រុងមករតនាគារកណ្តាល

ឥណទាន : - កត់ត្រាផ្ទេរសមតុល្យឥណទាយីនៃគណនី ចំណូលថវិកាចរន្ត

- កត់ត្រាផ្ទេរលទ្ធផលឱនភាពចូលគណនីយោងជាថ្មី ឥណាយិក ឬយោងជាថ្មី ឥណទាយី
- កត់ត្រាផ្ទេរលទ្ធផលឱនភាពរបស់រតនាគារខេត្ត-ក្រុងទៅរតនាគារកណ្តាល
- កត់ត្រាផ្ទេរលទ្ធផលអតិរេកពីរតនាគារខេត្ត-ក្រុងមករតនាគារកណ្តាល

សមតុល្យ :- ឥណទាយី បង្ហាញលទ្ធផល អតិរេក នៃការអនុវត្តន៏ថវិកាចរន្តដែលពុំទាន់បានចាត់ចែង

- ឥណាយិក បង្ហាញលទ្ធផល ឱនភាពនៃការអនុវត្តន៏ថវិកាចរន្ត ដែលពុំទាន់បានចាត់ចែង ។

ចំណាំ : គណនីនេះត្រូវអសមតុល្យនៅក្រោយពេលចាត់ចែងលទ្ធផលប្រចាំឆ្នាំនៅឆ្នាំបន្ទាប់ ។

៨_គណនី ឧបត្ថម្ភកធនឧពលសំភារៈ បរិក្ខារឥទ្ធភាពី " លេខ ១៣១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុងប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានមកពីការផ្តល់ឧបត្ថម្ភកធនជាទព្វសំភារៈ ឬជាសាច់ប្រាក់ពីប្រទេសនានាសំរាប់ទិញ សាងសង់ទ្រព្យសំភារៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះឧបត្ថម្ភកធនជាទព្វសំភារៈបានទទួល ជាមួយនឹង ចំណែកនៃ ឧបត្ថម្ភកធនទព្វសំភារៈ ដែលបានផ្ទេរចូលគណនីលទ្ធផលនៃការិយបរិច្ឆេទ

ឥណទាន : កត់ត្រាតំលៃទព្វសំភារៈ ឬសាច់ប្រាក់ ដែលបានមកពីការផ្តល់ដោយប្រទេសនានា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃ ឧបត្ថម្ភកធនជាទព្វសំភារៈដែលបានទទួលនិង ពុំទាន់ជំរះ ។

__ចំណាំ__ : - គណនីលេខ ១៣១ ត្រូវចែកជាអនុគណនីទៅតាមប្រទេសដែលបានផ្តល់ការឧបត្ថម្ភកធនមាន ជប៉ុន បារាំង អាឡឺម៉ង់ និងសំរាប់ប្រទេសផ្សេងៗ ទៀត ។

- ការជំរះផ្នែកខាងឥណពន្ធនៃគណនីលេខ ១៣១ នៅពេលដែលចំនួន ទឹកប្រាក់សរុបខាងផ្នែកឥណពន្ធ នៃគណនីលេខ ១៣៩ នឹងចំនួនទឹកប្រាក់សរុបខាងផ្នែកឥណទាន នៃគណនីលេខ ១៣១ នេះតាមប្រភេទ ឧបត្ថម្ភកធននីមួយៗ ។

- ការជំរះ គណនីលេខ ១៣១ និង គណនីលេខ ១៣៩ គឺជាប្រតិបត្តិការដីកា ។

៩_គណនី ឧបត្ថម្ភកធនទព្វសំភារៈ បរិក្ខារពីអង្គការអន្តរជាតិ " លេខ ១៣២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ដែលបានមកពីការផ្តល់ឧបត្ថម្ភកធនជាទព្វសំភារៈ ឬជាសាច់ប្រាក់ពីអង្គការអន្តរជាតិនានាសំរាប់ទិញទ្រព្យ សំភារៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះនូវឧបត្ថម្ភកធនជាទព្វសំភារៈបានទទួលជាមួយនឹងចំណែកនៃ ឧបត្ថម្ភកធនទព្វសំភារៈ ដែលបានផ្ទេរចូលគណនីលទ្ធផល

ឥណទាន : កត់ត្រាតំលៃទព្វសំភារៈ ឬជាសាច់ប្រាក់ ដែលបានមកពីការផ្តល់ដោយអន្តរជាតិ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃ ឧបត្ថម្ភកធនជាទព្វសំភារៈដែលបានទទួលនិង ពុំទាន់ជំរះ ។

__ចំណាំ__ : - គណនីលេខ ១៣២ ត្រូវចែកជាអនុគណនីទៅតាមអង្គការដែលផ្តល់ឧបត្ថម្ភកធនមាន : ធនាគារ ពិភពលោកធនាគារអភិវឌ្ឍន៍អាស៊ី អង្គការអាយហ្វាត អង្គការអូប៉ិច និងសំរាប់អង្គការផ្សេងៗ ទៀត ។

- ការជំរះផ្នែកខាងឥណពន្ធនៃគណនីនេះនៅពេលដែលចំនួនទឹកប្រាក់សរុប ខាងផ្នែកឥណទាននេះស្មើ នឹងចំនួនទឹកប្រាក់សរុបខាងផ្នែកឥណពន្ធ នៃគណនី លេខ ១៣៩ តាមប្រភេទឧបត្ថម្ភកធននីមួយៗ ។

- លេខនានៃការជំរះសមតុល្យគណនី លេខ ១៣២ និងគណនីលេខ ១៣៩ គឺជាប្រតិបត្តិការដីកា ។

១០-គណនី ឧបត្ថម្ភកធនសំរាប់ការរំលស់បំណុល " លេខ ១៣៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភកធនដែលបានទទួលជាប្រាក់សំរាប់សងបំណុល ឬបានទទួលឧបត្ថម្ភកធន ហើយកាត់កងត្រង់ជាមួយបំណុល ។

ការកត់ត្រា :

ឥណពន្ធ : ពុំមានប្រតិបត្តិការ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ ឧបត្ថម្ភកធនដែលបានទទួលជាប្រាក់ សំរាប់សងបំណុលប្រាក់ដើមខ្ចី

- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភកធនដែលបានទទួលដោយផ្ទេរត្រង់ទៅកាត់កងជាមួយបំណុលប្រាក់ដើមខ្ចី

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ឧបត្ថម្ភកធនសំរាប់រំលស់បំណុលដែលបានទទួលបូកបន្ត ។

<u>**ចំណាំ**</u> : - គណនីលេខ ១៣៣ ត្រូវចែកជាអនុគណនីទៅតាមប្រទេស ឬអង្គការអន្តរជាតិ ដែលបានផ្តល់ប្រាក់ឧបត្ថម្ភ ។

- ឧបត្ថម្ភកធនដែលបានទទួលជាប្រាក់សំរាប់សងបំណុលការប្រាក់ ត្រូវចាត់ទុកជាចំណូលថវិកាចរន្ត (គណនីលេខ ៧៥១ ឬ ៧៥២....) ។

១១-គណនី ឧបត្ថម្ភកធនវិនិយោគផ្ទេរទៅគណនីលទ្ធផល " លេខ ១៣៩ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទនីមួយៗ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធនវិនិយោគបានផ្ទេរទៅគណនីលទ្ធផល (តាមចំនួនទឹកប្រាក់ដែលបានធ្វើទាយជ្ជទានរំលស់)

- កត់ត្រាចំនួនទឹកប្រាក់នៃចំណែកឧបត្ថម្ភកធន វិនិយោគដែលបានកត់ត្រា បន្ថែមចូលគណនីលទ្ធផលចរន្ត

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បូកបន្តនៃចំណែកឧបត្ថម្ភកធនវិនិយោគបានផ្ទេរចូលគណនី លទ្ធផល នៃការិយបរិច្ឆេទ ដែលបានជំរះជាមួយគណនី ឧបត្ថម្ភកធន វិនិយោគដែលបានទទួល

- កត់ត្រាតំលៃគណនេយ្យនៃ ចំណែកសកម្មបានពីឧបត្ថម្ភកធនវិនិយោគដែលបានជំរះមុនកាលកំណត់ប្រើប្រាស់

សមតុល្យ : ឥណាយិកបង្ហាញចំនួនទឹកប្រាក់បូកបន្តនៃឧបត្ថម្ភកធនវិនិយោគដែលបានផ្ទេរចូលគណនីលទ្ធផល នៃ ការិយបរិច្ឆេទ ។

ចំណាំ : គណនីលេខ ១៣៩ ត្រូវចែកជាអនុគណនីទៅតាមប្រភពដែលផ្តល់ឧបត្ថម្ភកធន ។ ការកត់ត្រាទៅក្នុងគណនីនេះយោង តាមការគិតរំលស់ ។

១២_គណនី ការខ្ចីក្នុងប្រទេស " លេខ ១៦១ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលក្រសួង ស្ថាប័នក្នុងនាមរាជរដ្ឋាភិបាល បានទទួលពីធនាគារ ឬស្ថាប័នឥណទានក្នុងប្រទេស ។ គណនីការខ្ចីកត់ត្រាតែប្រាក់ដើមខ្ចីនិងបានសង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើម នៃប្រាក់ខ្ចីដែលបានសង ឬបានកាត់បន្ថយតាមកិច្ចព្រមព្រៀង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខ្ចីដែលពុំទាន់បានសងទៅភាគីជាអ្នកអោយខ្ចី ។

ចំណាំ : គណនីលេខ ១៦១ ត្រូវចែកទៅជាអនុគណនី សំរាប់ប្រាក់ខ្ចីពីធនាគារជាតិនៃកម្ពុជា ធនាគារពាណិជ្ជ និងសំរាប់ប្រាក់ខ្ចីពីស្ថាប័ន អង្គការជាតិផ្សេងទៀត ។

១៣_គណនី ការខ្ចីក្រៅប្រទេស " លេខ ១៦២ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ខ្ចីដែលក្រសួង ស្ថាប័នក្នុងនាមរាជរដ្ឋាភិបាល បានទទួលពីធនាគារក្រៅប្រទេស និង ពីអង្គការអន្តរជាតិ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានសង ឬបានបន្ថយតាមកិច្ចព្រមព្រៀង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមនៃប្រាក់ខ្ចីដែលបានទទួល

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ខ្ចីដែលពុំទាន់បានសងទៅភាគីជាអ្នកអោយខ្ចី ។

ចំណាំ : គណនីលេខ ១៦២ ត្រូវចែកទៅជាអនុគណនី សំរាប់ការខ្ចីពហុភាគី ទ្វេភាគី និងសំរាប់ការខ្ចីក្រៅប្រទេសផ្សេងទៀតៗ ។

១៤_គណនី ប្រាក់តំកល់ធានាបានទទួល " លេខ ១៦៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់

ដែលបានទទួលពីការដកលុយធានាលើសកម្មភាពអាជីវកម្ម របស់អាជីវករ ក្រុមហ៊ុន ដោយបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរចូលគណនីចរន្តរបស់ធនាគារនៅធនាគារ ជាប្រាក់រៀល ឬ ជាប្រាក់ដុល្លារអាមេរិក ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានសងទៅអាជីវករ ឬ ក្រុមហ៊ុនវិញ

- កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានផ្ទេរទៅជាចំណូលថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ធានាដែលបានទទួលពី អាជីវករ ឬ ក្រុមហ៊ុន

សមតុល្យ :ឥណទាយី បង្ហាញចំនួនទឹកប្រាក់តំកល់ធានាសកម្មភាពអាជីវកម្ម ដែលពុំទាន់បានសងទៅអាជីវករ ឬ ក្រុមហ៊ុន ។

<u>**ចំណាំ**</u> : គណនីលេខ ១៦៣ ត្រូវចែកទៅជាអនុគណនី សំរាប់ធនាគារកណ្តាល (ជាប្រាក់រៀល ជាប្រាក់ដុល្លារអាមេរិក) ធនាគារខេត្ត-ក្រុង ហើយលំអិត ទៅតាមប្រភពដែលបានបង់ប្រាក់ ។

១៥_គណនី អ្នកចុះឈ្មោះប័ណ្ណធនាគារ(បរិវិសករ ប័ណ្ណធនាគារ) " លេខ ១៦៥ " :

គណនីនេះបើកនៅធនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការបោះផ្សាយបណ្ណ័ធនាគារ និងបានសងប្រាក់ទៅបរិវិសករ បណ្ណ័ធនាគារវិញតាមកាលវសាន្ត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅ បរិវិសករ បណ្ណ័ធនាគារតាមតំលៃចារឹកក្រោមរូបភាពបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅបរិវិសករ បណ្ណ័ធនាគារ (ចំនួនទឹកប្រាក់ដែលបានទទួលជាក់ស្តែងដែលស្មើនឹងតំលៃចារឹកនាម ដក ប្រាក់កំរៃដែលបានសងមុន)

- កត់ត្រាចំនួនទឹកប្រាក់កំរៃដែលបានសងមុនទៅបរិវិសករបណ្ណ័ធនាគារហើយរង់ចាំអាណត្តិបើកប្រាក់ដើម្បីធ្វើនិយ័ត្តកម្ម

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលពុំទាន់បានសងទៅបរិវិសករ បណ្ណ័ធនាគារ ។

<u>**ចំណាំ**</u> : គណនីលេខ ១៦៥ ត្រូវចែកចេញជាអនុគណនី សំរាប់ប័ណ្ណធនាគារជាសន្លឹកប័ណ្ណ និង សំរាប់ប័ណ្ណធនាគារលើគណនីចរន្ត ។

១៦_គណនី សញ្ញាប័ណ្ណ " លេខ ១៦៦ " :

គណនីនេះបើកនៅធនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួលពីការ

បោះផ្សាយសញ្ញាបណ្ណ័ និងចំនួនទឹកប្រាក់បានចំណាយសងប្រាក់ដើមទៅអ្នកជាវវិញតាមកាលវសាន្ត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅអ្នកជាវសញ្ញាប័ណ្ណ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលពីការបោះផ្សាយសញ្ញាប័ណ្ណ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅអ្នកជាវសញ្ញាប័ណ្ណ ។

ចំណាំ : គណនីលេខ ១៦៦ ត្រូវចែកជាអនុគណនីសំរាប់តាមដានអ្នកជាវសញ្ញាប័ណ្ណនីមួយ ៗ ។

១៧. គណនី ការប្រាក់ខ្ចីបានគិតទុកមុនពុំទាន់បានបង់ " លេខ ១៦៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនការប្រាក់ខ្ចីដែលបានគណនាទុកមុន ដោយបានចាត់ជាចំណាយថវិកា តែពុំទាន់បានទូទាត់សងនៅចុងការិយបរិច្ឆេទ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនការប្រាក់គិតទុកមុនដែលបានសង ឬ បានបន្ថយ

ឥណទាន : កត់ត្រាចំនួនការប្រាក់គិតទុកមុនដែលត្រូវសង

សមតុល្យ : ឥណទាយី បង្ហាញចំនួនការប្រាក់ដែលបានគិតទុកមុន និងត្រូវសងនៅចុងការិយបរិច្ឆេទ ។

១៨. គណនី សោហ៊ុយសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ " លេខ ២០៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារ ខេត្ត- ក្រុង ប្រើសំរាប់កត់ត្រាចំណាយលើ ការសិក្សា ស្រាវជ្រាវ និង អភិវឌ្ឍន៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ចំណាយសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍ ដែលបានផ្ទេរទៅគណនីអចលកម្ម ពាក់ព័ន្ធ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយសិក្សាស្រាវជ្រាវ និងអភិវឌ្ឍន៍ដែលបានជំរះជាមួយគណនីរំលស់ អចលកម្ម

- សមតុល្យ : ឥណទាយិក បង្ហាញតំលៃនៃការសិក្សាស្រាវជ្រាវ និង អភិវឌ្ឍន៍កំពុងធ្វើ ។

ចំណាំ : គណនីលេខ ២០៣ ត្រូវចែកទៅជាអនុគណនីសំរាប់សោហ៊ុយសិក្សា និង សំរាប់សោហ៊ុយស្រាវជ្រាវ និង អភិវឌ្ឍន៍ការជំរះនៅពេលដែលទទួលបានការបញ្ជាក់ទទួលស្គាល់លើការអនុវត្តនំកិច្ចសន្យា ឬការពិសោធន៍

ស្រាវជ្រាវបានចប់ ។

១៩-គណនី ប្រកាសនីយបត្រ អាជ្ញាប័ណ្ណ និង សិទ្ធិប្រហាក់ប្រហែល " លេខ ២០៥ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីបង្កើត ឬទិញនូវប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានទិញ និងបង្កើតប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានជំរះតំលៃប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែល ជាមួយគណនីរំលស់ និង គណនីតំលៃគណនេយ្យនៃចំណែកសកម្មដែលបានលក់ ឬ ជំរះ ។

សមតុល្យ: ឥណាយិក បង្ហាញតំលៃប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សិទ្ធិប្រហាក់ប្រហែលកំពុងមាន ។

ចំណាំ : គណនីលេខ ២០៥ អាចចែកជាអនុគណនីសំរាប់ ប្រកាសនីយបត្រ អាជ្ញាបណ្ណ និង សំរាប់សិទ្ធិប្រហាក់ប្រហែល ។

២០-គណនី ដីធ្លី និង ធនធានធម្មជាតិ " លេខ ២១១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃដីធ្លី និងធនធានធម្មជាតិដែលបានទិញ បានពីអំណោយ និងបានពីរូបភាពផ្សេងទៀតហើយបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ

ឥណទាន : កត់ត្រាតំលៃដីធ្លី និងធនធានធម្មជាតិដែលបានបន្ថយដោយលក់ អំណោយ ឬ ផ្ទេរ

សមតុល្យ: ឥណាយិក បង្ហាញតំលៃដីធ្លី និងធនធានធម្មជាតិដែលកំពុងមាន ។

ចំណាំ : - តំលៃដីធ្លី និងធនធានធម្មជាតិត្រូវចែកជាអនុគណនីសំរាប់ ដីធ្លី និងសំរាប់ធនធានធម្មជាតិផ្សេងៗ

- គណនីដីធ្លីពុំមានការគិតរំលស់ឡើយ ។

២១-គណនី ការរៀបចំកែលំអដីធ្លី ដីរ៉ែ និង សម្បត្តិធម្មជាតិផ្សេងៗ " លេខ ២១២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិផ្សេងៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយលើការកែលំអដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិ

ឥណទាន : កត់ត្រា ចំនួនទឹកប្រាក់ដែលបានជំរះជាមួយ នឹងប្រាក់រំលស់ចូលបន្ត .

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បានចំណាយលើការកែលំអដីធ្លី ដីរ៉ែ និងសម្បត្តិធម្មជាតិពុំទាន់បានជំរះ ។

២២_គណនី សំណង់ " លេខ ២១៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃសំណង់អាគារដែលបានទិញ សាងសង់ បានពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃសំណង់ អាគារ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ

ឥណទាន : កត់ត្រាតំលៃសំណង់ អាគារដែលបានបន្ថយដោយលក់ ធ្វើអំណោយ ផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃសំណង់ អាគារដែលកំពុងមាន ។

<u>**ចំណាំ :**</u> គណនីលេខ ២១៣ត្រូវចែកទៅជាអនុគណនី សំរាប់អាគារ ការរៀបចំកែលំអអាគារ និងសំរាប់សំណង់ផ្សេងៗ ។

២៣_គណនី ហេដ្ឋារចនាសម្ព័ន្ធ " លេខ ២១៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃហេដ្ឋារចនាសម្ព័ន្ធដែលបានទិញ សាងសង់ ឬបានពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃ ហេដ្ឋារចនាសម្ព័ន្ធ ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ

ឥណទាន :កត់ត្រាតំលៃ ហេដ្ឋារចនាសម្ព័ន្ធ ដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃ ហេដ្ឋារចនាសម្ព័ន្ធដែលកំពុងមាន ។

<u>**ចំណាំ :**</u> គណនីលេខ ២១៤ ត្រូវចែកទៅជាអនុគណនី សំរាប់ផ្លូវថ្នល់ ធារាសាស្ត្រ អាយស្ម័យាន អាកាសយានដ្ឋានទូរគមនាគមន៍ បណ្តាញអគ្គីសនី និងសំរាប់បណ្តាញផ្សេងៗ ។

២៤_គណនី ឋាបនកម្មបច្ចេកទេស សំភារៈ និងបរិក្ខារ " លេខ ២១៥ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃឋាបនកម្មបច្ចេកទេស សំភារៈ បរិក្ខារ ដែលបានពីការទិញ ពីអំណោយ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃឋាបនកម្មបច្ចេកទេស សំភារៈ ហត្ថូបករណ៍ដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ

ឥណទាន : កត់ត្រាតំលៃឋាបនកម្មបច្ចេកទេស សំភារៈហត្ថូបករណ៍ដែលបានបន្ថយដោយលក់ ធ្វើអំណោយ ជំរះ ឬផ្ទេរ

សមតុល្យ : ឥណាយិក បង្ហាញតំលៃឋាបនកម្មបច្ចេកទេស សំភារៈ ហត្ថូបករណ៍ដែលកំពុងមាន ។

<u>ចំណាំ</u> : គណនីលេខ ២១៥ ត្រូវចែកទៅជាអនុគណនីសំរាប់ឋាបនកម្មបច្ចេកទេស សំភារៈ និងសំរាប់គ្រឿងឧបករណ៍(ហត្ថូបករណ៍) ។

២៥.គណនី ស្នាដៃសិល្បៈ និង ការប្រមូល (សន្សំ) " លេខ ២១៦ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃទ្រព្យសម្បត្តិ ដូចជា ស្នាដៃ ផ្ទាំងគំនូរ រូបបដិមាករ ចម្លាក់ វត្ថុបូរាណ សៀវភៅបូរាណ ...។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃ អចលកម្មដែលបានបញ្ចូលជាទ្រព្យសម្បត្តិរដ្ឋ

ឥណទាន : កត់ត្រាតំលៃ អចលកម្មដែលបានបញ្ចេញ , ជំរះ

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្ម ជា ស្នាដៃ ផ្ទាំងគំនូរ រូបបដិមាករចម្លាក់ វត្ថុបូរាណ សៀវភៅបូរាណកំពុងមាន ។

២៦.គណនី អចលកម្មដែលបានទទួលគ្រប់គ្រង ប្រើប្រាស់ " លេខ ២១៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្មដែលបានគ្រប់គ្រង និងប្រើប្រាស់តែពុំមែនជាកម្មសិទ្ធរបស់រដ្ឋ ទេ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃ អចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង និងប្រើប្រាស់

ឥណទាន : កត់ត្រាតំលៃ អចលកម្មដែលបានជំរះចេញពីការគ្រប់គ្រង និងប្រើប្រាស់

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មដែលបានទទួលមកធ្វើការគ្រប់គ្រង និងប្រើប្រាស់ ។

<u>ចំណាំ</u> : គណនីលេខ ២១៧ ត្រូវចែកទៅជាអនុគណនីសំរាប់ដីធ្លី ការរៀបចំកែលំអដីធ្លី អាគារ ឋាបនកម្មបច្ចេកទេស សំភារៈហត្ថូបករណ៍ និង សំរាប់អចលកម្មផ្សេងទៀត ។

២៧_គណនី អចលកម្មរូបីផ្សេងៗ " លេខ ២១៨ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃ អចលកម្មរូបីផ្សេង ទៀត ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មរូបីដែលបានបញ្ចូលជាទ្រព្យសម្បត្តិរបស់រដ្ឋ

ឥណទាន : កត់ត្រាតំលៃ អចលកម្មរូបីដែលបានបន្ថយដោយលក់ អំណោយ ផ្ទេរ ឬ ជំរះ

សមតុល្យ : ឥណទេយិក បង្ហាញតំលៃអចលកម្មរូបីផ្សេងទៀតដែលកំពុងមាន ។

<u>**ចំណាំ**</u> : គណនីលេខ ២១៨ ត្រូវចែកទៅតាមប្រភេទសំរាប់សំភារៈឧបករណ៍ដឹកជញ្ជូន សំភារៈឧបករណ៍ ការិយាល័យ និង សំភារៈពត៌មាន និងទូរគមនាគមន៍ សម្ភារីម និងសំរាប់អចលកម្មរូបីផ្សេងៗ ទៀត ។

២៨_គណនី អចលកម្មរូបីកំពុងដំណើរការ (ឆ្លងកាត់រតនាគារ) " លេខ ២៣១ " :

គណនីបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ នៃ ចំណែកអចលកម្មរូបីកំពុងដំណើរផលិត សាងសង់ ពុំទាន់បានសំរេចជាស្ថាពរ ។

ការកត់ត្រា :

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយទូទាត់ជូនអ្នកម៉ៅការលើការផលិត សាងសង់អចលកម្ម តែពុំទាន់រួចរាល់នៅចុងការិយបរិច្ឆេទនីមួយៗ ។

- កត់ត្រាចំនួនទឹកប្រាក់បានចំណាយក្នុងការទិញសំភារៈ ឬសេវាក្នុងការផលិតអចលកម្ម

ឥណទាន : កត់ត្រាតំលៃអចលកម្មរូបីដែលបានផលិត សាងសង់រួច ហើយផ្ទេរទៅគណនីអចលកម្មពាក់ព័ន្ធ

សមតុល្យ : ឥណទេយិក បង្ហាញតំលៃអចលកម្មរូបីដែលកំពុងផលិតពុំទាន់បានរួចរាល់នៅចុងការិយបរិច្ឆេទ ។

២៩_គណនី អចលកម្មអរូបីកំពុងដំណើរ " លេខ ២៣២ " :

គណនីបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាតំលៃអចលកម្ម អរូបីកំពុងដំណើរការផលិត ឬ សាងសង់ដែលពុំទាន់បានសំរេចជាស្ថាពរ ។

ការកត់ត្រា :

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយទូទាត់ជូនអ្នកម៉ៅការលើការផលិត ឬសាងសង់អចលកម្ម តែពុំទាន់រួចរាល់នៅចុងការិយបរិច្ឆេទនីមួយៗ ។

- កត់ត្រាចំនួនទឹកប្រាក់បានចំណាយក្នុងការទិញសំភារៈ ឬសេវាក្នុងការសាងសង់ ផលិតអចលកម្ម

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានផលិត ឬ សាងសង់រួចហើយ ផ្ទេរទៅគណនីអចលកម្មពាក់ព័ន្ធ

សមតុល្យ : ឥណពន្ធ បង្ហាញតំលៃអចលកម្មដែលកំពុងផលិត ឬសាងសង់ ពុំទាន់បានរួចរាល់នៅចុងការិយបរិច្ឆេទ

ចំណាំ : គណនីលេខ ២៣២ ត្រូវចែកទៅអនុគណនីសំរាប់សំរាប់ការរៀបចំ និងកែលំអដីធ្លី អាគារហេដ្ឋារចនាសម្ព័ន្ធ និងសំរាប់ឋបនកម្មបច្ចេកទេស ។

៣០_គណនី អចលកម្មរូបីកំពុងដំណើរការ (ក្រៅរតនាគារ) " លេខ ២៣៣ " :

គណនីបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយនៅក្រៅរតនាគារលើចំណែកអចលកម្មរូបីកំពុងដំណើរផលិត សាងសង់ ពុំទាន់បានសំរេចជាស្ថាពរ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយទូទាត់ជូនអ្នកម៉ៅការ ឬអ្នកទទួលការសាងសង់ ការផលិតអចលកម្ម តែពុំទាន់បានរួចរាល់នៅចុងការិយបរិច្ឆេទ ។

ឥណទាន : កត់ត្រាតំលៃអចលកម្មដែលបានផលិត សាងសង់រួច ហើយផ្ទេរទៅគណនីអចលកម្មពាក់ព័ន្ធ

សមតុល្យ : ឥណពន្ធ បង្ហាញតំលៃអចលកម្មដែលកំពុងសាងសង់ ផលិត ពុំទាន់បានរួចរាល់នៅចុងការិយបរិច្ឆេទ ។

៣១_គណនី ប្រាក់រំដោះលើការងារវិនិយោគ " លេខ ២៣៨ " :

គណនីបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់មុនជូនទៅអ្នកទទួលការងារវិនិយោគឯកជន ដោយយោងតាមកិច្ចសន្យា ឬ កិច្ចព្រមព្រៀង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់មុនទៅអ្នកទទួលការងារវិនិយោគ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ផ្តល់មុនដែលបានកាត់កងជាមួយទឹកប្រាក់បំណុលត្រូវសងទៅអ្នកទទួលការសាងសង់

- កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកទទួលការបានបង្វិលសងមកវិញ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនប្រាក់បានផ្តល់មុនលើការងារវិនិយោគឯកជនដែលពុំទាន់បានជំរះ ។

ចំណាំ : គណនីលេខ ២៣៨ ត្រូវចែកទៅជាអនុគណនីសំរាប់អចលកម្មរូបី និងសំរាប់អចលកម្មអរូបី ។

៣២_គណនី អចលកម្មបានធ្វើសម្បទាន ឬ ប្រទាស់" លេខ ២៥១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃអចលកម្មរដ្ឋ ដែលបានដាក់អោយសហគ្រាស ក្រុមហ៊ុនឯកជនប្រើប្រាស់ធ្វើអាជីវកម្មតែនៅជាកម្មសិទ្ធរបស់រដ្ឋ។ ការជូសជុលយោងតាមកិច្ចសន្យា ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានប្រគល់ទៅអង្គភាព សហគ្រាស ក្រុមហ៊ុន គ្រប់គ្រង

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ជំរះតំលៃអចលកម្ម ដែលបានប្រគល់ទៅអង្គភាព សហគ្រាស ក្រុមហ៊ុន គ្រប់គ្រង

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មដែល ដែលបានប្រគល់ទៅអង្គភាព សហគ្រាស ក្រុមហ៊ុន ផ្សេងៗគ្រប់គ្រង ។

៣៣_គណនី អចលកម្មដែលបានបែងចែក ឬដាក់អោយប្រើប្រាស់" លេខ ២៥២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រានូវតំលៃអចលកម្មដែលបាន បែងចែកអោយទៅអាជ្ញាធរដែនដី សមូហភាពមូលដ្ឋាន តែនៅជាកម្មសិទ្ធរបស់រដ្ឋ ។

ការកត់ត្រា:

ឥណពន្ធ : កត់ត្រាតំលៃអចលកម្មដែលបានបែងចែក ហើយបានផ្ទេរត្រលប់មកវិញ

ឥណទាន : កត់ត្រាតំលៃ អចលកម្មដែលបានបែងចែក និង ផ្ទេរការគ្រប់គ្រង

សមតុល្យ : ឥណាយិក បង្ហាញតំលៃអចលកម្មដែលបានបែងចែកទៅអាជ្ញាធរដែនដី សមូហភាពមូលដ្ឋាន បូកបន្ត ។

៣៤_គណនី មូលបំរុងនៃភាគកម្ម" លេខ ២៦១ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋាភិបាល បានចំណាយ និង បានទទួលវិញពីការចូលរួមជាភាគកម្មជាមួយសហគ្រាស ក្រុមហ៊ុន ឬ ស្ថាប័នហិរញ្ញវត្ថុ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយដើម្បីចូលរួមភាគកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលបានទទួលពីការសងវិញនូវភាគកម្មពេលបញ្ចប់ការចូលរួម ឬ ការជំរះ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានចំណាយចូលរួមជាភាគកម្មកំពុងមាន ។

ចំណាំ :- គណនីលេខ ២៦១ ត្រូវចែកចេញជាអនុគណនី ទៅតាមសហគ្រាស ស្ថាប័នដែលរដ្ឋាភិបាលបានចូលរួម ។

- ចំនួនទឹកប្រាក់ដែលកត់ត្រាលើគណនីនេះគឺទាក់ទងតែជាប្រាក់ដើមតែប៉ុណ្ណោះ ។

៣៥-គណនី ការអោយខ្ចី (ការសងទិញនូវទ្រព្យសកម្ម) " លេខ ២៧១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋបានផ្តល់ទៅស្ថាប័ន គ្រឹះស្ថានសាធារណៈ សមូហភាពមូលដ្ឋាន ក្រុមហ៊ុន អង្គការ ខ្ចីដើម្បីបំរើអោយទិសដៅវិនិយោគដោយមានការប្រាក់ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុន អង្គការ បានខ្ចី

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដើមអោយខ្ចី ដែលក្រសួង ស្ថាប័ន អង្គភាព គ្រឹះស្ថានសាធារណៈ ក្រុមហ៊ុន អង្គការ បានសងមកវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដើមអោយខ្ចីដែលពុំទាន់បានទូទាត់មកវិញ ។

ចំណាំ :- គណនីលេខ ២៧១ ត្រូវចែកចេញជាអនុគណនី ទៅតាមមុខសញ្ញាដែលបានអោយប្រាក់ខ្ចី

- ការកត់ត្រានៅក្នុងគណនី ២៧១ គឺតែចំនួនប្រាក់ដើមអោយខ្ចី និងបានសងមកវិញ ឯកំរៃការប្រាក់ដែលបានទទួលគឺត្រូវកត់ត្រាទៅក្នុងគណនីចរន្ត ចំណូលថវិកាពីការប្រាក់ ។

៣៦-គណនី ប្រាក់តំកល់ធានាបានបង់ " លេខ ២៧៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់សំរាប់តំកល់ធានា លើសកម្មភាពផ្គត់ផ្គង់ សេវាកម្ម ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់លើការតំកល់ធានា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់តំកល់ធានា ដែលបាន ទូទាត់មកវិញ

- កត់ត្រាចំនួនទឹកប្រាក់តំកល់ធានា ដែលបាន ផ្ទេរទៅគណនីផ្សេងៗ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់តំកល់ធានាបានបង់ដែលពុំទាន់បានទូទាត់មកវិញ ឬពុំទាន់បានផ្ទេរ ។

ចំណាំ : គណនីលេខ ២៧៤ ត្រូវចែកជាអនុគណនី ទៅតាមមុខសញ្ញា ដែលបានបង់ប្រាក់តំកល់ធានា ។

៣៧_គណនី ការប្រាក់គិតទុកមុនពុំទាន់បានទទួល(ប្រាក់អោយខ្ចី) " លេខ ២៧៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនការប្រាក់ដែលត្រូវទទួលពីការអោយខ្ចីប្រាក់ហើយបានគិតទុកមុននៅចុងការិយបរិច្ឆេទដោយបានចាត់ជាចំណូលថវិកា តែសាច់ប្រាក់ពុំទាន់បានទទួល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនការប្រាក់ដែលបានគិតទុកមុន និងត្រូវទទួល

ឥណទាន : កត់ត្រាចំនួនការប្រាក់បានគិតទុកមុនដែលបានទទួល

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនការប្រាក់ពីការអោយខ្ចីដែលគិតទុកមុនត្រូវទទួល ។

ចំណាំ :- គណនីលេខ ២៧៧ ត្រូវកត់ត្រានៅថ្ងៃទី ៣១ ខែ ធ្នូ នូវចំនួនការប្រាក់ដែលត្រូវទទួលពីការអោយខ្ចីដោយបដិភាគ នឹងខាងឥណទាននៃ គណនីចំណូលថវិកា (លេខ ៧៦១

- គណនីលេខ ២៧៧ ចែកជាអនុគណនី ទៅតាមប្រភពដែលត្រូវទូទាត់ការប្រាក់អោយខ្ចី ។

៣៨_គណនី រំលស់អចលកម្មអរូបី " លេខ ២៨០ " :

គណនីនេះបើកនៅរតនាគារ កណ្តាល និង នៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មអរូបី របស់ក្រសួង មន្ទីរ អង្គភាពដែលបានទិញ បានពីអំណោយ ពីឧបត្ថម្ភកធនវិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មដែលបានជំរះជាមួយតំលៃអចលកម្ម

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មក្នុងឆ្នាំដែលបានចាត់ជាចំណាយថវិកាចរន្ត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់អចលកម្មបូកបន្ត ។

ចំណាំ : - គណនីរំលស់អចលកម្មអរូបី ត្រូវចែកទៅជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី ៣ នៃគណនីអចលកម្មអរូបី បន្ថែមពីក្រោយលេខ ២៨០

- ការជំរះចំនួនទឹកប្រាក់ខាងឥណពន្ធ នៃគណនីរំលស់អចលកម្មអរូបី យោងលើការលក់ចេញ ការបោះបង់ ចោល ការបាត់បង់ និងបានផ្ទេរ ។

- ករណីដែលចំនួនទឹកប្រាក់រំលស់បូកបន្តនៃអចលកម្មស្មើនឹងតំលៃបញ្ចូលគឺត្រូវបញ្ឈប់ការធ្វើទាយជ្ជទានរំលស់ ។ ការជំរះលុះត្រាតែអចលកម្មនោះឈប់ប្រើប្រាស់ ។

៣៩_គណនី រំលស់អចលកម្មរូបី " លេខ ២៨១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់

រំលស់អចលកម្មរូបី (លើកលែងដីធ្លី) ដែលបានមកពីការទិញ ពីអំណោយ ឬពីឧបត្ថម្ភកធនវិនិយោគ ។

ការកត់ត្រា ៖

ឥណពន្ធ ៖ កត់ត្រាចំនួនទឹកប្រាក់រំលស់អចលកម្មដែលបានជំរះជាមួយតំលៃនៃអចលកម្ម

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់រំលស់ក្នុងឆ្នាំ ដោយបានចាត់ទុកជាចំណាយថវិកាចរន្ត

សមតុល្យ ៖ ឥណទាយី បង្ហាញចំនួនទឹកប្រាក់រំលស់បូកបន្ត ។

ចំណាំ ៖- គណនីរំលស់អចលនវត្ថុរូបី ត្រូវបែងចែកជាអនុគណនីទៅតាមប្រភេទនៃអចលកម្មនីមួយៗ ដោយយកលេខលំដាប់ទី ៣ នៃគណនីអចលកម្មបន្ថែមពីក្រោយលេខ ២៨១ ។

- អចលកម្មដែលបានធ្វើរំលស់ស្មើ នឹងតំលៃបញ្ចូលហើយនៅតែប្រើប្រាស់បាននោះ ត្រូវបញ្ឈប់ការធ្វើទាយជូទានរំលស់ និងពុំទាន់ជាកម្មវត្ថុនៃការជំរះឡើយ ។

- ការជំរះខាងឥណពន្ធ នៃគណនីរំលស់យោងទៅតាមការលក់ចេញ បោះបង់ចោល បាត់បង់ ឬ ផ្ទេរ ។

៤០_គណនី អ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារ "លេខ ៤០១" ៖

គណនីនេះ បើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងទៅអ្នកផ្គត់ផ្គង់ទំនិញ ផ្តល់សេវាកម្ម ការងារដោយយោងតាមអាណត្តិបើកប្រាក់ ។

ការកត់ត្រា ៖

ឥណពន្ធ ៖ - កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជូនអត្ថគាហកៈ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុក ផ្ទេរចូលថវិការដ្ឋ ឬទូទាត់ទៅមុខសញ្ញាផ្សេង

ឥណទាន ៖ កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់ទំនិញ សេវា ការងារតាមអាណត្តិបើកប្រាក់ ឬ ផ្ទេរពីគណនីផ្សេងមក

សមតុល្យ ៖ ឥណទាយី បង្ហាញចំនួនទឹកប្រាក់បំណុលដែលត្រូវសងទៅ អត្ថគាហកៈ ។

ចំណាំ ៖ - គណនីនេះពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ

- គណនីនេះត្រូវបែងចែកទៅជាអនុគណនីសំរាប់រតនាគារថ្នាក់កណ្តាល រតនាគារខេត្ត-ក្រុងជាប្រាក់ប្រាក់រៀលជាប្រាក់ដុល្លារ តាមក្រសួង មន្ទីរ ដែលបានបោះផ្សាយអាណត្តិបើកប្រាក់ ចែកជាបំណុលឆ្នាំចាស់ និង ឆ្នាំថ្មី ។

៤១_គណនី ប្រាក់ដើមខ្ចី ការប្រាក់ខ្ចី និង ទិតាគឧានុ ត្រូវសង "លេខ ៤០២" ៖

គណនីនេះ បើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវទូទាត់សងប្រាក់

ដើម និង ការប្រាក់ខ្ចី ទៅអ្នកដែលជាអ្នកអោយខ្ចីប្រាក់ និងវិភាគទានដែលត្រូវបង់ ។ ការទូទាត់ នឹងត្រូវទូទាត់ជាមូលប្បទានប័ត្រ ឬ បង្វែរ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនប្រាក់ដែលបានសងទៅអ្នកអោយខ្ចី (ប្រាក់ដើម ការប្រាក់) ឬអង្គការ សមាគម

- កត់ត្រាចំនួនទឹកប្រាក់ដែលបានបន្ថយ លុបចោលបំណុល ការប្រាក់ ឬកាតព្វកិច្ច .

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បំណុលប្រាក់ខ្ចី ការប្រាក់ ឬវិភាគទានដែលត្រូវសង

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកអោយខ្ចីប្រាក់ អង្គការ សមាគម ។

ចំណាំ : - គណនីនេះពុំមានតំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ ។

- គណនីនេះត្រូវចែកទៅជាអនុគណនីសំរាប់ប្រាក់ត្រូវសងជាប្រាក់រៀល ជាប្រាក់ដុល្លារព្រមទាំងចែកចេញជា បំណុលឆ្នាំចាស់ និង ឆ្នាំថ្មី ។

៤២-គណនី ការកាត់ទុក ការជំពាក់ " លេខ ៤០៧ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ទុកពីចំនួនទឹកប្រាក់ត្រូវសងទៅអ្នកផ្គត់ផ្គង់ទុកសំរាប់សងទៅមុខសញ្ញផ្សេងៗ យោងតាមការសំរេចរបស់តុលាការ ឬអាជ្ញាធរដែលមានសមត្ថកិច្ច ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅអ្នកទទួលផលពីការកាត់ទុកក្រោមរូបភាព ជាសាច់ប្រាក់ បង្វែរ ឬ ជាមូលប្បទានប័ត្រ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់ចេញពីចំនួនទឹកប្រាក់ដែលត្រូវទូទាត់ជូនទៅអ្នកផ្គត់ផ្គង់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលបានកាត់ទុកដែលពុំទាន់បានសងទៅអ្នកទទួលផលពី ពីការកាត់ទុក ។

ចំណាំ : - គណនីនេះពុំមានតំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ

- គណនីនេះត្រូវចែកទៅជាអនុគណនីទៅតាមអ្នកទទួលផលបានពីការកាត់ទុក ។

៤៣-គណនី អ្នកផ្គត់ផ្គង់ឥណទាយិក " លេខ ៤០៩ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់មុនទៅអ្នកផ្គត់ផ្គង់ សំភារៈសេវា ។ គណនីនេះត្រូវទូទាត់កាត់កងជាមួយនឹងគណនី អ្នកផ្គត់

ផ្តល់ នៅពេលមានអាណត្តិបើកប្រាក់ត្រូវទូទាត់ទៅអ្នកទាំងនោះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់មុន ជូនទៅអ្នកផ្គត់ផ្គង់ ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលបានកាត់កងជាមួយនឹងចំនួនទឹកប្រាក់ដែលត្រូវសងទៅអ្នកផ្គត់ផ្គង់

- កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់បានបង្វិលសងមកវិញ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ត្រូវទារ ឬត្រូវកាត់កងពីបំណុលដែលត្រូវសង ។

<u>ចំណាំ</u> : - គណនីនេះពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ គឺជាប្រភេទគណនីរង់ចាំ

- គណនីនេះត្រូវចែកទៅជាអនុគណនីទៅតាម អ្នកផ្គត់ផ្គង់ ។

៤៤. គណនី អ្នកជាប់ពន្ធ (ពន្ធគយ) " លេខ ៤១១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គល ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាទៅក្នុងគណនីនេះ គឺយោងតាមរបាយការណ៍ពីអង្គភាពគយ និងរដ្ឋាករ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយ ដែលត្រូវប្រមូល (ខាងឥណពន្ធ នៃគណនីនេះ បដិភាគនឹងខាងឥណទានបានកត់ត្រាទុកមុន (លេខ ៤៨២.១)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធគយដែលសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គលបានទូទាត់

- កត់ត្រាចំនួនទឹកប្រាក់បំណុលដែលបានបន្ថយ ឬ ជំរះ (ខាងឥណទាននៃគណនីនេះ បដិភាគនឹងខាង ឥណពន្ធនៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៨២.១)

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បំណុលពន្ធគយដែលត្រូវប្រមូល ។

<u>ចំណាំ</u> :- ការកត់ត្រាខាងឥណទាននៃគណនីនេះ គឺទន្ទឹមនឹងលេខនាកត់ត្រាចំណូលប្រាក់ពិតប្រាកដ ដែលបានកត់ត្រាខាង ឥណពន្ធ គណនី ហិរញ្ញវត្ថុ និង ខាង ឥណទាន គណនី ចំណូលថវិកា

- គណនីនេះត្រូវចែកជាអនុគណនី សំរាប់ប្រើនៅរតនាគារកណ្តាល សំរាប់រតនាគារខេត្ត-ក្រុង និងចែកជាបំណុលត្រូវប្រមូលក្នុងឆ្នាំកំពុងអនុវត្ត និង ឆ្នាំមុន

- រាល់លើកនៃការបង់ប្រាក់ អង្គភាពត្រូវធ្វើការវិភាគ និងផ្តល់ពត៌មានជល់រតនាគារដើម្បីកត់ត្រាជា

ជាចំណូលក្នុងឆ្នាំ ឬ បន្ថយបំណុលឆ្នាំមុន ។

៤៥_គណនី អ្នកជាប់ពន្ធ (ពន្ធដារ) " លេខ ៤១២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធដារ ដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គល ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាទៅក្នុងគណនីនេះគឺយោងតាមរបាយការណ៍របស់អង្គភាពពន្ធដារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធដារត្រូវប្រមូល(ខាងឥណពន្ធ នៃគណនីនេះ បដិភាគ នឹងខាងឥណទាន នៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៧២.២)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធដារដែលសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គលបានបង់
- កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធដែលបានបន្ថយ ឬ ជំរះ(ខាងឥណទាននៃគណនីនេះបដិភាគ នឹងខាង ឥណពន្ធនៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៧២.២)
- ទន្ទឹម និងលេខនាខាងឥណទានត្រូវមានលេខនាទី ២ កត់ត្រាខាងឥណពន្ធគណនីហិរញ្ញវត្ថុ និង ឥណទាននៃគណនីចំណូលថវិកាដែលពាក់ព័ន្ធ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បំណុលពន្ធដារដែលត្រូវប្រមូល ។

__ចំណាំ__ : - គណនីលេខ ៤១២ ត្រូវចែកជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល នៅរតនាគារខេត្ត ក្រុង និង ចែកជា បំណុលត្រូវប្រមូលក្នុងឆ្នាំកំពុងអនុវត្ត និង ឆ្នាំមុន

- រាល់លើកនៃការបង់ប្រាក់ អង្គភាពពន្ធដារត្រូវធ្វើការវិភាគ និងផ្តល់ព័តមានដល់រតនាគារដើម្បីកត់ត្រាជាចំណូលក្នុងឆ្នាំ ឬ បន្ថយបំណុលឆ្នាំមុន ។

៤៦_គណនី អតិថិជន (ចំណូលមិនមែនសារពើពន្ធ) " លេខ ៤១៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនពន្ធដែលត្រូវប្រមូលពីសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គល ។ ចំនួនទឹកប្រាក់ដែលត្រូវកត់ត្រាគឺយោងតាមរបាយការណ៍ពីអង្គភាពដែលមានការពាក់ព័ន្ធនឹងការគ្រប់គ្រងចំណូលនេះ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនពន្ធដែលត្រូវប្រមូល (ខាងឥណពន្ធ នៃគណនីនេះបដិភាគ នឹងខាងឥណទាន នៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៧២.៣)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលសហគ្រាស ក្រុមហ៊ុន ឬ រូបវ័ន្តបុគ្គល បានបង់

- កត់ត្រាចំនួនទឹកប្រាក់បំណុលសារពើពន្ធដែលបានបន្ថយ ឬ ជំរះ (ខាងឥណទាននៃគណនីនេះ បដិភាគ នឹងខាង ឥណពន្ធនៃគណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន (លេខ ៤៨២.៣)

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បំណុលមិនមែនសារពើពន្ធដែលត្រូវប្រមូល ។

ចំណាំ :- ការកត់ត្រាខាងឥណទាននៃគណនីនេះ គឺទន្ទឹមនឹងលេខនាកត់ត្រាចំណូលបានប្រាក់ពិតប្រាកដដែល កត់ត្រាខាងឥណពន្ធ គណនី ហិរញ្ញវត្ថុ និង ឥណទាន គណនី ចំណូលថវិកាចរន្ត

- គណនីលេខ ៤១៣ ត្រូវចែកជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល (ជាប្រាក់ដុល្លារនិងជាប្រាក់រៀល) នៅរតនាគារខេត្ត-ក្រុង និង ចែកជាបំណុលត្រូវប្រមូលក្នុងឆ្នាំកំពុងអនុវត្ត និង ឆ្នាំមុន

- រាល់លើកនៃការបង់ប្រាក់ រតនាគារត្រូវធ្វើការវិភាគ ដើម្បីកត់ត្រាជាចំណូលក្នុងឆ្នាំ ឬបន្ថយបំណុលឆ្នាំមុន ។

៤៧_គណនី ប្រាក់បៀវត្ស និង លាភការត្រូវសង " លេខ ៤២១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បៀវត្សនិង លាភការដែលត្រូវសង និងបានបើកផ្តល់តាមអាណត្តិបើកប្រាក់ ឬ លិខិតស្នើសុំមុនរបស់ក្រសួង ស្ថាប័ននៅរដ្ឋបាលកណ្តាល និង របស់មន្ទីរនានានៅខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស និងលាភការដែលបានបើកផ្តល់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់បៀវត្ស និងលាភការដែលត្រូវបើកផ្តល់ជូន ក្រសួង ស្ថាប័ន មន្ទីរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនបំណុលប្រាក់បៀវត្ស និង លាភការដែលពុំទាន់បានបើកផ្តល់ជូន ក្រសួង ស្ថាប័ន មន្ទីរ ។

ចំណាំ : គណនីលេខ ៤២១ មានតំរូហត្ថលេខារបស់ម្ចាស់គណនីជាភ្នាក់ងារបើកផ្តល់ ហើយត្រូវចែកជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារ ខេត្ត-ក្រុង និងលំអិតទៅតាម ក្រសួង ស្ថាប័ន មន្ទីរ ព្រមទាំងចែកជាឆ្នាំចាស់ និងឆ្នាំថ្មី ។

៤៨_គណនី សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗ ត្រូវសង " លេខ ៤២២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់

សោហ៊ុយបេសកកម្ម និង សោហ៊ុយផ្សេងៗដែលត្រូវសងទៅក្រសួង ស្ថាប័ន មន្ទីរនានាដោយផ្ទាល់ (ក្រៅពីអ្នកផ្គត់ផ្គង់) តាមយេះភ្ជាក់ងារបើកផ្តល់ ឬ រដ្ឋទេយ្យករបុរេប្រទាន ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបើកផ្តល់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់សោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលត្រូវបើកផ្តល់ជូន ក្រសួង ស្ថាបន័ មន្ទីរ ដោយយោងតាមអាណត្តិបើកប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនបំណុលសោហ៊ុយបេសកកម្ម និងសោហ៊ុយផ្សេងៗដែលពុំទាន់បានបើក បើកផ្តល់ជូន ក្រសួង ស្ថាប័ន មន្ទីរ ។

ចំណាំ : គណនីលេខ ៤២២ ពុំចាំបាច់មានគំរូហត្ថលេខារបស់ម្ចាស់គណនី ហើយត្រូវចែកជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង និងសំរាប់សំអិតទៅតាមក្រសួង ស្ថាប័ន មន្ទីរព្រមទាំងចែកជាឆ្នាំចាស់ និងឆ្នាំថ្មី ។

៤៩.គណនី ប្រាក់បញ្ញើមូលនិធិអាណត្តិប្រៃសណីយ៍ " លេខ ៤៤១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយបានមកពីការបង់ជាសាច់ប្រាក់ ឬពីការបង្វែររបស់ ក្រសួង និង មន្ទីរប្រៃសណីយ និង ទូរគមនាគមន៍ សំរាប់កិច្ចប្រតិបត្តិការសេវាអាណត្តិប្រៃសណីយ៍ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរចេញពីរតនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាសាច់ប្រាក់ ដោយបង្វែរ ឬតាមអាណត្តិបើកប្រាក់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រសួង ឬមន្ទីរប្រៃសណីយ៍ និង ទូរគមនាគមន៍ កំពុងមាននៅរតនាគារដែលពុំទាន់បានប្រើប្រាស់ ។

ចំណាំ : គណនីនេះត្រូវមានគំរូហត្ថលេខាពីម្ចាស់គណនី និងត្រូវចែកទៅជាអនុគណនី សំរាប់រតនាគារកណ្តាល និង សំរាប់រតនាគារខេត្ត-ក្រុង ។

៥០.គណនី ប្រាក់បញ្ញើថវិកា ខេត្ត-ក្រុង " លេខ ៤៤២ " :

គណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ ចំណូល ចំណាយ របស់ខេត្ត-ក្រុង ដែលបានពីប្រភពចំណូលផ្ទាល់នៅខេត្ត-ក្រុង និង បានពីឧបត្ថម្ភធន ពីថ្នាក់កណ្តាល និងពីប្រភព

ផ្សេងៗទៀត ។

ការកត់ត្រា ៖

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែល ខេត្ត-ក្រុងបានដក ជាសាច់ប្រាក់ ដោយបង្វែរ ឬមូលប្បទានប័ត្រ

- កត់ត្រាចំនួនទឹកប្រាក់ ដែល ខេត្ត-ក្រុង បានផ្ទេរចូលថវិការដ្ឋ (ផ្ទេរអតិរេក)

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែល ខេត្ត-ក្រុងបានបង់ជាសាច់ប្រាក់ បង្វែរ ឬមូលប្បទានប័ត្រ

- កត់ត្រាចំនួនទឹកប្រាក់ឧបត្ថម្ភតុល្យភាព ដែលបានទទួលពីថ្នាក់កណ្តាល និងពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ខេត្ត-ក្រុងកំពុងមាននៅរតនាគារ ពុំទាន់បានប្រើប្រាស់ ។

ចំណាំ ៖ គណនីនេះមានប្រតិបត្តិការឆ្លុះបញ្ចាំងបញ្ច្រាស់ នឹងគណនីប្រាក់បញ្ញើរបស់ ខេត្ត-ក្រុង នៅរតនាគារ ដែលមានគណនី លេខ ៥១៥ (ក្នុងប្រព័ន្ធគណនីនៃគណនេយ្យទូទៅសំរាប់ថវិកាខេត្ត-ក្រុង) ។

៥១. គណនី ប្រាក់បញ្ញើថវិកា ឃុំ សង្កាត់ " លេខ ៤៤៣ " ៖

គណនីនេះបើកនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយ របស់ឃុំ សង្កាត់ ដែលបានពីប្រភពចំណូលផ្ទាល់នៅឃុំ សង្កាត់ ពីអំណោយ ពីអង្គការជាតិ អន្តរជាតិ ឧបត្ថម្ភកធន ពីរដ្ឋ និង ឧបត្ថម្ភកធនពី ខេត្ត-ក្រុង ។

ការកត់ត្រា ៖

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលឃុំ សង្កាត់ បានដកប្រើប្រាស់ ក្រោមរូបភាពជាសាច់ប្រាក់មូលប្បទានប័ត្រ ឬ បង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលជាចំណូលថវិកា ចំណូលពីប្រាក់កក់ ចំណូលផ្សេងៗ ដោយបង់ជាសាច់ប្រាក់ ឬ បង្វែរតាមរយៈធនាគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើដែល ឃុំ សង្កាត់កំពុងមាន ដែលពុំទាន់បានចាត់ចែង ឬ ប្រើប្រាស់ ។

ចំណាំ : - គណនីលេខ ៤៤៣ ត្រូវមានគំរូហត្ថលេខា និងបើកលំអិតទៅតាម ឃុំ សង្កាត់និមួយៗ (តាមលេខកូដរបស់ ឃុំ សង្កាត់)

- ចលនាខាងឥណទាននៃគណនី លេខ ៤៤៣ ឆ្លុះបញ្ចាំងបញ្ច្រាសនឹងចលនាខាងឥណពន្ធ នៃគណនីសាច់ប្រាក់ដែលត្រូវផ្តល់ដោយរដ្ឋាភិបាល (លេខ ៤១.១) ក្នុងប្លង់គណនេយ្យទូទៅសំរាប់ថវិកា ឃុំ សង្កាត់ ។

- ចលនាខាងឥណពន្ធ នៃគណនីលេខ ៤៤៣ ឆ្លុះបញ្ចាំងបញ្ច្រាសនឹងចលនាខាងឥណទាន នៃគណនីប្រាក់បញ្ញើនៅរតនាគារ (គណនី លេខ ៥១ ក្នុងប្លង់គណនេយ្យទូទៅសំរាប់ថវិកា ឃុំ សង្កាត់ ។

- សមតុល្យ ឥណទាយី នៃ គណនីលេខ ៤៤៣ ត្រូវស្មើនឹងផលបូក សមតុល្យឥណពន្ធ នៃគណនីលេខ ៤១.១ និង សមតុល្យឥណពន្ធនៃគណនីលេខ ៥១ (ប្លង់គណនេយ្យទូទៅសំរាប់ថវិកា ឃុំ សង្កាត់) ។

៥២.គណនី "ប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជន" លេខ ៤៥០ :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើរបស់ក្រុមហ៊ុនឯកជនដែលបានពីការទូទាត់ដោយអាណត្តិបើកប្រាក់ ការបង់ជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬ បង្វែរពីប្រភពផ្សេង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានសងទៅក្រុមហ៊ុន

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលក្រុមហ៊ុន បានបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់ដែលក្រុមហ៊ុនទទួលការទូទាត់ដោយអាណត្តិបើកប្រាក់របស់ក្រសួង មន្ទីរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រុមហ៊ុនមាននៅរតនាគារដែលពុំទាន់ប្រើប្រាស់ ។

<u>ចំណាំ</u> : - គណនីលេខ ៤៥០ ត្រូវចែកជាអនុគណនី សំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង ចែកជាប្រាក់បញ្ញើឆ្នាំចាស់ ឆ្នាំថ្មី លំអិតទៅតាមក្រុមហ៊ុននីមួយៗ និង ចែកទៅតាមប្រភេទប្រតិបត្តិការបង់ជាសាច់ប្រាក់និង បានពីការទូទាត់ដោយអាណត្តិបើកប្រាក់ ។

- គណនីត្រូវនេះមានគំរូហត្ថលេខារបស់ម្ចាស់គណនី ។ ពេលសុំបើកគណនី ម្ចាស់គណនីត្រូវមាន ប័ណ្ណប៉ាតង់ និង លិខិតអនុញ្ញាត្តិអាជីវកម្ម ។

៥៣.គណនី "ប្រាក់បញ្ញើរបស់គ្រឹះស្ថានសេដ្ឋកិច្ចស្វយ័ត" លេខ ៤៥១" :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល និង ចំណាយ របស់អង្គភាពសេដ្ឋកិច្ចស្វយ័ត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬដោយបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានមកពីការទូទាត់ដោយអាណត្តិបើកប្រាក់របស់ក្រសួង មន្ទីរ

- កត់ត្រានូវចំនួនទឹកប្រាក់ចំណូលដែលបានមកពីការផ្ទេរពីប្រភពផ្សេងៗ

សមតុល្យ : ឥណទាយី បង្ហាញចំនួនប្រាក់បញ្ញើរបស់អង្គភាពសេដ្ឋកិច្ចស្វយ័តមាននៅរតនាគារដែលពុំទាន់បាន ប្រើប្រាស់ ។

ចំណាំ : គណនីលេខ ៥៤១ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី និងត្រូវចែកទៅជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្ដាល សំរាប់រតនាគារខេត្ត-ក្រុង លំអិតទៅតាមអង្គភាពសេដ្ឋកិច្ចស្វយ័តនិមួយៗ និងចែកជាបំណុលឆ្នាំចាស់ និងឆ្នាំថ្មី ។

៥៤_គណនី ប្រាក់បញ្ញើរបស់សហគ្រាសចំរុះ " លេខ ៤៥២ " :

គណនីនេះបើកនៅរតនាគារកណ្ដាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់ចុះកិច្ចបញ្ជិកាទឹកប្រាក់ចំណូល ចំណាយរបស់អង្គភាពសេដ្ឋកិច្ចចំរុះរដ្ឋដែលបានផ្ញើនៅរតនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រានូវចំនួនទឹកប្រាក់ដែលបានដក តាមរូបភាពជា សាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

ឥណទាន : - កត់ត្រានូវចំនួនទឹកប្រាក់ចំណូលរបស់អង្គភាពចំរុះរដ្ឋដែលបានបង់ក្រោមរូបភាព ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

- កត់ត្រានូវចំនួនទឹកប្រាក់ចំណូលរបស់អង្គភាពចំរុះរដ្ឋ ដែលបានពីការទូទាត់ដោយអាណត្តិបើកប្រាក់

សមតុល្យ : ឥណទាយី បង្ហាញនូវចំនួនទឹកប្រាក់ដែលអង្គភាពសេដ្ឋកិច្ចចំរុះរដ្ឋកំពុងមាននៅរតនាគារពុំទាន់ប្រើប្រាស់ ។

ចំណាំ : គណនីលេខ ៤៥២ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី និងត្រូវបើកលំអិតទៅតាមអង្គភាពផ្ញើប្រាក់នីមួយៗ ។

៥៥_គណនី ប្រាក់បញ្ញើមូលនិធិរបស់អង្គការជាតិ អន្តរជាតិ " លេខ ៤៥៣ " :

គណនីនេះបើកនៅរតនាគារកណ្ដាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលចំណាយរបស់អង្គការ សមាគមដែលបានយកមកផ្ញើនៅរតនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលអង្គការ សមាគមបានដកជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬបង្វែរដែលអង្គការសមាគមបានយកមកផ្ញើ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់អង្គការ សមាគមនៅរតនាគារដែលពុំទាន់ដកយក ទៅប្រើប្រាស់ ។

ចំណាំ : គណនីលេខ ៤៥៣ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី និងត្រូវចែកទៅជាអនុគណនីទៅតាមអង្គការសមាគមនីមួយៗ ។

៥៦_អនុគណនី ទំនាក់ទំនងរវាងរតនាគារកណ្តាល និង រតនាគារខេត្ត_ក្រុង អំពីការផ្ទេរសាច់ប្រាក់ " លេខ ៤៥៨.១.៣ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនប្រាក់ដែលបានផ្ទេរពីរតនាគារថ្នាក់កណ្តាលទៅរតនាគារខេត្ត-ក្រុង និងពីរតនាគារខេត្ត-ក្រុងមកវិញ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនប្រាក់ដែលរតនាគារកណ្តាលបានបញ្ជូនទៅរតនាគារខេត្ត-ក្រុង

- កត់ត្រាចំនួនតួលេខផ្ទេរសមតុល្យឥណទាយីទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

ឥណទាន : - កត់ត្រាចំនួនប្រាក់ដែលរតនាគារខេត្ត-ក្រុងផ្ទេរមក

- កត់ត្រាផ្ទេរសមតុល្យឥណពន្ធទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

សមតុល្យ : - ឥណពន្ធ បង្ហាញចំនួនប្រាក់ដែលរតនាគារកណ្តាលបានផ្ទេរទៅរតនាគារខេត្តក្រុងបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

- ឥណទាយី បង្ហាញអំពីចំនួនប្រាក់ដែលរតនាគារខេត្ត-ក្រុងផ្ទេរមករតនាគារកណ្តាលបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ ។

ចំណាំ : អនុគណនីនេះត្រូវចែកទៅជាអនុគណនីបន្តទៅតាមរតនាគារខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធហើយត្រូវអសមតុល្យនៅដំណាច់ឆ្នាំ ។

៥៧_អនុគណនី ទំនាក់ទំនងរវាងរតនាគារកណ្តាល និងរតនាគារខេត្ត_ក្រុងអំពីការផ្ទេរប្រតិបត្តិការផ្សេង ៗ " លេខ ៤៥៨.១.៤ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗ (ក្រៅពីផ្ទេរ សាច់ប្រាក់ ផ្ទេរសមតុល្យ) ពីរតនាគារកណ្តាលទៅរតនាគារខេត្ត-ក្រុង និងទទួលតួលេខផ្ទេរពីរតនាគារខេត្ត-ក្រុងមក ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗ ពីរតនាគារខេត្ត -ក្រុងមករតនាគារកណ្តាល
- កត់ត្រាផ្ទេរសមតុល្យឥណទាយីចូលទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

ឥណទាន : - កត់ត្រាចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗពីរតនាគារកណ្តាលទៅរតនាគារខេត្ត-ក្រុង
- កត់ត្រាផ្ទេរសមតុល្យឥណាយិកចូលទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

សមតុល្យ : - ឥណាយិក បង្ហាញចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗពីរតនាគារខេត្ត-ក្រុង មកដែលពុំទាន់ផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ ។
- ឥណទាយី បង្ហាញចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗ ពីរតនាគារកណ្តាលទៅរតនាគារខេត្តក្រុង ដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនង អំពីការផ្ទេរសមតុល្យ ។

ចំណាំ : អនុគណនីនេះត្រូវចែកទៅជាអនុគណនីបន្តទៅតាមរតនាគារខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ។

៥៨. អនុគណនី ទំនាក់ទំនងរវាងរតនាគារកណ្តាល និងរតនាគារខេត្ត-ក្រុងអំពីការផ្ទេរសមតុល្យ " លេខ ៤៥៨.១.៥ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនតួលេខ ផ្ទេរសមតុល្យមកពីអនុគណនីលេខ ៤៥៨.១.៣ និង ៤៥៨.១.៤ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតួលេខផ្ទេរសមតុល្យឥណាយិកនៃអនុគណនីលេខ ៤៨៥.១.៣ និង ៤៥៨.១.៤

ឥណទាន : កត់ត្រាតួលេខផ្ទេរ សមតុល្យឥណទាយីនៃអនុគណនី លេខ ៤៥៨.១.៣ និង ៤៥៨.១.៤

សមតុល្យ :- ឥណាយិក បង្ហាញចំនួនតួលេខផ្ទេរសមតុល្យបូកបន្តនៃអនុគណនីលេខ ៤៥៨.១.៣ និង ៤៥៨១.៤
- ឥណទាយី បង្ហាញចំនួនតួលេខផ្ទេរសមតុល្យបូកបន្តនៃអនុគណនីលេខ ៤៥៨.១.៣ និង ៤៥៨.១.៤

ចំណាំ : អនុគណនីនេះត្រូវចែកទៅជាអនុគណនីបន្តទៅតាមរតនាគារខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ។

៥៩. អនុគណនី ទំនាក់ទំនងរវាងរតនាគារខេត្ត-ក្រុង និងរតនាគារកណ្តាលអំពីការផ្ទេរសាច់ប្រាក់ " លេខ ៤៥៨.២.៣ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនតួលេខស្តីពីការបញ្ជូនប្រាក់ពីរតនាគារខេត្ត-ក្រុង ទៅរតនាគារកណ្តាល និងទទួលពីរតនាគារកណ្តាលមកវិញ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនប្រាក់ដែលបានបញ្ជូនទៅរតនាគារកណ្តាល

- កត់ត្រាចំនួនតួលេខផ្ទេរសមតុល្យឥណាយិកទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

ឥណទាន : - កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគារកណ្តាលបានបញ្ជូនមក

- កត់ត្រាផ្ទេរសមតុល្យឥណទាយីទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

សមតុល្យ : - ឥណាយិក បង្ហាញអំពីចំនួនប្រាក់ដែលបានផ្ទេរទៅរតនាគារកណ្តាលបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ ។

- ឥណទាយី បង្ហាញអំពីចំនួនប្រាក់ដែលបានផ្ទេរពីរតនាគារកណ្តាលមករតនាគារខេត្ត-ក្រុង បូកបន្តដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ ។

ចំណាំ : អនុគណនីលេខ ៤៥៨.២.៣ ត្រូវអសមតុល្យនៅដំណាច់ឆ្នាំ ។

៦០-អនុគណនី ទំនាក់ទំនងរតនាគារខេត្ត-ក្រុង និង រតនាគារកណ្តាលអំពីការផ្ទេរប្រតិបត្តិការផ្សេងៗ " លេខ ៤៥៨.២.៤ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនតួលេខផ្ទេរប្រតិបត្តិការផ្សេងៗ ពីរតនាគារខេត្ត-ក្រុង ទៅរតនាគារកណ្តាល និង ពីរតនាគារកណ្តាលមករតនាគារខេត្ត-ក្រុង ។

ការកត់ត្រា :

ឥណពន្ធ :- កត់ត្រាផ្ទេរតួលេខនៃប្រតិបត្តិការផ្សេងៗ ដែលផ្ទេរ ពីរតនាគារកណ្តាល មករតនាគារខេត្ត-ក្រុង

- កត់ត្រាការផ្ទេរសមតុល្យឥណទាយី ចូលទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

ឥណទាន :- កត់ត្រាផ្ទេរតួលេខនៃប្រតិបត្តិការផ្សេងៗ ពី រតនាគារខេត្ត-ក្រុង ទៅរតនាគារកណ្តាល

- កត់ត្រាការផ្ទេរសមតុល្យឥណាយិកចូលទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ

សមតុល្យ : - ឥណាយិក បង្ហាញចំនួនតួលេខផ្ទេរនៃប្រតិបត្តិការផ្សេងៗ ពីរតនាគារកណ្តាលមកដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនងអំពីការផ្ទេរសមតុល្យ ។

- ឥណទាយី បង្ហាញចំនួនតួលេខផ្ទេរនៃប្រតិបត្តិការផ្សេងៗ ពីរតនាគារខេត្ត-ក្រុងទៅរតនាគារកណ្តាលដែលពុំទាន់បានផ្ទេរទៅគណនីទំនាក់ទំនង អំពីការផ្ទេរសមតុល្យ ។

៦១-អនុគណនី ទំនាក់ទំនងរវាងរតនាគារខេត្ត-ក្រុង និងរតនាគារកណ្តាល អំពីការផ្ទេរសមតុល្យ " លេខ ៤៥៨.២.៥ " :

អនុគណនីនេះបើកនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនតួលេខផ្ទេរសមតុល្យមកពីអនុគណនីលេខ ៤៥៨.២.៣ , ៤៥៨.២.៤ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាតួលេខផ្ទេរសមតុល្យឥណាយិកនៃអនុគណនី លេខ ៤៥៨.២.៣ និង ៤៥៨.២.៤

ឥណទាន : កត់ត្រាតួលេខផ្ទេរសមតុល្យឥណទាយីនៃអនុគណនី លេខ ៤៥៨.២.៣ និង ៤៥៨.២.៤

សមតុល្យ : - ឥណាយិក បង្ហាញចំនួនតួលេខផ្ទេរសមតុល្យបូកបន្តនៃអនុគណនី៤៥៨.២.២ ៤៥៨.២.៣ និង ៤៥៨.២.៤

- ឥណទាយី បង្ហាញចំនួនតួលេខផ្ទេរសមតុល្យបូកបន្តនៃអនុគណនី ៤៥៨.២.៣ និង ៤៥៨.២.៤

__ចំណាំ__ : អនុគណនីនេះត្រូវចែកជាអនុគណនីបន្តទៅតាមរតនាគារខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ។

៦២_អនុគណនី ទិសមតាពបេឡា ឥណាយិក " លេខ ៤៦០.១ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡារវាងបញ្ជីបេឡា នឹង សាច់ប្រាក់ជាក់ស្តែង ដោយយោងតាមបញ្ជីសារពើភ័ណ្ឌ និង ប័ណ្ណចំណាយបេឡា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡាបានដោះស្រាយជាចំណាយថវិកា ឬបានបំពេញជាសាច់ប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់លំអៀងខ្វះក្នុងបេឡាដែលពុំទាន់បានដោះស្រាយ ។

៦៣_អនុគណនីទិសមតាពបេឡា ឥណទាយី" លេខ ៤៦០.២" :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡារវាងបញ្ជីបេឡា នឹងសាច់ប្រាក់ជាក់ស្តែង ដោយយោងតាមបញ្ជីសារពើភ័ណ្ឌ និងប័ណ្ណចំណូលបេឡា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡាដែលបានដោះស្រាយផ្ទេរជាចំណូលថវិការដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងលើសក្នុងបេឡា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ លំអៀងលើសក្នុងបេឡាដែលពុំទាន់បានដោះស្រាយ ។

៦៤_គណនី ឱនភាពគណនេយ្យត្រូវដោះស្រាយ " លេខ ៤៦១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ឱនភាពរបស់គណនេយ្យករដែលបណ្តាលមកពីការផ្ទេរប្រាក់លើសពីសមតុល្យឥណទាយី ឬការគណនាបញ្ជីខុស ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលខ្វះ ឬបាត់លើបញ្ជីគណនេយ្យហើយរង់ចាំការដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលខ្វះ ឬបាត់លើបញ្ជីគណនេយ្យដែលបានដោះស្រាយជាចំណាយថវិកា ឬបានសងប្រាក់វិញ ។

សមតុល្យ : ឥណពន្ធិក បង្ហាញចំនួនទឹកប្រាក់ឱនភាពគណនេយ្យដែលពុំទាន់បានដោះស្រាយ ។

<u>**ចំណាំ**</u> : គណនីលេខ ៤៦១ ត្រូវចែកជាអនុគណនី សំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង និងលំអិតទៅតាមអ្នកទទួលខុសត្រូវលើឱនភាពនិមួយៗ ។

៦៥_គណនី ប្រាក់តំកល់ និងធានាលើទីផ្សារសាធារណៈ " លេខ ៤៦២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលអ្នកផ្គត់ផ្គង់ អ្នកម៉ៅការបានបង់សំរាប់ដឹកលំធានា លើការដេញថ្លៃ ធានាគុណភាព ធានាលើការផ្គត់ផ្គង់ ដោយយោងតាមតាមកិច្ចសន្យា ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់តំកល់ និងធានាដែលបានសងជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

- កត់ត្រាចំនួនទឹកប្រាក់តំកល់ និងធានាដែលបានផ្ទេរចូលថវិការដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់តំកល់ និងធានា ដែលបានទទួលជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់តំកល់ និងធានា ដែលមាននៅរតនាគារ ។

<u>**ចំណាំ**</u> : - គណនីនេះត្រូវចែកទៅជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង និងលំអិតទៅតាមសាម៉ីក្រសួង មន្ទីរ អង្គភាពជាអ្នកទទួលការផ្គត់ផ្គង់ ហើយមានគំរូហត្ថលេខាម្ចាស់គណនី ។

- នៅពេលដកប្រាក់កក់វិញ ក្រសួង មន្ទីរ អង្គភាព ត្រូវចេញលិខិតបញ្ជាក់មក រតនាគារដើម្បីបើកផ្តល់ប្រាក់ជូនទៅអ្នកបានបង់ប្រាក់ ។

៦៦_គណនី ឥណទាយិកផ្សេងៗ " លេខ ៤៦៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់រង់ចាំដោះស្រាយជាចំណាយថវិកា ឬផ្ទេរទៅគណនីសកម្មផ្សេងទៀត ។ គណនីលេខ ៤៦៣ ជាគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលត្រូវដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានដោះស្រាយ ដោយចេញអាណត្តិបើកប្រាក់ ឬផ្ទេរទៅគណនីផ្សេងទៀត

សមតុល្យ : ឥណទាយិក បង្ហាញចំនួនទឹកប្រាក់ដែលកំពុងរង់ចាំការដោះស្រាយ ។

ចំណាំ : គណនីនេះត្រូវចែកទៅជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល នៅរតនាគារ ខេត្ត-ក្រុង និងលំអិតតាមដានទៅតាមមុខសញ្ញានីមួយ ៗ ។

៦៧_អនុគណនី មូលនិធិថែទាំផ្លូវ " លេខ ៤៦៣.១ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ជាប្រភពនៃមូលនិធិសំរាប់ថែទាំផ្លូវ ដែលបានពីការប្រាក់ចំណូលពន្ធលើការនាំចូលប្រេងឥន្ធនៈ និងប្រភពផ្សេងៗ ទុកចំណាយលើការថែទាំផ្លូវ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់មូលនិធិដែលបានត្រៀមទុកចំណាយលើការថែទាំផ្លូវ

(ខាងឥណពន្ធ នៃគណនីនេះបដិភាគ នឹងខាងឥណទាន នៃគណនីបន្ទុកត្រូវសងលើធនធានបែងចែក (លេខ ៤៦៨.២)

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់មូលនិធិដែលបានចំណាយ

(ខាងឥណទាននៃគណនីនេះបដិភាគនឹងខាង ឥណពន្ធ នៃគណនីបន្ទុកត្រូវសងលើធនធានបែងចែកលេខ ៤៦៨.២ ទន្ទឹមលេខនាបើកផ្តល់ប្រាក់) ។

សមតុល្យ : ឥណទាយិក បង្ហាញចំនួនទឹកប្រាក់មូលនិធិសំរាប់ថែទាំផ្លូវដែលពុំទាន់បានប្រើប្រាស់ ។

ចំណាំ : សមតុល្យនៃគណនី លេខ ៤៦៨.២ត្រូវ ស្មើនឹងចំនួនសាច់ប្រាក់ទុកបំរុងចំណាយលើការថែទាំផ្លូវ ។

៦៨_គណនី មូលនិធិ ឃុំ សង្កាត់ " លេខ ៤៦៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយមូលនិធិដែល

បានមកពីការផ្តល់វិភាជន៍ពីថវិការដ្ឋ បានមកពីអំណោយ ប្រាក់ខ្ចីក្នុង និងក្រៅប្រទេស ពីអង្គការជាតិ អន្តរជាតិ និង ពីប្រភពផ្សេងទៀតសំរាប់ ឃុំ សង្កាត់ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ដែលបានដកដោយបង្វែរទៅថវិកាឃុំ សង្កាត់តាមរយៈរតនាគារខេត្ត-ក្រុង

- កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរទៅថវិកាឃុំ សង្កាត់តាមរយៈធនាគារជាតិនៃកម្ពុជា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលបានពីការផ្តល់វិភាជន៍ពីថវិការដ្ឋតាមអាណត្តិបើកប្រាក់

- កត់ត្រាចំនួនប្រាក់ដែលបានទទួលពីប្រភពផ្សេងទៀត

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់មូលនិធិឃុំ សង្កាត់ ដែលមាននៅរតនាគារកណ្តាលពុំទាន់បានបែងចែក។

ចំណាំ : គណនីលេខ ៤៦៤ មានតំរូវហត្ថលេខារបស់ម្ចាស់គណនី ។

៦៩-អនុគណនី អតិរេកពីការបង់ប្រាក់លើស " លេខ ៤៦៥.១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលអតិថិជន អ្នកជាប់ពន្ធបានបង់ចូលរតនាគារលើសពីកាតព្វកិច្ច ហើយរង់ចាំដោះស្រាយ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បង់លើស ដែលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់ចូលរតនាគារលើសពីកាតព្វកិច្ច

សមតុល្យ : ឥណទាយី បង្ហាញចំនួនអតិរេកពីការបង់ប្រាក់ដោយអ្នកជាប់ពន្ធ អតិថិជនដែលពុំទាន់បានដោះស្រាយ ។

ចំណាំ : គណនីលេខ ៤៦៥.១ ត្រូវចែកជាអនុគណនី សំរាប់អ្នកបានបង់ប្រាក់លើសនីមួយៗ។

៧០-គណនី ប្រាក់បញ្ញើរបស់ក្រសួង មន្ទីរ " លេខ ៤៦៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បញ្ញើរបស់ក្រសួង និងអង្គភាពចំណុះក្រសួង របស់មន្ទីរ និងអង្គភាពចំណុះឬ (ក្រៅពីប្រាក់បៀវត្ស និងប្រាក់បំណាច់ រង្វាន់ទេយ្យបុរេប្រទាន រង្វាន់ទេយ្យចំណូល និង ប្រាក់បញ្ញើរបស់អង្គភាពស្វយ័ត) ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬដោយបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែល ក្រសួង មន្ទីរ និងអង្គភាពចំណុះបានទទួលពដោយអាណត្តិបើក ប្រាក់ ឬ បង្វែរពីប្រភពផ្សេងមក

- កត់ត្រាចំនួនទឹកប្រាក់ដែលក្រសួង មន្ទីរ និងអង្គភាពចំណុះបានបង់ចូលរតនាគារជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬដោយបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់ក្រសួង មន្ទីរ និងអង្គភាពចំណុះពុំទាន់បានដកប្រើប្រាស់ ។

ចំណាំ : អនុគណនីលេខ ៤៦៧ ត្រូវចែកជាអនុគណនីសំរាប់ ក្រសួង អង្គភាពចំណុះក្រសួង មន្ទីរ និងសំរាប់អង្គភាពចំណុះមន្ទីរ ព្រមទាំងចែកជាឆ្នាំចាស់ និង ឆ្នាំថ្មី ។ គណនីនេះមានតំរូហត្ថលេខាម្ចាស់គណនី ។

៧១-អនុគណនី បន្ទុកត្រូវសងទៅគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត " លេខ ៤៦៨.១ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានដកជាសាច់ប្រាក់ ជាមូលប្បទានប័ត្រ ឬ ដោយបង្វែរ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានទទួលតាមអាណត្តិបើកប្រាក់ ឬពីប្រភពផ្សេងទៀត

សមតុល្យ : ឥណទាយី បង្ហាញចំនួនប្រាក់បញ្ញើរបស់គណកម្មាធិការជាតិរៀបចំការបោះឆ្នោតមាននៅរតនាគាររតនាគារដែលពុំទាន់បានដកយកទៅប្រើប្រាស់ ។

ចំណាំ : គណនីនេះមានតំរូហត្ថលេខារបស់ម្ចាស់គណនី ហើយចែកជាអនុគណនីសំរាប់រតនាគារថ្នាក់កណ្តាល និងសំរាប់រតនាគារខេត្ត-ក្រុង ។

៧២-អនុគណនី បន្ទុកត្រូវសងលើថវិកាថែទាំផ្លូវ " លេខ ៤៦៨.២ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ប្រភពមូលនិធិ ដែលបានកត់ត្រាទុកសំរាប់ប្រើប្រាស់លើការចំណាយថែទាំ ជួសជុលផ្លូវ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់នៃមូលនិធិដែលបានប្រើប្រាស់ (កត់ត្រានៅពេលបើកផ្តល់ប្រាក់)

- កត់ត្រាចំនួនមូលនិធិដែលបានជំរះ ឬលុបចោល

ឥណទាន : កត់ត្រាចំនួនមូលនិធិដែលបានសន្សំទុកពីពន្ធនាំចូលប្រេងឥន្ធនៈ (យោងតាមសលាកប័ត្រលេខនា និង ប្រតិវេទក៍គយ) និងប្រភពផ្សេងទៀត .

សមតុល្យ : ឥណទាយី បង្ហាញចំនួនមូលនិធិសំរាប់ចំណាយលើការថែទាំផ្លូវពុំទាន់បានប្រើប្រាស់ ។

ចំណាំ : អនុគណនីនេះ ពុំមានគំរូបហត្ថលេខារបស់ម្ចាស់គណនីទេ ហើយកត់ត្រា បដិភាគនឹងគណនីមូលនិធិថែទាំផ្លូវ (លេខ ៤៦៣.១) ។ សមតុល្យនៃគណនី ៤៦៨.២ ស្មើនឹងប្រាក់បំរុងទុកប្រើប្រាស់លើការថែទាំជួសជុលផ្លូវ ។

៧៣_អនុគណនី ប្រាក់កំរៃរួមរតនាគារ " លេខ ៤៧០.១ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយកំរៃសេវារបស់រតនាគារ ដែលបានមកពីការផ្ទេរប្រាក់ពីគណនីឯកជន គណនីប្រាក់បញ្ញើអង្គភាពស្វយ័តទៅគណនីឯកជនមួយទៀត ។

ការកត់ត្រា :

ឥណពន្ធ :- កត់ត្រាចំនួនទឹកប្រាក់ដែលបានបង្វែរចូលថវិការដ្ឋ (រតនាគារកណ្តាលនិងនៅរតនាគារខេត្ត ក្រុង)

- កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅរតនាគារកណ្តាល (នៅរតនាគារខេត្ត-ក្រុង)
- កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅគណនីកំរៃអត្ថប្រយោជន៍របស់រតនាគារកណ្តាល (ការកត់ត្រានៅរតនាគារកណ្តាល)

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលពីកំរៃសេវារបស់រតនាគារដោយបានពីការបង់ជាសាច់ប្រាក់ ឬបង្វែរ (នៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់កំរៃរួមរបស់រតនាគារដែលពុំទាន់បានបែងចែក ។

៧៤_អនុគណនី ប្រាក់កំរៃអត្ថប្រយោជន៍រតនាគារជាតិ " លេខ ៤៧០.២ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយប្រាក់កំរៃជាអត្ថប្រយោជន៍របស់រតនាគារជាតិ ដែលបានមកពីការផ្ទេរពីគណនីកំរៃរួមនៅរតនាគារនៅថ្នាក់កណ្តាល និងបានពីការផ្ទេរពីរតនាគារ ខេត្ត-ក្រុង។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកជាសាច់ប្រាក់

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីគណនីកំរៃរួមរតនាគារ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរពីរតនាគារខេត្ត-ក្រុង (ចំណែកសល់ពីការបង់ចូលថវិកា)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់កំរៃជាអត្ថប្រយោជន៏របស់រតនាគារជាតិ ដែលពុំទាន់បានដកយកទៅប្រើប្រាស់ ។

៧៥_អនុគណនី សាច់ប្រាក់បានទទួលពីរតនាគារខេត្ត_ក្រុងរង់ចាំនិយ័ត្តកម្ម " លេខ៤៧០.៣ ":

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនសាច់ប្រាក់ដែល រតនាគារកណ្តាលបានទទួលពីរតនាគារខេត្ត-ក្រុងផ្ទេរមកតាមរយៈធនាគារជាតិ នៃកម្ពុជា ហើយរង់ចាំទូទាត់ជាមួយប្រកាសឥណពន្ធដែលរតនាគារខេត្ត-ក្រុង ត្រូវប្រគល់មករតនាគារកណ្តាលនៅពេលក្រោយ ។ គណនីលេខ ៤៧០.៣ ជាប្រភេទគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានទទួល ហើយបានទូទាត់ជាមួយប្រកាសឥណពន្ធរបស់រតនាគារខេត្ត-ក្រុង

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានទទួល ហើយពុំទាន់បានទូទាត់ជាមួយប្រកាសឥណពន្ធ របស់រតនាគារខេត្ត-ក្រុង

សមតុល្យ : ឥណទាយី បង្ហាញចំនួនសាច់ប្រាក់ដែលបានទទួលរង់ចាំការទូទាត់ជាមួយប្រកាសឥណពន្ធ ។

ចំណាំ : អនុគណនីនេះត្រូវតាមដានលំអិតទៅតាមរតនាគារខេត្ត-ក្រុង ដែលបានផ្ទេរប្រាក់មក ។

៧៦_អនុគណនី ចំណេញពីអត្រាប្តូរប្រាក់រង់ចាំការដោះស្រាយ " លេខ ៤៧០.៤ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់លំអៀងពីអត្រាប្តូរប្រាក់ដែលកើតមានឡើង នៅពេលបោះផ្សាយអាណត្តិបើកប្រាក់ជារូបិយបណ្ណ័ និងពេលទូទាត់ជាក់ស្តែង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណេញពីលំអៀងអត្រាប្តូរប្រាក់ដែលបានផ្ទេរចូលជាចំណូលថវិការដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណេញពីលំអៀងអត្រាប្តូរប្រាក់រវាងចំនួនទឹកប្រាក់ត្រូវសង (ចំនួនប្រាក់រូបិយបណ្ណ័ គិតជាប្រាក់រៀលជាមួយអត្រាប្តូរប្រាក់ពេលចេញអាណត្តិបើកប្រាក់) នឹងចំនួនទឹកប្រាក់បានសង (ចំនួនប្រាក់រូបិយ័ណ្ណគិតជាប្រាក់រៀលជាមួយអត្រាប្តូរប្រាក់ពេលបើកផ្តល់).

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណេញពីលំអៀងអត្រាប្តូរពុំទាន់បានបង្វែរចូលថវិកា ។

៧៧_អនុគណនី ចំណូលផ្សេងៗ និង បង្វែររង់ដោះស្រាយ " លេខ ៤៧០.៨ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលផ្សេងៗ ឬ ចំនួនទឹកប្រាក់ដែលត្រូវបង្វែរទៅគណនីអ្នកម្មផ្សេងទៀត ។ គណនីលេខ ៤៧០.៨ ជាគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលបានដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលរង់ចាំដោះស្រាយ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលរង់ចាំការដោះស្រាយ ។

ចំណាំ : គណនីលខ ៤៧០.៨ ត្រូវចែកជាអនុគណនីទៅតាមប្រភពចំណូលនីមួយៗ ។

៧៨_គណនី ចំណូលបណ្តោះអាសន្ន (គយ_ពន្ធ) " លេខ ៤៧១ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលអង្គភាពពន្ធដារ និង អង្គភាពគយនិងរដ្ឋាករបានបង់ជាសាច់ប្រាក់ចូលបេឡារតនាគារឬបានបង្វែរចូលគណនីចរន្តរបស់រតនាគារនៅធនាគារជាតិ នៃកម្ពុជា និងសាខា ដោយរង់ចាំការរៀបចំសលាកប័ត្រផ្ទេរចូលជាចំណូលថវិការដ្ឋ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ ដែលបាន បង្វែរចូលថវិការដ្ឋ

- កត់ត្រាចំនួនទឹកប្រាក់ ដែលបាន បង្វែរទៅគណនីផ្សេងទៀត

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលជាបណ្តោះអាសន្នដែលអង្គភាពពន្ធដារ គយ និងរដ្ឋាករបានបង់ជាសាច់ប្រាក់ដោយការបង្វែរ ឬ ជាមូលប្បទានប័ត្រ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលជាបណ្តោះអាសន្នដែលបានបង់ចូលរតនាគារ ហើយពុំទាន់មានសលាកប័ត្រផ្ទេរចូលថវិការដ្ឋ ឬ បែងចែកទៅមុខសញ្ញាផ្សេងទៀត ។

ចំណាំ : - គណនីលេខ ៤៧១ត្រូវចែកទៅជាអនុគណនី សំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង និងលំអិតទៅតាមអង្គភាពដែលបង់ចំណូល ហើយត្រូវមានគំរូហត្ថលេខាពីម្ចាស់គណនី ។

- គណនីលេខ ៤៧១ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៧៩_អនុគណនី ចំណាយមុនការធ្វើអាណត្តិកិច្ច " លេខ ៤៧២.១ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានចំណាយ(ប្រតិបត្តិការរតនៈវត្ថុ) លើការទូទាត់ការប្រាក់ខ្ចី និងប្រាក់ដើមខ្ចីដោយពុំទាន់បានកត់ត្រាជាចំណាយថវិកាជាស្ថាពរ ដោយរង់ចាំអាណត្តិបើកប្រាក់ដើម្បីធ្វើនិយ័ត្តកម្ម ។ គណនីលេខ ៤៧២.១ ជាគណនីរង់ចាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនការប្រាក់ ឬប្រាក់ដើមខ្ចី ដែលបានសងតាមរូបភាព បង្វែរ ឬ មូលប្បទានប័ត្រ

ឥណទាន : កត់ត្រាចំនួនការប្រាក់ ឬប្រាក់ដើមខ្ចីដែលបានសង ដោយទូទាត់ជាមួយអាណត្តិបើកប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនការប្រាក់ ឬប្រាក់ដើមខ្ចីបានសង តែពុំទាន់មានអាណត្តិបើកប្រាក់ធ្វើនិយ័ត្តកម្ម ។

<u>**ចំណាំ**</u> : អនុគណនីលេខ ៤៧២.១ ត្រូវលំអិតទៅតាមប្រភេទខ្ចង់ប្រាក់ដែលបានសង ។

៨០_អនុគណនី សាច់ប្រាក់បានផ្ទេរទៅរតនាគារខេត្ត-ក្រុង រង់ចាំធ្វើនិយ័ត្តកម្ម "លេខ ៤៧២.២" :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនសាច់ប្រាក់ដែលរតនាគារកណ្តាលបានផ្ទេរទៅរតនាគារខេត្ត-ក្រុង តាមរយៈធនាគារជាតិ នៃកម្ពុជា ហើយរង់ចាំការទូទាត់ជាមួយប្រកាសឥណទានដែលរតនាគារខេត្ត-ក្រុង ប្រគល់មកនៅពេលក្រោយ ។ គណនីលេខ ៤៧២.៣ ជាគណនីរង់ចាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅរតនាគារខេត្ត-ក្រុង
ហើយពុំទាន់បានទទួលប្រកាសឥណទាន

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ ដែលបានទូទាត់ជាមួយប្រកាសឥណទានរបស់រតនាគារ ខេត្ត-ក្រុង

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ដែលបានផ្ទេរទៅរតនាគារខេត្ត-ក្រុង រង់ចាំការទូទាត់ជាមួយប្រកាស ។

<u>**ចំណាំ**</u> : អនុគណនីលេខ ៤៧២.២ ត្រូវលំអិតទៅតាមរតនាគារខេត្ត-ក្រុង ដែលបានផ្ទេរប្រាក់ទៅ ។

៨១_អនុគណនី ខាតពីអត្រាប្តូរប្រាក់ រង់ចាំការដោះស្រាយ " លេខ ៤៧២.៣ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់ចំនួនទឹកប្រាក់លំអៀងពីអត្រាប្តូរប្រាក់ដែលកើតមានឡើងនៅពេលបោះផ្សាយអាណត្តិបើកប្រាក់ជារូបិយបណ្ណ័ និងពេលទូទាត់ជាក់ស្តែង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់លំអៀងខាតពីអត្រាប្តូរប្រាក់រវាងចំនួនប្រាក់ត្រូវសង (ចំនួនប្រាក់រូបិយបណ្ណ័គិតជាប្រាក់រៀលជាមួយអត្រាប្តូរប្រាក់ពេលបោះផ្សាយអាណត្តិបើកប្រាក់) នឹងបានសង (ចំនួនប្រាក់រូបិយប័ណ្ណគិតជាប្រាក់រៀលជាមួយអត្រាប្តូរប្រាក់នៅពេលបើកផ្តល់)

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់លំអៀងខាតពីអត្រាប្តូរប្រាក់ដែលបានដោះស្រាយដោយអាណត្តិបើកប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់លំអៀងខាតពីអត្រាប្តូរប្រាក់ដែលពុំទាន់បានដោះស្រាយ ។

៨២_អនុគណនី ចំណាយផ្សេងៗរង់ចាំដោះស្រាយ " លេខ ៤៧២.៨ " :

អនុគណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយឬមានលក្ខណៈប្រហាក់ប្រហែលដែលរង់ចាំការដោះស្រាយ ឬផ្ទេរទៅគណនីសកម្មផ្សេងទៀត ។គណនីលេខ ៤៧២.៨ ជាគណនីចំលង ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយរង់ចាំការដោះស្រាយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយបានដោះស្រាយ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយរង់ចាំដោះស្រាយ ។

ចំណាំ : គណនីលេខ ៤៧២.៨ ត្រូវចែកជាអនុគណនីសំរាប់មុខសញ្ញានីមួយៗ ។

៨៣_គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សំរាប់ដំណើរការ " លេខ ៤៧៣ ":

គណនីនេះបើកនៅរតនាគារកណ្តាលនិងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បានចំណាយជាបណ្តោះអាសន្នលើការផ្តល់ប្រាក់បុរេប្រទានទៅក្រសួង ស្ថាប័ន មន្ទីរ អង្គភាព (យោងតាមលិខិតសំរេចរបស់ ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ រតនាគារកណ្តាល)សំរាប់ការងារវិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់បុរេប្រទានទៅ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាពក្រោមរូបភាពជា សាច់ប្រាក់ បង្វែរ ឬ មូលប្បទានប័ត្រ

ឥណទាន :- កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយបង់ជាសាច់ប្រាក់ បង្វែរ ឬមូលប្បទានប័ត្រ

- កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយអាណត្តិបើកប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាពបានទទួល ហើយពុំទាន់បានទូទាត់ ។

ចំណាំ :- គណនីនេះត្រូវចែកជាអនុគណនី សំរាប់កត់ត្រាការផ្តល់បុរេប្រទាននៅរតនាគារកណ្តាល នៅរតនាគារខេត្ត-ក្រុង និងលំអិតទៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដែលបានទទួលប្រាក់បុរេប្រទាន

- គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៨៤-គណនី ចំណូលបានទទួលពុំទាន់មានសលាកបត្រ " លេខ ៤៧៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលទទួលបានតែពុំទាន់មានសលាកប័ត្របង់ចូលថវិកាជាស្ថាពរ ក្រៅពីអង្គភាពពន្ធដារ និងអង្គភាពគយនិងរដ្ឋាករ ។ គណនីលេខ ៤៧៤ ជាគណនីរង់ចាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរចូលជាចំណូលថវិកា ឬ បានបន្ថយ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួល ហើយពុំទាន់មានសលាកប័ត្របង់ចូលថវិកា

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលដែលរង់ចាំសលាកប័ត្រផ្ទេរចូលថវិកា ។

ចំណាំ : គណនីលេខ ៤៧៤ ត្រូវចែកជាអនុគណនី សំរាប់រតនាគារកណ្តាល(ជាប្រាក់រៀល និងប្រាក់ដុល្លារអាមេរិក) រតនាគារខេត្ត-ក្រុង និងលំអិតទៅតាមអង្គភាព ដែលមានការពាក់ព័ន្ធលើការបង់ប្រាក់ ។ គណនីនេះពុំមានគំរូបាត្តលេខាម្ចាស់គណនីទេ ។

៨៥-គណនី ចំណូលបណ្តោះអាសន្នរបស់គណនេយ្យកររដ្ឋបាលហិរញ្ញវត្ថុ "លេខ ៤៧៥ " :

គណនីនេះបើកនៅ អង្គភាពគយ និង រដ្ឋាករ និងនៅអង្គភាពពន្ធដារ ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលបានទទួលដោយការបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬ បង្វែរ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់ ឬផ្ទេរចូលរតនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានទទួល ហើយពុំទាន់បង់សាច់ប្រាក់ ឬបង្វែរចូលគណនីចរន្តរបស់រតនាគារ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលដែលពុំទាន់បានផ្ទេរជាសាច់ប្រាក់ ឬបង្វែរទៅរតនាគារ ។

ចំណាំ : គណនីលេខ ៤៧៥ ត្រូវចែកជាអនុគណនី សំរាប់អង្គភាពគយនិង រដ្ឋាករ អង្គភាពពន្ធដារ និងចែក

តាមថ្នាក់កណ្តាល និង ខេត្ត-ក្រុង ។

៨៦-គណនី រដ្ឋទេយ្យករចំណូល " លេខ ៤៧៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រដ្ឋទេយ្យករចំណូល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលបានផ្ទេរចូលថវិការដ្ឋ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូល ដែលរដ្ឋទេយ្យករបានបង់ជាសាច់ប្រាក់ មូលប្បទានប័ត្រ ឬបង្វែរ

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ដែលរដ្ឋទេយ្យករចំណូលពុំទាន់បានបង្វែរចូលជាចំណូលថវិកា។

__ចំណាំ__ : គណនីលេខ ៤៧៧ ត្រូវមានគំរូហត្ថលេខារបស់ម្ចាស់គណនី និងត្រូវចែកទៅជាអនុគណនីសំរាប់រតនាគារកណ្តាល សំរាប់រតនាគារខេត្ត-ក្រុង និងលំអិតតាមក្រសួង មន្ទីរដែលស្នើសុំបើកគណនីប្រាក់បញ្ញើរបស់រដ្ឋទេយ្យករចំណូល ។

៨៧-គណនី ចំណាយជាបណ្តោះអាសន្ន (បុរេប្រទានសាច់ប្រាក់) សំរាប់វិនិយោគ " លេខ ៤៧៨ " :

គណនីនេះបើកនៅរតនាគារកណ្តាលនិងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ជាចំណាយជាបណ្តោះអាសន្នលើការផ្តល់បុរេប្រទានសាច់ប្រាក់ទៅក្រសួង ស្ថាប័ន មន្ទីរ អង្គភាព (យោងតាមលិខិតសំរេចរបស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ឬ រតនាគារកណ្តាល)សំរាប់ការងារវិនិយោគ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់បុរេប្រទានទៅ ក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ក្រោមរូបភាពជាសាច់ប្រាក់ បង្វែរ ឬ មូលប្បទានប័ត្រ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយបង់ជាសាច់ប្រាក់ ឬបង្វែ
- កត់ត្រាចំនួនទឹកប្រាក់ដែលបានទូទាត់បុរេប្រទានដោយអាណត្តិបើកប្រាក់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលក្រសួង ស្ថាប័ន មន្ទីរ អង្គភាព បានទទួលហើយពុំទាន់បានទូទាត់ ។

__ចំណាំ__ : - គណនីនេះត្រូវចែកជាអនុគណនី សំរាប់កត់ត្រាការផ្តល់បុរេប្រទាននៅរតនាគារកណ្តាល នៅរតនាគារខេត្ត-ក្រុង និងលំអិតទៅតាមក្រសួង ស្ថាប័ន មន្ទីរ អង្គភាព ដែលបានទទួលប្រាក់បុរេប្រទាន

- គណនីនេះត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៨៨_គណនី ចំណូលត្រូវប្រមូលបានកត់ត្រាទុកមុន " លេខ ៤៨២ ":

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់បំណុលពន្ធ និងមិនមែនសារពើពន្ធដែលត្រូវទារពីអាជីវករ អ្នកជាប់ពន្ធ ។ គណនីលេខ ៤៨២ កត់ត្រាបដិភាគជាមួយគណនីអ្នកជាប់ពន្ធ និង អតិថិជន (លេខ ៤១១ ៤១២ និង ៤១៣) ដោយយោងតាមរបាយការណ៍ពីអង្គភាពពន្ធដារ អង្គភាពគយ និង រដ្ឋាករ ។

ការកត់ត្រា :

ឥណពន្ធ : - កត់ត្រាចំនួនទឹកប្រាក់ពន្ធ និងមិនមែនពន្ធដែលប្រមូលបាន ដោយកត់ត្រាបដិភាគនឹងគណនី អ្នកជាប់ពន្ធ ឬគណនីអតិថិជន

- កត់ត្រាចំនួនទឹកប្រាក់ពន្ធ មិនមែនពន្ធដែលបានជំរះដោយបន្ធូរបន្ថយ ឬ លប់ចោល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ពន្ធ និងមិនមែនសារពើពន្ធដែលត្រូវប្រមូល ដោយកត់ត្រាបដិភាគនឹងគណនីអ្នកជាប់ពន្ធ អតិថិជន (លេខ ៤១១ ៤១២ ៤១៣)

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ពន្ធ និងមិនមែនសារពើពន្ធដែលត្រូវប្រមូល ។

<u>**ចំណាំ**</u> : - ការកត់ត្រាខាងឥណទានគណនី លេខ ៤៨២ ទន្ទឹមនឹងលេខនាកត់ត្រាចំណូលពិតប្រាកដ ដែលប្រមូលបាន (ឥណពន្ធ គណនី ហិរញ្ញវត្ថុ និង ឥណទាន គណនី ចំណូលថវិកា)

- គណនីលេខ ៤៨២ ត្រូវចែកជាអនុគណនីសំរាប់តាមដានបំណុលពន្ធគយ បំណុលពន្ធដារ និងបំណុលមិនមែនសារពើពន្ធ ។

៨៩_គណនី បន្ទុកបានពិនិត្យកត់ត្រាមុន " លេខ ៤៨៦ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាបែងចែកចំនួនទឹកប្រាក់ចំណាយថវិកាមួយចំនួនសំរាប់យោងទៅកត់ត្រានៅការិយបរិច្ឆេទក្រោយ ។ ការបែងចែកត្រូវធ្វើនៅថ្ងៃទី ៣១ ខែ ធ្នូនៃ ការិយបរិច្ឆេទ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបែងចែកដោយបន្ថយចំណាយថវិកាឆ្នាំនេះទុកកត់ត្រាជាចំណាយថវិកាឆ្នាំបន្ទាប់

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានបែងចែកដោយផ្ទេរទៅជាចំណាយថវិកានៅឆ្នាំបន្ទាប់

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកបានពិនិត្យកត់ត្រាមុនពុំទាន់បានចាត់ចែង ។

ចំណាំ : គណនីនេះពុំមានគំរូបាត្តលេខាម្ចាស់គណនីទេ ហើយត្រូវចែកទៅជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ។

៩០-គណនី ផលបានពិនិត្យកត់ត្រាមុន " លេខ ៤៨៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានពីការបង់ជាសាច់ប្រាក់ បង្វែរ និងមូលប្បទានប័ត្រហើយត្រូវបែងវិលែកសំរាប់ទុកកត់ត្រាជាចំណូលថវិកានាការិយបរិច្ឆេទបន្ទាប់ ។ ការបែងវិលែកត្រូវធ្វើនៅថ្ងៃទី ៣១ ខែ ធ្នូ នៃការិយបរិច្ឆេទកំពុងអនុវត្ត ។

ការកត់ត្រា :

ឥណពន្ធ :កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាដែលបានធ្វើនិយ័ត្តកម្មបន្ថយពីឆ្នាំមុនហើយបានផ្ទេរជាចំណូលថវិកាឆ្នាំនេះ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណូលថវិកាត្រូវបែងវិលែកសំរាប់ជាចំណូលថវិកាឆ្នាំបន្ទាប់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់ចំណូលថវិកាដែលបានវិលែកសំរាប់ការិយបរិច្ឆេទក្រោយ ។

ចំណាំ : គណនីនេះពុំមានគំរូហត្ថលេខារបស់ម្ចាស់គណនីទេ ហើយត្រូវចែកទៅជាអនុគណនី សំរាប់ ប្រើនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ។

៩១-គណនី ចរន្តនៅធនាគារជាតិ នៃកម្ពុជា និងនៅសាខា " លេខ ៥១០ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយរបស់រតនាគារ របស់អង្គភាពពន្ធដារ អង្គភាពគយនិង រដ្ឋាករដែលកើតមាន នៅធនាគារជាតិ នៃកម្ពុជានិងនៅសាខាតាម ខេត្ត-ក្រុង ។ គណនីលេខ ៥១០ ឆ្លុះបញ្ចាំងប្រតិបត្តិការបញ្ច្រាសនឹងគណនីនៅធនាគារជាតិនៃកម្ពុជានិងនៅសាខា ខេត្ត- ក្រុង ហើយចែកជាអនុគណនី សំរាប់គណនីចរន្តរបស់រតនាគារ (ថ្នាក់កណ្តាល ថ្នាក់ខេត្ត-ក្រុង) របស់អង្គភាពគយ និងរដ្ឋាករ និងរបស់អង្គភាពពន្ធដារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានបង់ចូលធនាគារជាសាច់ប្រាក់ ដោយបង្វែរ និងបានពីការទូទាត់របស់សភា ផាត់ទាត់ជាមួយមូលប្បទានប័ត្រដែលបានទទួល

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ដែលបានដកពីធនាគារជាសាច់ប្រាក់ ដោយបង្វែរនិងការទូទាត់របស់សភា ផាត់ទាត់ជាមួយមូលប្បទានប័ត្រដែលបានបោះផ្សាយ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើរបស់រតនាគារដែលកំពុងមាននៅធនាគារ ។

ចំណាំ : - គណនីនេះត្រូវចែកជាអនុគណនី សំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារ ខេត្ត-ក្រុង អង្គភាពគយនិងរដ្ឋាករ និងសំរាប់អង្គភាពពន្ធដារ

- នៅរតនាគារ ខេត្ត-ក្រុង អនុគណនី លេខ ៥១០.២ ត្រូវចែកជាអនុគណនីបន្តសំរាប់បំរើអោយប្រតិបត្តិការថវិការដ្ឋ និងថវិកាខេត្ត-ក្រុង អនុគណនីបន្ត លេខ ៥១០.២.០១ និងអនុគណនីបន្ត សំរាប់បំរើអោយថវិកា ឃុំ សង្កាត់ (អនុគណនី លេខ ៥១០.២.០២) ។

៩២-គណនី មូលប្បទានប័ត្រធ្វើបេឡាទិញ " លេខ ៥១១ " :

គណនីនេះបើកនៅរតនាគារកណ្តាល នៅរតនាគារខេត្ត-ក្រុង នៅអង្គភាពគយ និងរដ្ឋាករ និងនៅអង្គភាព ពន្ធដារប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានទទួលហើយរង់ចាំការទូទាត់របស់សភាផាត់ទាត់ ឬធនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលរតនាគារបានទទួល និងរង់ចាំការទូទាត់របស់សភាផាត់ទាត់ ឬ ធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានទូទាត់ និងបាន បញ្ចូលទឹកប្រាក់ទៅគណនីចរន្ត

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានទទួល តែពុំទាន់បានទទួទាត់ ។

ចំណាំ : គណនីនេះត្រូវចែកជាអនុគណនីសំរាប់រតនាគារ អង្គភាពគយ និង រដ្ឋាករ អង្គភាពពន្ធដារ ហើយត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៩៣-គណនី មូលប្បទានប័ត្របានបោះផ្សាយ " លេខ ៥១២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលរតនាគារបានបោះផ្សាយជូនទៅអត្ថគាហកៈ ដែលរង់ចាំការទូទាត់របស់សភាផាត់ទាត់ ឬធនាគារ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រ ដែលបោះផ្សាយដោយរតនាគារហើយបានទូទាត់ដោយ សភាជាតំទាត់ ឬ ធនាគារ

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់នៃមូលប្បទានប័ត្របានបោះផ្សាយដោយរតនាគារដែលរង់ចាំការទូទាត់

សមតុល្យ : ឥណទាយី បង្ហាញចំនួនទឹកប្រាក់នៃមូលប្បទានប័ត្រដែលបានបោះផ្សាយដោយរតនាគារ ដែលពុំទាន់បានទូទាត់ ។

ចំណាំ : គណនីនេះត្រូវស្មូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៩៤.គណនី ប្រាក់រូបិយប័ណ្ណនៅធនាគារជាតិ នៃកម្ពុជា " លេខ ៥១៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយជារូបិយប័ណ្ណនៅធនាគារជាតិនៃកម្ពុជា ដោយយោងតាមអាណត្តិបើកប្រាក់ ឬតាមប្រកាសនៃការផ្ទេរផ្សេងទៀត ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលជារូបិយប័ណ្ណនៅធនាគារជាតិ នៃកម្ពុជា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយជារូបិយប័ណ្ណតាមអាណត្តិបើកប្រាក់ (ជាប្រតិបត្តិការថវិកា)

- កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្ទេរទៅគណនីផ្សេងៗ (ជាប្រតិបត្តិការរតនះវត្ថុ) យោងតាមការសំរេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងសក្ខីប័ត្ររបស់ធនាគារជាតិ នៃកម្ពុជា ។

សមតុល្យ : ឥណយិក បង្ហាញចំនួនទឹកប្រាក់ជារូបិយប័ណ្ណដែលកំពុងមាននៅធនាគារជាតិនៃកម្ពុជា ។

ចំណាំ : - គណនីលេខ ៥១៣ ត្រូវចែកទៅជាអនុគណនីសំរាប់ឆ្លុះបញ្ចាំងទៅនឹងគណនីទាំងឡាយ ដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

- ចំណូល ចំណាយតាមរយៈធនាគារជាតិជាប្រាក់ដុល្លារអាមេរិក តែការកត់ត្រានៅរតនាគារជាប្រាក់រៀលក្រោយពីការគិតតាមអត្រាប្តូរប្រាក់ផ្លូវការរបស់ធនាគារជាតិ នៃកម្ពុជា ។

- គណនីលេខ ៥១៣មានប្រតិបត្តិការបញ្ច្រាស នឹងគណនីដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

៩៥.គណនី ប្រាក់បញ្ញើជំនួយជាប្រាក់រៀលនៅធនាគារជាតិ នៃកម្ពុជា " លេខ ៥១៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយនៃប្រាក់ជំនួយ ឬប្រាក់ខ្ចីជាប្រាក់រៀលដែលផ្ញើនៅធនាគារជាតិនៃកម្ពុជា ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានមកពីជំនួយ ឬ ប្រាក់ខ្ចី ដោយបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយតាមអាណត្តិបើកប្រាក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយដោយផ្ទេរទៅគណនីផ្សេងទៀត

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើបានពីជំនួយដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

<u>**ចំណាំ**</u> : - គណនីលេខ ៥១៤ ត្រូវបែកទៅជាអនុគណនីសំរាប់ឆ្លុះបញ្ចាំងទៅនឹងគណនីទាំងឡាយដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

- គណនីលេខ ៥១៤ មានប្រតិបត្តិការបញ្ច្រាសនឹង គណនីនៅធនាគារជាតិនៃកម្ពុជា ។

៩៦_គណនី ប្រាក់បញ្ញើមូលនិធិនៅធនាគារក្រៅរតនាគារ " លេខ ៥១៦ " :

គណនីនេះបើកនៅរតនាគារកណ្តាល ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណូល ចំណាយនៃប្រាក់ជំនួយ ឬប្រាក់ខ្ចីជាប្រាក់រៀលហើយផ្ញើនៅធនាគារជាតិនៃកម្ពុជាដោយយោងតាមអាណត្តិបើកប្រាក់ ឬតាមប្រកាសការផ្ទេរផ្សេងទៀត។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណូលដែលបានមកពីជំនួយ ឬ ប្រាក់ខ្ចី ដោយបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយតាមអាណត្តិបើកប្រាក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- កត់ត្រាចំនួនទឹកប្រាក់ចំណាយដោយផ្ទេរទៅគណនីផ្សេងទៀត

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បញ្ញើបានពីជំនួយដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

<u>**ចំណាំ**</u> :- គណនីលេខ ៥១៦ ត្រូវបែកទៅជាអនុគណនីសំរាប់ឆ្លុះបញ្ចាំងទៅនឹងគណនីទាំងឡាយដែលមាននៅធនាគារជាតិ នៃកម្ពុជា ។

- គណនីលេខ ៥១៤ មានប្រតិបត្តិការបញ្ច្រាសនឹង គណនីនៅធនាគារជាតិនៃកម្ពុជា ។

៩៧_គណនី បេឡាសាច់ប្រាក់" លេខ ៥៣២ " :

គណនីនេះបើកនៅរតនាគារកណ្តាល នៅរតនាគារខេត្ត-ក្រុង នៅអង្គភាពគយ និងរដ្ឋាករ និងនៅអង្គភាពពន្ធដារ ប្រើសំរាប់កត់ត្រាចំនួនសាច់ប្រាក់ចំណូល ចំណាយបេឡាប្រចាំថ្ងៃ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនសាច់ប្រាក់ដែលបានបង់ចូលបេឡា

ឥណទាន : កត់ត្រាចំនួនសាច់ប្រាក់ដែលបានដកចេញពីបេឡា

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនសាច់ប្រាក់ដែលមានក្នុងបេឡា ។

ចំណាំ : គណនីលេខ ៥៣២ ត្រូវចែកជាអនុគណនីសំរាប់ប្រើនៅរតនាគារកណ្តាល រតនាគារខេត្ត-ក្រុង អង្គភាពគយ និងរដ្ឋាករ និង សំរាប់អង្គភាពពន្ធដារ ។

៩៨-គណនី រដ្ឋទេយ្យករបុរេប្រទាន " លេខ ៥៤៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានសំរាប់ចរិកាមិនមែនកម្មវិធី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ដោយអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ជាសាច់ប្រាក់ ឬបង្វែរ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលរដ្ឋទេយ្យករបុរេប្រទាន ពុំទាន់បានទូទាត់ជាមួយរតនាគារជាអាណត្តិបើកប្រាក់ ឬ ជាសាច់ប្រាក់ ។

ចំណាំ : - គណនីរដ្ឋទេយ្យករបុរេប្រទានត្រូវចែកជាអនុគណនីសំរាប់រតនាគារកណ្តាល រតនាគារខេត្ត-ក្រុង និងលំអិតទៅតាម ក្រសួង ស្ថាប័ន និង មន្ទីរនីមួយ ៗ

- ការបង្កើន ឬការបន្ថយកំរិតកំណត់រដ្ឋទេយ្យបុរេប្រទាន គឺត្រូវធ្វើនៅក្រៅបញ្ជីការគណនេយ្យ ។

- គណនី លេខ ៥៤៣ ត្រូវសូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

៩៩-គណនី រដ្ឋទេយ្យករបុរេប្រទាន កម្មវិធី " លេខ ៥៤៤ " :

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទាន សំរាប់ចរិកាតាមកម្មវិធី ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ដែលបានផ្តល់ទៅរដ្ឋទេយ្យករបុរេប្រទានជាសាច់ប្រាក់ ឬបង្វែរ

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ដោយអាណត្តិបើកប្រាក់

- កត់ត្រាចំនួនទឹកប្រាក់បុរេប្រទានដែលបានទូទាត់ជាសាច់ប្រាក់ ឬបង្វែរ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់បុរេប្រទានដែលរដ្ឋទេយ្យករបុរេប្រទាន ពុំទាន់បានទូទាត់ជាមួយរតនាគារជាអាណត្តិបើកប្រាក់ ឬ ជាសាច់ប្រាក់ ។

ចំណាំ : - គណនីរដ្ឋទេយ្យករបុរេប្រទានត្រូវចែកជាអនុគណនីសំរាប់រតនាគារកណ្តាល រតនាគារខេត្ត-ក្រុង

និងលំអិតទៅតាម ក្រសួង ស្ថាប័ន មន្ទីរ និងអង្គភាពអនុវត្តកម្មវិធី

- ការបង្កើន ឬការបន្ថយក៏រិតកំណត់រជ្ជទេយ្យបុរេប្រទាន គឺត្រូវធ្វើនៅក្រៅបញ្ជីការគណនេយ្យ
- គណនី លេខ ៩៤៣ ត្រូវស្មូន្យសមតុល្យនៅដំណាច់ឆ្នាំ ។

១០០_គណនី ចំណាយទិញសំភារៈផ្គត់ផ្គង់ថែទាំ " លេខ ៦០១ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំភារៈផ្គត់ផ្គង់ថែទាំ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០១ ត្រូវចែកទៅជាអនុគណនីសំរាប់ ចំណាយទិញសំភារៈសំអាត និងអនាម័យ ចំណាយទិញសំភារៈសំរាប់ថែទាំអគារ ទិញសំភារៈសំរាប់ថែទាំផ្លូវ ថ្នល់ ស្ពាន និង លូ ទិញសំភារៈថែទាំសំភារៈឧបករណ៍គ្រឿងម៉ាស៊ីន សំរាប់ទិញប្រេងឥន្ធនៈ និងសំរាប់ប្រេងរំអិល ។

១០១_គណនី ចំណាយទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល " លេខ ៦០២ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាប្ញកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០២ ត្រូវចែកទៅជាអនុគណនីសំរាប់ ចំណាយទិញសំភារៈការិយាល័យ និង ការបោះពុម្ព ទិញសៀវភៅមើល និងការងារ និងសំរាប់ទិញសំភារៈផ្គត់ផ្គង់ផ្នែករដ្ឋបាលផ្សេងៗ ទៀត ។

១០២_គណនី ចំណាយទិញស្បៀងអាហារ និងផលិតផលកសិកម្ម " លេខ ៦០៣ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និង នៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រា ចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញចំណីអាហារ និង ផលិតផលកសិកម្ម ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០៣ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញស្បៀង ទិញចំណីសត្វ ទិញពូជ និងកូនរុក្ខជាតិ ទិញផលិតផលការពារសុខមាលភាពរុក្ខជាតិ និងជី ទិញពូជសត្វ ឱសថ និងវត្ថុធាតុបសុពេទ្យ និងសំរាប់ទិញផលិតផលផ្សេងៗ ទៀត ។

១០៣_គណនី ចំណាយទិញសំលៀកបំពាក់ និង ការតុបតែង" លេខ ៦០៤ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំលៀកបំពាក់ និង ការតុបតែងលំអ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០៤ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយទិញឯកសណ្ឋាន ទិញសំលៀកបំពាក់ការពារសុវត្ថិភាព ទិញមេដាយ (គ្រឿងឥស្សរយស) និងសំរាប់ទិញសំលៀកបំពាក់ការតុបតែងផ្សេងៗទៀត ។

១០៤_គណនី ចំណាយទិញសំភារៈតូចតាច សង្ហារឹម និងសំភារៈបរិក្ខា" លេខ ៦០៥ ":

គណនីនេះ បើកនៅរតនាគារកណ្តាល និងនៅរតនាគារ ខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំភារៈ សង្ហារឹម និង ទិញសំភារៈ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០៥ ត្រូវចែកទៅជាអនុគណនីសំរាប់ចំណាយទិញ សំភារៈ និងបរិក្ខារ ទិញសង្ហារឹម ទិញសំភារៈប្រើប្រាស់ និងសំរាប់ទិញសំភារៈផ្សេងៗទៀត ។

១០៥_គណនី ចំណាយទិញថាមពល និង ទឹក " លេខ ៦០៦ " :

គណនីនេះ បើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទូទាត់លើការប្រើប្រាស់ថាមពល និង ការប្រើប្រាស់ទឹក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

ចំណាំ : គណនីលេខ ៦០៦ ត្រូវចែកទៅជាអនុគណនីសំរាប់ចំណាយលើអគ្គិសនី ចំណាយលើទឹក និងសំរាប់ចំណាយលើថាមពលផ្សេងៗ ។

១០៦_គណនី ចំណាយទិញសំភារៈបរិក្ខារថែទាំសុខភាព " លេខ ៦០៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំភារៈបរិក្ខារ ថែទាំសុខភាព ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១០៧_គណនី ចំណាយទិញសំភារៈផ្គត់ផ្គង់ផ្សេង ៗ " លេខ ៦០៨ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទិញសំភារៈផ្សេងៗ ទៀត ដែលពុំបានរៀបរាប់ខាងលើ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយដែលផ្ទេរទៅគណនីលទ្ធផលនៃការអនុវត្តន៍ថវិកាចរន្តនៅចុងការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១០៨_គណនី ចំណាយលើកិច្ចសន្យានៃការផ្តល់សេវាជាមួយសហគ្រាស "លេខ ៦១១ ":

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើទូទាត់ជូនទៅសហគ្រាស ក្រុមហ៊ុន ឬ អាជីវករដែលបានផ្តល់សេវាកម្មដល់ក្រសួង មន្ទីរ អង្គភាពរដ្ឋ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១០៩_គណនី ចំណាយឈ្នួលមធ្យោបាយដឹកជញ្ជូន " លេខ ៦១២ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទូទាត់ថ្លៃឈ្នួលមធ្យោបាយដឹកជញ្ជូនធ្វើដំណើរ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១១០_គណនី ចំណាយថ្លៃឈ្នួល និង បន្ទុក (អសង្ហារឹម) " លេខ ៦១៣ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការទូទាត់លើឈ្នួលទីតាំង និងបន្ទុក ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : - កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណពន្ធ បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១១១_គណនី សោហ៊ុយបណ្តុះបណ្តាលបុគ្គលិក "លេខ ៦១៤ ":

គណនីនេះបើកនៅរតនាគារកណ្តាល និង នៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការបណ្តុះបណ្តាលបុគ្គលិក និងកិច្ចសន្យានៃអ្នកជំនាញការ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១១២. គណនី ចំណាយលើការថែទាំ និង ជួសជុល " លេខ ៦១៥ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការថែទាំ ជួសជុល ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹក ប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

<u>**ចំណាំ**</u> : គណនីលេខ ៦១៥ ត្រូវចែកទៅជាអនុគណនី សំរាប់ចំណាយលើការថែទាំ ដីធ្លី ព្រៃឈើ និងតំបន់ផ្លែ ការថែទាំ និងជួសជុលអគារ និងប្រាសាទ ការថែទាំ និងជួសជុលផ្លូវ ផ្លូវលំ ស្ពាន និង លូ ការថែទាំបណ្តាញផ្សេងៗ ការថែទាំដែនទេសាទ ការថែទាំ និងជួសជុលមធ្យោបាយដឹកជញ្ជូន ការថែទាំនិងជួសជុលសំភារៈឧបករណ៍ការិយាល័យ សំភារៈព័ត៌មានវិទ្យានិងទូរគមនាគមន៍ និងសំរាប់ការថែទាំ និងជួសជុលសំភារៈឧបករណ៍បច្ចេកទេស ។

១១៣. គណនី សោហ៊ុយធានារ៉ាប់រង " លេខ ៦១៦ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការបង់សោហ៊ុយធានារ៉ាប់រងផ្សេង ៗ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណទេយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

១១៤_គណនី សោហ៊ុយសិក្សាពិសោធន៍ សោហ៊ុយនៃការប្រើប្រាស់សេវា និងសោហ៊ុយនៃការប្រើប្រាស់សិទ្ធិ " លេខ ៦១៧ " :

គណនីនេះបើកនៅរតនាគារកណ្តាល និងនៅរតនាគារខេត្ត-ក្រុង ប្រើសំរាប់កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិការដ្ឋលើការសិក្សាពិសោធន៍ ការប្រើប្រាស់សេវា និង ការប្រើប្រាស់សិទ្ធិ ។

ការកត់ត្រា :

ឥណពន្ធ : កត់ត្រាចំនួនទឹកប្រាក់បានចំណាយថវិកា

ឥណទាន : កត់ត្រាចំនួនទឹកប្រាក់ចំណាយថវិកាដែលផ្ទេរទៅគណនីលទ្ធផលនៃការិយបរិច្ឆេទ

សមតុល្យ : ឥណាយិក បង្ហាញចំនួនទឹកប្រាក់ចំណាយថវិកាបូកបន្ត ដែលពុំទាន់បានផ្ទេរទៅគណនីលទ្ធផល ។

